ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ស្រុកបោះ [illegible]
- [illegible] ខេត្តតាកែវ

[illegible]

លេខ៣០ ខែមិថុនា ឆ្នាំ២០០២

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣០ ខែមិថុនា ឆ្នាំ២០០២


## មាតិកា


◆ សំបុត្រៈ ស្រមោលយុត្តិធម៌នៅកម្ពុជា ....................................១

**ផ្នែកឯកសារ**

◆ ប្រវត្តិរូបរបស់ ដួន កន្ថា ....................................................២

◆ សេចក្តីព្រាងគោលនយោបាយរបស់បក្សចំពោះនារី.................. ៦

◆ ទីតាំងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះ .............................៩

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១........ ១២

◆ ការជួបសន្ទនារវាងសមមិត្ត អៀង សារី ..............................១៤

◆ ការសន្ទនារបស់សមមិត្ត អៀង សារី.......................................១៨

◆ នួន ជា បដិសេធថាមិនបានសម្លាប់មនុស្ស ............................២០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ នៅពេលដែលការអត់ឃ្លានចូលមកដល់ ...................................២៣

◆ ថ្នាំអាចម៍ទន្សាយ ..........................................................................២៦

◆ សម្លេងពីមន្ទីរស-២១ ...................................................................២៩

◆ អ្នកស្រុកអន្លង់វែងមិនជឿថា តាម៉ុក ......................................៣៦

◆ អប់រំកុមារបដិវត្ត ស្រុកត្រាំកក់ ខេត្តតាកែវ............................៣៨

**ផ្នែកច្បាប់**

◆ ក្រមច្បាប់នីតិវិធីជាអប្បបរមា .....................................................៤៨

**វេទិកាពិភាក្សាសាធារណៈ**

◆ យុទ្ធសាស្ត្រការពារប្រទេសរបស់ខ្មែរក្រហម ................................៥១

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ បាត់បងប្រុសជាងម្ភៃឆ្នាំហើយ ....................................................៥៧

**សិល្បៈខ្មែរក្រហម**

◆ រឿងបដិវត្តៈ ស្នារតីឈ្លាសវៃរបស់កុមារឃ្វាលក្របី.............. ៦០

◆ កំណាព្យៈ ដាច់ខាតការពារព្រំដែនកម្ពុជាដ៏ពិសិដ្ឋ!...........ក្របក្រោយ




កុមារបដិវត្ត


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១៣ម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


(រូបថតក្របមុខផ្តល់ឲ្យដោយ ចូសេហ្វ កុហ្វម៉ាន់)
រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


***វាគ្មិនលេខនេះ:*** *ដេវីត ឆេនដល័រ, អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ហ៊ុយ វណ្ណៈ, គីម កែវកន្និដ្ឋា, អែម សុខឃីម* ***អ្នកនិពន្ធនិងស្រាវជ្រាវ:*** *លី សុផល, ដួង សុភារិទ្ធ* ***ជំនួយការនិពន្ធនាយក:*** *សាន់ កល្យាណ* ***និពន្ធនាយករងទី១:*** *ស៊ួ ប៊ុនស៊ូ* ***និពន្ធនាយករងទី២:*** *សឹម សុរិយ៉ា* ***អ្នកបកប្រែ:*** *អេង កុកថាយ* ***និពន្ធនាយកទូទៅ:*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រ:*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយ :*** *សុខ វណ្ណៈ*

*សំបុត្រៈ*

# ស្រមោលយុត្តិធម៌នៅកម្ពុជា
# តម្លៃជីវិតខ្មែរ

ការចាប់ខ្លួនអតីតមេបញ្ជាការខ្មែរក្រហម សមមិត្ត សំ ប៊ិត (ប៊ិត ឬ រ៉ាញ់ ប៊ិត) គឺជាសកម្មភាពដែលបម្រើឲ្យយុត្តិធម៌ ប៉ុន្តែវាអាចនឹងក្លាយទៅជាសកម្មភាពបិទបាំងការពិតទាំងស្រុងមួយទៅវិញ ប្រសិនបើកម្មាភិបាលខ្មែរក្រហមរូបនេះត្រូវបានវិនិច្ឆ័យទោសពីបទធ្វើឃាតជនបរទេសមុនពេលដែលត្រូវប្រឈមមុខនឹងការកាត់សេចក្តីពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនកម្ពុជា ។ ប្រជាជនកម្ពុជាប្រមាណ២លាននាក់បានស្លាប់បាត់បង់ជីវិតដោយសារទារុណកម្ម ធ្វើការបាក់កម្លាំង ជំងឺ ការសម្លាប់ និងគ្រោះទុរ្ភិក្សដែលញាំញីនៅក្នុងរបបវាលពិឃាតខ្មែរក្រហមអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។

ប៉ុល ពត ដែលជាមេដឹកនាំរបបខ្មែរក្រហម បានស្លាប់នៅឆ្នាំ១៩៩៨ ។ កម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់មួយចំនួនទៀតដូចជា អៀង សារី, អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន កំពុងតែរស់នៅប្រកបដោយសេរីភាពក្នុងប្រទេសកម្ពុជានៅឡើយ ។

រាជរដ្ឋាភិបាលកម្ពុជាបានចាប់ខ្លួនសមមិត្ត សំ ប៊ិត នៅថ្ងៃពុធ ទី២២ ខែឧសភា វេលាម៉ោង៧ៈ៣០ព្រឹក (នៅផ្ទះរបស់ សំ ប៊ិត ផ្ទាល់) ពីបទពាក់ព័ន្ធទៅនឹងការវាយឆ្មក់លើរថភ្លើងនៅភាគខាងត្បូងនៃខេត្តកំពត និងសម្លាប់ទេសចរបរទេសចំនួន៣រូបក្នុងខែកក្កដាឆ្នាំ១៩៩៤ ។ ជនបរទេសទាំងបីនាក់នោះរួមមានឈ្មោះ ប្រ៊ីតគុន ម៉ាក្ស (ជនជាតិអង់គ្លេស), ហ្សង់ ម៉ៃឃើល ប្រាកែត (ជនជាតិបារាំង) និង ដាវីដ វីលសុន (ជនជាតិអូស្ត្រាលី) ។

នៅក្នុងពេលជាមួយគ្នា ក៏មានជនជាតិខ្មែរមួយចំនួនត្រូវបានសម្លាប់នៅពេលវាយប្រហាររថភ្លើងនោះ ។

សមមិត្ត សំ ប៊ិត គឺជាអតីតអនុលេខារងនៃបក្សកុម្មុយនិស្តកម្ពុជាប្រចាំភូមិភាគនិរតី ដែលមាន តាម៉ុក ជាលេខានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បច្ចុប្បន្ននេះ តាម៉ុកកំពុងជាប់ឃុំឃាំងអស់រយៈពេលជាង៣ឆ្នាំមកហើយ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

តើអធិបតេយ្យភាពកម្ពុជាដែលប្រើប្រាស់សម្រាប់ស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះរបស់ខ្លួនរាប់លាននាក់ នឹងចាប់ផ្តើមពីការផ្តល់យុត្តិធម៌ដល់ជនបរទេសចំនួន៣រូប?

**ឆាំង យុ**

# ប្រវត្តិរូបរបស់ ជួន កន្ថា

**I. អំពីផ្ទាល់ខ្លួន**

១) ឈ្មោះដើមៈ ជួន កន្ថា ឈ្មោះបដិវត្តៈ ណាក់

២) ទីកន្លែងកំណើតៈ ប៉ារីសទី XVII ប្រទេសបារាំង

ទីកន្លែងរស់នៅមុនចូលបដិវត្តៈ ប្រទេសបារាំង

កើតនៅថ្ងៃទី១០ ខែ៦ ឆ្នាំ១៩៥៥

៣) ភេទស្រី ជនជាតិខ្មែរ

៤) នៅលីវ

៥) វណ្ណៈភាពដើមមុនចូលបដិវត្តៈ អនុធនសិស្ស

គ្រួសារខ្ញុំមានឪពុកម្ដាយនិងបងប្អូនទាំងអស់៥នាក់ ។ មានផ្ទះមួយ៥បន្ទប់ ឡានមួយ ។ ចំពោះផ្ទាល់ខ្លួនគ្មានធ្វើអ្វីទេ គិតតែរៀនសូត្រ ។ តាំងពីរស់នៅប្រទេសបារាំង១ឆ្នាំហើយមកប្រទេសយើងវិញនៅភ្នំពេញ ។ តាំងពីអាយុ៦ឆ្នាំ ចូលសាលាកាល់ម៉ែតនៅភ្នំពេញ ។ រួចហើយឆ្នាំ១៩៦៣ ដោយសារពួកអាសីហនុថាឪពុកជាខ្មែរក្រហម ក៏ត្រូវចេញពីប្រទេសយើងយ៉ាងរហ័ស ដូច្នេះក៏ខ្ញុំត្រូវចេញទៅប្រទេសបារាំងជាមួយឪពុកមុនម្ដាយនិងប្អូន មុនដល់ប្រទេសបារាំងក៏ឆ្លងទៅប្រទេសឆេកូស្លូវ៉ាគីមួយរយៈ ។ ដល់ប្រទេសបារាំងខែ៥ ឆ្នាំ១៩៦៣ ។ ពេលនោះក៏រស់ជាមួយបងឪពុក (ជួន មុម) ។ ខែ៩-១៩៦៣ ត្រូវចូលសាលាថ្នាក់ទី៨ តែដោយមិនសូវចេះបារាំងក៏ត្រូវធ្លាក់មួយថ្នាក់នៅថ្នាក់ទី៩ ។ ខែ១២-១៩៦៣ ក៏ម្ដាយនិងប្អូនមកដល់ប្រទេសបារាំង ។ ពេលនោះក៏ឪពុកបានការងារធ្វើ បានផ្ទះសមហភាពដែលជិពាក់លុយរាល់ខែនិងឡាន១ ។ ដល់ឆ្នាំ១៩៧០ ខែ៥ ក៏បានទិញផ្ទះវីឡាមួយ ។ ឆ្នាំ៧០ឡើងទៅ ឪពុកទៅប៉េកាំង ហើយចំពោះផ្ទាល់ខ្លួនក៏នៅតែដដែលគឺថារៀននៅសាលាបារាំង ។ ក្រៅពីការរៀនសូត្រនៅសាលាក៏មានការមើលកូនគេក្នុងរយៈពេលដែលផ្អាករៀនម្ដង១ ។ លទ្ធផលនៃការងារនេះគឺយកទៅទិញសៀវភៅរៀន និងទិញខោអាវរបស់ផ្ទាល់ ។ ធ្វើដូច្នេះមិនមែនដោយសារឪពុកម្ដាយដោះស្រាយមិនរួចទេ សំខាន់គឺដើម្បីម្ចាស់ការក្នុងការដោះស្រាយបញ្ហាបន្តិចបន្តួចរបស់ផ្ទាល់ខ្លួន ។ និយាយរួមមិនដែលមានការខ្វះខាតក្នុងជីវភាពរស់នៅប្រចាំថ្ងៃទេ ។ ដល់ឆ្នាំ៧២ ដោយសារពួកបារាំងនៅក្នុងសាលាដឹងថាឪពុកនៅប៉េកាំង ក៏ចាប់ផ្ដើមធ្វើសកម្មភាពកុំឲ្យខ្ញុំរៀនដើម្បីឡើងថ្នាក់ ។ ដូច្នេះពេលនោះក៏បានឃើញគ្មានអនាគតចំពោះផ្ទាល់ខ្លួនក៏បានស្នើទៅប្រទេសចិន ។ ពេលនោះដោយសារមិនទាន់ក្ដាប់សភាពការណ៍នៅក្នុងប្រទេសយើង ក៏ដូចមិនទាន់មានគោលជំហរស្នេហាជាតិ ក៏បាននិយាយថា ទៅតែ១ឆ្នាំដើម្បីរៀនជាអក្សរចិនទេ ។ ម្យ៉ាងទៀតដោយសម្ពារទាញអូសផង ។ ថ្ងៃ២៩ ខែ១០ ឆ្នាំ១៩៧២ ចេញពីប្រទេសបារាំងទៅប្រទេសចិន ។

៦) ក្រោយពីចូលបដិវត្តន៍ក៏នៅប៉េកាំង រស់នៅក្នុងសមហភាពហូបជាសមូហភាព ។ ក៏ប៉ុន្តែសមហភាពនេះនៅតែមានប្រាក់ខែ ។ នៅកន្លែងនោះគឺជាកន្លែងមួយដែលខ្មែរយើងមកពីគ្រប់ប្រទេសដើម្បីមកជួយធ្វើការងារនយោបាយក្រៅប្រទេសក្នុងរយៈពេលសង្គ្រាមហើយដែលជាកន្លែងដែលលត់ដំមួយកម្រិតទាបនិងរៀនសូត្រតាមដានសភាពការណ៍នៅក្នុងប្រទេសយើង ។ នៅក្នុងសមូហភាពនេះមួយចំនួនតិចល្អស្មោះត្រង់ជាមួយបដិវត្តន៍ ។ មួយចំនួនធំគាំទ្របដិវត្តន៍ជារូបភាពប្រឆាំងបដិវត្តន៍ជាខ្លឹមសារ ។ នៅក្នុងនេះមានខ្សែកា.ហេ្វ.បេទាំងអស់ ។ ចំពោះផ្ទាល់ខ្លួនក៏មិនបានមានការទាក់ទងប៉ុន្មានជាមួយពួកទាំងអស់នេះទេ ព្រោះម្យ៉ាងខ្ញុំនៅនារីតែម្នាក់ឯងទេ ក្រៅពីនេះសុទ្ធតែយុវជនឬគ្រួសារមួយចំនួនតិច ។ ម្យ៉ាងទៀត ក៏ខ្ញុំត្រូវទៅរៀនសូត្រនៅសាលាចិនហើយទៅកន្លែងនោះមួយអាទិត្យមួយដង ។ ដូច្នេះតាំងពីឆ្នាំ៧២ ទៅដល់ខែ៩ ឆ្នាំ៧៣ ក៏រៀនអក្សរចិនមួយរយៈពេល៥ខែ

ជាមួយលោកគ្រូមួយ ។ ខែ៩ ឆ្នាំ៧៣ ទៅដល់ខែ៦ ឆ្នាំ៧៤ រៀននៅសាលាចិន ។ សាលានេះជាសាលាធ្វើភាសាចិនចំពោះគ្រប់ប្រទេសណាដែលចង់រៀន ។ ខែ៩ ឆ្នាំ៧៤ ទៅដល់ខែ៩ ឆ្នាំ៧៥ ទៅកង់ទុង រៀនវិជ្ជាពេទ្យជាមូលដ្ឋាន ។ ឆ្នាំ៧៥ ចុងខែ៩ អង្គការស្នើឲ្យយើងខ្ញុំចូលប្រទេសវិញ ក៏បានមកវិញ និងសល់មួយចំនួនតូចនៅរៀនសូត្រ ។ ចំពោះផ្ទាល់ខ្លួនមានការចាប់ផ្តើមយកចិត្តទុកដាក់រៀនភាសាខ្មែរតាំងពីឆ្នាំ១៩៧៤ ។

មកដល់ប្រទេសយើង មុនដំបូងនៅផ្ទះជិត ក-២ រយៈពេល ៣ថ្ងៃ រួចហើយទៅមន្ទីរ ប-៤ ដែលជាមន្ទីរមួយសំរាប់ឲ្យខ្មែរមកពីបរទេសភាគច្រើនមករៀនសូត្រឆ្លងជីវទស្សន៍បដិវត្តន៍មុននឹងចុះទៅមូលដ្ឋាន ។ ម្យ៉ាងទៀតជាកន្លែងមួយសំរាប់ដាក់ ប៉ែននុត និងគ្រួសារ ។ អ្នកទទួលខុសត្រូវគឺ សមមិត្តសន (យុទ្ធជនដែលមកពីក្រៅប្រទេសក្នុងរយៈពេលសង្គ្រាម គឺថាដើមឆ្នាំ ១៩៧៣) ។ លើកនោះរៀនសូត្រជាមួយ អ៊ីហែម ។ ក្រោយដែលបានរៀនសូត្រ ក៏មិត្តយើងទាំងអស់ត្រូវចុះទៅមូលដ្ឋាននៅកំពង់ចាម ។ ឯចំពោះផ្ទាល់ខ្លួនដោយសារឈឺក៏នៅ ប-៤ ដដែលប្រហែលរយៈ៣អាទិត្យ ។ ចេញពីកន្លែងនោះ ក៏ត្រូវទៅ ប-១ រយៈពេល៣ខែ ។ រួចហើយក៏ត្រូវចាត់តាំងទៅបកប្រែនៅ ព-១ និង ព-៣ ។

៦) ចូលបដិវត្តន៍ថ្ងៃទី២៩ ខែ១០ ឆ្នាំ១៩៧២ នៅប៉េកាំង ប្រទេសចិន ។ ម្យ៉ាងជាឪពុកនាំឲ្យចូល ដោយខស្សរាប់សរសេរសំបុត្រពន្យល់សភាពការណ៍នៅប្រទេសយើង និងប្រៀបធៀបអនាគតយើងខ្ញុំក្នុងសង្គមបដិវត្តន៍និងក្នុងសង្គមនាយទុន ។ ម្យ៉ាងទៀត ចំពោះខ្លួនខ្ញុំផ្ទាល់ ពេលនោះមិនទាន់យល់អ្វីដែលហៅបដិវត្តន៍ អ្វីដែលហៅវណ្ណៈ អ្វីដែលហៅបដិវត្តន៍រំដោះជាតិរំដោះប្រជាជន ដូច្នេះក៏ខ្វះខាតជំហរស្នេហាជាតិដែរ ។

៧) មុនចូលបដិវត្តន៍ មុនដំបូងគ្មានភារកិច្ចអ្វីច្បាស់លាស់ទេ ។ ឆ្នាំ៧៣ដល់ខែ៦ ឆ្នាំ៧៤ រៀនជាអក្សរចិននៅប៉េកាំង ។ ខែ៩ ឆ្នាំ៧៤ ដល់ខែ៩ ឆ្នាំ៧៥ រៀនវិជ្ជាពេទ្យជាមូលដ្ឋាននៅកង់តុង ។ ខែ១០ ឆ្នាំ៧៥ ដល់ខែ២ ឆ្នាំ៧៦ ពលកម្មបង្កបង្កើនផលនៅ ប-១ ទទួលខុសត្រូវ ពូហុង ។ ខែ២ ឆ្នាំ៧៦ ដល់ខែ១ ឆ្នាំ៧៧ បកប្រែជាភាសាចិននៅពេទ្យបដិវត្តន៍សំរាប់កុមារ ព-១ អ្នកទទួលខុសត្រូវ បងធី ។ ខែ២ ឆ្នាំ៧៧ ដល់បច្ចុប្បន្ន បកប្រែជាភាសាចិននៅពេទ្យបដិវត្តន៍សំរាប់កូន ព៣ អ្នកទទួលខុសត្រូវបងមិញ ។

៨) កំរិតវប្បធម៌ក្នុងសង្គមចាស់ៈ រៀនដល់ថ្នាក់ទី៩នៅភ្នំពេញ (សាលាកាលម៉ែត) ។ រៀនដល់ថ្នាក់ទី២នៅប្រទេសបារាំង ។

សង្គមថ្មីរាប់ពីចូលបដិវត្តន៍មកៈ រៀនជាភាសាចិននៅប៉េកាំង (ប្រទេសចិន) និងវិជ្ជាបច្ចេកទេសពេទ្យនៅកង់ទុង ។ ចូលប្រទេសយើងហើយគឺជួយបង្ហាត់បណ្តាមិត្តយើង ។

៩) ពេលដែលខ្ញុំនៅប្រទេសបារាំង មនុស្សដែលរៀនភាគច្រើនគឺវណ្ណៈភាពអនុធននិងនាយទុន ។ ចំពោះផ្ទាល់ខ្លួនក៏មិនដែលមានមិត្តជិតស្និទ្ធខាងវណ្ណៈភាពទាំងអស់នេះ ពិតមែនតែមានឥទ្ធិពល ពីព្រោះបានជួបរាល់ថ្ងៃពេលរៀនដែរ ។ ក្រៅពីនេះពេលផ្អាករៀន២ខែក្នុង១ឆ្នាំៗ ក៏ចូលរួមជីវភាពជាមួយវណ្ណៈភាពកម្មករ ។ ខ្ញុំមិនដែលបានរស់ជាមួយមជ្ឈដ្ឋានកសិករទេ ។

ពេលខ្ញុំនៅប្រទេសចិន ខ្ញុំនៅរស់ក្នុងសមហភាពខ្មែរពិតមែនតែជាមជ្ឈដ្ឋានអនុធនសិស្សនិងបញ្ញាជន ។ នៅជុំវិញផ្ទាល់ខ្លួនជាមិត្តចិនមជ្ឈដ្ឋានកម្មករ-កសិករ ។ ទើបដល់ប្រទេសយើងបានរួមជីវភាពក្នុងមជ្ឈដ្ឋានកសិករ ។ ដូច្នេះនិយាយរួម មុនចូលបដិវត្តន៍ធ្លាប់រួមជីវភាពនៅមជ្ឈដ្ឋានអនុធនសិស្ស-បញ្ញាជន និងក្រោយចូលបដិវត្តន៍ ពិសេសក្រោយមកប្រទេសយើងវិញបានរួមជីវភាពក្នុងមជ្ឈដ្ឋានកសិករ ។

ឆ្លងតាមការរួមជីវភាពក្នុងមជ្ឈដ្ឋានទាំងអស់នេះឃើញថាមជ្ឈដ្ឋានអនុធននៅមានកម្មសិទ្ធិបុគ្គល ផ្នែកសម្ភារៈក្តី សតិអារម្មណ៍ក្តីជាច្រើន ។ មិនចេះមានសាមគ្គីធំទូលាយ ចេះតែសាមគ្គីមានផលប្រយោជន៍ ។ ឆាប់យល់និងក្តាប់មាគ៌ារបស់បក្ស មានជំហរស្នេហាជាតិ តែខ្វះជំហរស្នេហាបដិវត្តន៍ បណ្តាលឲ្យមិនបានអនុវត្តមាគ៌ារបស់បក្សឲ្យបានដាច់ខាត ។ ឯមជ្ឈដ្ឋានកសិករវិញមានស្មារតីលះបង់ខ្ពស់បំផុត ចេះទ្រាំទ្រការលំបាកវេទនាពុះពារគ្រប់ឧបសគ្គ មានសាមគ្គីធំទូលាយណាស់ចំពោះគ្រប់មជ្ឈដ្ឋានឲ្យតែដើរតាមបដិវត្តន៍ ពេលយល់និងក្តាប់មាគ៌ារបស់បក្ស ក៏អនុវត្តស្លាប់រស់ដាច់ខាតជាមួយបក្ស ។ តែនៅមានការឃើញយ៉ាវក្នុង

ការធ្វើការងារប្រចាំថ្ងៃ ។

១០) ធ្លាប់រៀនជាវគ្គនយោបាយ៥ដង (២ដងនៅប៉េកាំង ៣ដងនៅប្រទេសយើង)

១១) ធ្លាប់ធ្វើប្រវត្តិរូបសង្ខេប១ដង លំអិត២ដងទាំងលើកនេះ និងឆ្លងជីវទស្សន៍បដិវត្តន៍៣ដង ។

១២) គុណសម្បត្តិធំៗគឺចង់កសាងខ្លួនឲ្យទៅជានារីមួយដែលមានគោលជំហរស្នេហាជាតិ ស្នេហាបដិវត្តន៍រឹងប៉ឹង ។ម្យ៉ាងទៀត បានកំចាត់លើកម្មសិទ្ធិគ្រប់បែបយ៉ាងជាភាគច្រើន ។ តែគុណវិបត្តិធំៗគឺនៅតែមានកម្មសិទ្ធិនិយាយស្តីនិយាយលេងដោយគ្មានជំហរចាស់ទុំ គ្មានជំហរទទួលខុសត្រូវចំពោះបក្ស និងចំពោះមាគ៌ារបស់បក្ស ។ នេះជាឥទ្ធិពលដែលជាប់យ៉ាងខ្លាំងនៃវណ្ណៈភាពអនុធនបារាំងដែលមានអត្តចរិតសេរីសំបើមណាស់ទាំងគ្រប់ផ្នែក ។ ឥទ្ធិពលដ៏អាក្រក់នេះ បណ្តាលឲ្យលេចចេញជាអាកប្បកិរិយាមិនសុភាពរាបសា ទាំងក្នុងការនិយាយស្តីរវាងនារីក៏ដូចជានារីរវាងយុទ្ធជន ធ្វើឲ្យមានការខុសឆ្គងមិនសមស្របភ្នែកសមហភាព ព្រោះនៅប្រទេសបារាំងក៏ដូចជានៅប្រទេសចិនមានការទាក់ទងរវាងនារីនិងយុទ្ធជនជាធម្មតា ឯចំពោះផ្ទាល់ខ្លួនដោយសារមិនបានភ្ជាប់នៃអត្តចរិតខ្មែរ ក៏នៅមានការខុសឆ្គងខ្លះៗដែរក្នុងការនិយាយស្តី ។

ឆ្លងតាមការរៀនសូត្រនិងការដកការពិសោធន៍ជាបន្តបន្ទាប់ ក៏បានកែប្រែមួយចំនួនធំ និងបានកំចាត់លើការនិយាយស្តីសេរីនេះបាន៨០% ដូច្នេះនៅសេសសល់២០%ទៀតដែលខ្ញុំជឿជាក់និងដាច់ខាតកំចាត់បានដោយឈរលើមាគ៌ារបស់បក្សដាច់ខាត ។

## II. អំពីឪពុកម្តាយបង្កើត

១) ឪពុកឈ្មោះដើមៈ ជួន ប្រាសឹត ឈ្មោះបដិវត្តៈ សាន ម្តាយឈ្មោះដើមៈ ជួន គ្រីស៊ីយ៉ាន ឈ្មោះបដិវត្តៈ មិនចូលបដិវត្តន៍ទេ ។

២) ឪពុកជនជាតិខ្មែរ ម្តាយជនជាតិបារាំង

៣) ទីកន្លែងៈ ឪពុកនៅ ប-១ ភ្នំពេញ ម្តាយនៅប្រទេសបារាំង ។

ឪពុកកើតថ្ងៃទី៣ ខែ២ ឆ្នាំ១៩៣០ អាយុ៤៨ នៅរស់ ។ ម្តាយកើតនៅប៉ារីសថ្ងៃទី៨ ខែ៥ ឆ្នាំ១៩៣០ អាយុ៤៨ នៅរស់ ។

៤) វណ្ណៈភាពរបស់ឪពុកៈ អនុធនថ្នាក់លើ បញ្ញាជន ។

វណ្ណៈភាពដើមរបស់ម្តាយៈ កម្មករ តែក្រោយដែលមានគ្រួសារក៏ទៅជាវណ្ណៈភាពអនុធន ចំពោះម្តាយក៏មិនសូវបានរៀនអ្វីជាធំដុំទេ ។ តែក្រោយដែលមានគ្រួសារក៏បានរកការងារធ្វើ ហើយនិងរៀនសូត្រតទៅទៀត ដោយមិនត្រូវការសញ្ញាប័ត្រទេ ។ បច្ចុប្បន្នមិនដឹងតើធ្វើការងារអ្វីទេ ។

ចំពោះឪពុកៈ ពេលនៅប្រទេសបារាំងទទួលខុសត្រូវផ្នែកសេដ្ឋកិច្ចខាងអាកាសចរណ៍បារាំង ។ តែមិនសូវច្បាស់ទេ ។ ម្យ៉ាងទៀត តាមការដឹងខ្លះក៏មានការអប់រំប្រមូលកម្លាំងដើម្បីមានគោលជំហរខាងបដិវត្តន៍ ។

៥) ឪពុកចូលបក្សកុម្មុយនិស្តកម្ពុជា ។ ស្រឡាញ់គាំទ្រស្តាប់រស់ដាច់ខាតជាមួយបក្ស ម្តាយគ្មានចូលអង្គការណាទេ ។ នៅប្រទេសបារាំងមិនយល់អ្វីអំពីបដិវត្តន៍កម្ពុជាទេ ។ គាត់ដើរផ្លូវផ្សេងពីផ្លូវបដិវត្តន៍ ។ មានការយល់ខ្លះៗអំពីបដិវត្តន៍ឆ្នាំ១៩២១នៃប្រទេសរុស្ស៊ី ដែលជាបដិវត្តន៍ម្យ៉ាងចំពោះប្រទេសអឺរ៉ុប ។ល ។ ពិសេសមិនយល់អំពីរបបសមូហភាពមិនចាយលុយ ។ល ។

៦) ចំពោះម្តាយមានឥទ្ធិពលទៅលើខ្ញុំមុនចូលបដិវត្តន៍យ៉ាងខ្លាំងដែរ ។ គាត់បានអប់រំខ្ញុំឲ្យទៅជាបារាំងដូចគាត់ តាំងពីសម្លៀកបំពាក់រហូតដល់ការនិយាយស្តីនិងជីវភាពរស់នៅ ។ គាត់អូសទាញខ្ញុំកុំឲ្យដើរផ្លូវបដិវត្តន៍ ហើយដើរផ្លូវនាយទុនវិញដែលជាផ្លូវស្រួលសប្បាយតាមគំនិតរបស់គាត់ ។ គាត់បំពាក់លើកម្មសិទ្ធិឯកជនជាសំភារៈជាសតិអារម្មណ៍ ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏មិនបានបំពាក់ទាំងស្រុងតាមគំនិតរបស់គាត់ទេ ។ ម្យ៉ាងការបំពាក់នេះ មិនមែនឈរលើមាគ៌ាទេ គឺឈរលើមនោសញ្ចេតនាបុគ្គលក្នុងឋានៈជាម្តាយស្រឡាញ់កូន ។ ឥទ្ធិពលពីម្តាយលើខ្ញុំដែលនៅសេសសល់ខ្លាំងជាងគេគឺការនិយាយសេរីមិនទទួលខុសត្រូវ ។

ចំពោះឪពុកវិញ ក្រោយដែលទៅប្រទេសបារាំងក៏មិនសូវបានជាប់ទេ ព្រោះការងារគាត់ច្រើន ។ តែដោយសារគាត់ស្លូតបូត

ជាងម្តាយ ក៏ចំពោះផ្ទាល់ខ្លួនជាសតិអារម្មណ៍ផ្អៀងទៅខាងឪពុកច្រើនជាង ។ ពេលគាត់ទៅប្រទេសចិនក៏បានខិតខំផ្ញើសំបុត្រឃោសនាអប់រំបំផុសឲ្យខ្ញុំចេះភាសាខ្មែរ ឲ្យខ្ញុំយល់អំពីសភាពការណ៍នៅក្នុងប្រទេស ឲ្យខ្ញុំដើរតាមផ្លូវបដិវត្តន៍ ឲ្យខ្ញុំបំពាក់លើគោលជំហរស្នេហាជាតិ ស្នេហាបដិវត្តន៍យ៉ាងរឹងប៉ឹង ។ ដូច្នេះតាំងពីតូចមក ខ្ញុំក៏ស្រឡាញ់ឪពុកជាងម្តាយ តែទោះបីយ៉ាងណាក៏ដោយ មិនសូវចេះមានមនោសញ្ចេតនាដាក់ស្តែងលើឪពុកម្តាយទេ ។ ភាគច្រើនមានការរំភើបក្នុងចិត្តតែមិនលេចចេញទេ ។ បច្ចុប្បន្នគ្មានការជំពាក់ជំពិនលើខ្ញុំទេ ហើយក៏មិនអាចលះបង់ឪពុកម្តាយបានដោយគ្មានស្តាយអ្វីទេ ។

៧) អាចមានឥទ្ធិពលយ៉ាងខ្លាំងលើម្តាយ ដោយសារគាត់ស្រឡាញ់ខ្ញុំខ្លាំងជាងគេ ។ តែមិនសូវដឹងដែរ ។ ឯចំពោះឪពុកវិញ គឺមានការជួយពន្យល់អំពីម្តាយនិងប្អូនដែលនៅប្រទេសបារាំងថា មិនងាយធ្វើបដិវត្តន៍បានទេ ឲ្យគេដើរផ្លូវរបស់គេទៅ ហើយឲ្យលះបង់គេទាំងស្រុង កុំឲ្យនៅមានការគិតគូរស្មុគស្មាញថែមទៀត បណ្តាលឲ្យមានឥទ្ធិពលដល់ការបំពេញភារកិច្ចជាប្រចាំថ្ងៃ ។

III. **អំពីបងប្អូនបង្កើត**

១) មាន៣នាក់ៈ ស្រី២ ប្រុស១

១) ខ្ញុំ

២) ដួន អែវេបូរី ប្រុស អាយុ២១ កើតថ្ងៃទី១៨-៨-៥៧ នៅភ្នំពេញ បច្ចុប្បន្ននៅប្រទេសបារាំងជាមួយម្តាយ ។

៣) ដួន ប៉ាស្កាលគីរ៉ា ស្រី អាយុ១៧ឆ្នាំ កើតថ្ងៃទី ៦-៦-៦១ នៅភ្នំពេញ បច្ចុប្បន្ននៅប្រទេសបារាំងជាមួយម្តាយ ។

២) វណ្ណៈភាពរបស់ប្អូនស្រីទី១គឺអនុធន តែធ្វើសំណង់នៅប្រទេសបារាំង វណ្ណៈភាពរបស់ប្អូនទី២គឺអនុធនសិស្ស ប្រហែលនៅតែរៀនសូត្រ ។

៣) គ្មានការជំពាក់ជំពិនលើខ្ញុំទេ ។ ពេលបែកគ្នា គេនៅតូចមិនសូវយល់អ្វីទេ ហើយបច្ចុប្បន្ននេះក៏មិនគិតគូរដល់គេដែរ ព្រោះដើរផ្លូវខុសគ្នាហើយ ។

៤) គ្មានឥទ្ធិពលលើប្អូនប្រុសទេ គ្រាន់តែស្រឡាញ់ខ្ញុំក្នុងឋានៈជាបងដែលឧស្សាហ៍ជួយគាត់ដោយសារគាត់ជាមនុស្សមិនធម្មតា ។ ឧស្សាហ៍មានមាត់តូចធំដាក់តែមិនវាយ ។ ឯចំពោះប្អូនស្រីឧស្សាហ៍តាមខ្ញុំ ឧស្សាហ៍ស្តាប់ខ្ញុំ ។ តែបច្ចុប្បន្ននេះ គ្មានឥទ្ធិពលអ្វីទេ ហើយម្យ៉ាងក៏ខ្ញុំនៅឆ្ងាយដូច្នេះមិនដឹងទេ ។

IV. **មិត្តជិតស្និទ្ធ**

១) គ្មានមិត្តជិតស្និទ្ធទេក្រៅពីសមហភាព ។

២) ធ្លាប់រួមប្រាស្រ័យក្នុងមជ្ឈដ្ឋានអនុធនបញ្ញាជន ។ ឥទ្ធិពលភាគច្រើនមិនល្អទេ ។ ឧទាហរណ៍ មិនបានកសាងឲ្យមានគោលជំហរស្រឡាញ់ការងារពលកម្មទ្រាំទ្រការលំបាកវេទនា ។ល ។

V. ***សុខភាព លទ្ធភាព***

ក្រៅពីជំងឺក្បាលដោយសារសរសៃឈាមរួញតូច គ្មានបញ្ហាធំដុំទេ ។ អាចបំពេញគ្រប់ភារកិច្ចដែលសមូហភាពប្រគល់ឲ្យជូនបក្សដោយជោគជ័យបំផុត ។

ថ្ងៃទី៥-២-៧៨

នៅភ្នំពេញ ព-៣

(ឯកសារដើមលេខ I 05793)

## ពាក្យស្លោកខ្មែរក្រហម

◆ បន្តវាយកម្ទេចគោលជំហរកម្មសិទ្ធិសួនតួឱ្យអស់រលីងខាងសម្ភារៈ សិទ្ធិអំណាច និងសីលធម៌រស់នៅដាច់ខាត។

◆ កម្ចាត់របៀបរបបដឹកនាំនិងធ្វើការងាររាយមាយ រយីករយាក ប៉ាតណា ប៉ាតណី ប្រថុយប្រថានគ្មានស្មារតីទទួលខុសត្រូវដាច់ខាត។

◆ ប្តេជ្ញាវាយសម្រុកអនុវត្តមាគ៌ាកសិកម្មសម័យឱ្យបានឆាប់រហ័សពី១០ទៅ១៥ឆ្នាំដាច់ខាត។

(ដកស្រង់ពីសៀវភៅទង់បដិវត្តន៍)

◆ យកចិត្តទុកដាក់ការងារនយោបាយសតិអារម្មណ៍ឱ្យល្អនិងស្អាតបរិសុទ្ធជាប់ជានិច្ច ព្រមជាមួយនោះត្រូវយកចិត្តទុកដាក់ការងារចាត់តាំងឱ្យល្អនិងឱ្យស្អាតបរិសុទ្ធជាប់ជានិច្ច។

(ដកស្រង់ពីសៀវភៅកំណត់ហេតុលេខ០ ៧/៦)

# សេចក្តីព្រាងគោលនយោបាយរបស់បក្សចំពោះនារី

## ១) សារសំខាន់របស់នារីក្នុងបដិវត្តន៍

បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យយើងសំដៅកម្ទេចចក្រពត្តិសក្តិភូមិនាយទុនប្រតិកិរិយា កម្ទេចរដ្ឋអំណាចរបស់វា ហើយស្ថាបនារដ្ឋអំណាចប្រជាជនបដិវត្ត ជាក់ស្តែងគឺកសាងរដ្ឋអំណាចកម្មករកសិករក្រោមការដឹកនាំរបស់បក្ស ។

ដើម្បីនឹងសម្រេចបដិវត្តប្រជាជាតិប្រជាធិបតេយ្យកម្ពុជា ត្រូវមានកម្លាំងមនុស្ស កម្លាំងប្រជាជនដ៏កុះករជានារី មានការតស៊ូប្រឆាំងទាំងនយោបាយទាំងអាវុធ ។

នៅក្នុងកម្លាំងមនុស្ស កម្លាំងប្រជាជដ៏កុះករ ក្នុងនេះនារីមានតួនាទីសំខាន់ណាស់ នារីមានចំនួន៥០%នៃប្រជាជនកម្ពុជាទាំងមូល ។ ដូច្នេះនារីមានសារសំខាន់ណាស់ក្នុងការតស៊ូបដិវត្ត ទាំងខាងផ្នែកកម្លាត់ខ្មាំង ទាំងផ្នែកកសាងនៅគ្រប់សមរភូមិនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ យោធា នយោបាយបរទេស សមរភូមិក្រោយនិងសមរភូមិមុខ ។ ដើម្បីយល់ពីសារសំខាន់របស់នារីនៅក្នុងបដិវត្តន៍ឲ្យបានច្បាស់លាស់ចាំបាច់កម្ចាត់ទស្សនៈនិងការលម្អៀងខុសពីរយ៉ាង ដូចតទៅ÷

ក) ការមិនយល់នូវការតស៊ូបដិវត្តន៍ដោយនយោបាយនិងអាវុធដែលធ្វើឡើងពាសពេញ វាយខ្មាំងគ្រប់ទិសទី ភ្ជាប់ជើងខ្មាំងគ្រប់មុខនិងគ្រប់ទីកន្លែង វាយសន្ធឹងនិងបំបែកខ្មាំងឲ្យខ្សោយគ្រប់ពេលវេលា ។ កម្លាំងបដិវត្តន៍ទាំងនេះមាននារីចំនួនជាង៥០% មានតួនាទីសំខាន់ណាស់ក្នុងការតស៊ូអាវុធនិងតស៊ូនយោបាយតាំងពីក្រោយសង្រ្គាមលោកលើកទីពីរមក បានបញ្ជាក់នាទីរបស់នារីនេះយ៉ាងសន្ធឹកច្បាស់ណាស់ ។

ខ) ទស្សនៈមើលងាយឬមើលស្រាលនូវតួនាទីរបស់នារីតាមតែគោលជំហររបស់សក្តិភូមិនាយទុន ដែលយកនារីសម្រាប់គ្រាន់តែធ្វើឧបករណ៍គ្រប់បែបយ៉ាងសម្រាប់បម្រើវណ្ណៈវាតែប៉ុណ្ណោះ ។

## ២) ការងារកៀងគរនារីរបស់បក្ស

ក) ដណ្តើមយកនារីឲ្យបានកុះករសម្រាប់ធ្វើបដិវត្តន៍ឲ្យបានជោគជ័យលើខ្មាំង បក្សចាំបាច់ខកខានមិនបាននូវការធ្វើការងារកៀងគរនារី ។ ការងារកៀងគរនារី“តាមមាគ៌ាវណ្ណៈ” ត្រូវធ្វើ÷



កម្មាភិបាលនារីខ្មែរក្រហម

◆ ទាំងនយោបាយផង

◆ ទាំងខាងចាត់តាំងផង

១) ក្នុងការកៀងគរនារីនេះ លទ្ធភាពមានច្រើនណាស់ គឺលទ្ធភាពទាំងចំនួនច្រើនជាង៥០%នៃប្រជាជនទូទៅ ស្ថិតនៅគ្រប់ច្រកល្ហក គ្រប់សមរភូមិ ស្រែចម្ការ រោងចក្រ សាលារៀន ការដ្ឋាន ក្រសួង ទីផ្សារ គ្រួសារ នៅសមរភូមិខាងមុខ សមរភូមិខាងក្រោយ អាវុធ នយោបាយ ។ល ។

លទ្ធភាពទាំងគុណភាពដែលស្មោះត្រង់ ស្នេហាជាតិ ក្លាហាន ស្នេហាសេរីភាព សមភាព ពលកម្ម ហ្មត់ចត់ ល្អិតល្អន់ ខ្នះខ្នែង សីលធម៌ស្អាតស្អំ មិនទិលខូចដូចបុរស ហើយជាពិសេសនារីនិយាយរួមមិនក្បត់ដូចដែលតែងមាននៅក្នុងភេទបុរសទេ ។

លទ្ធភាពដោយនារីមានប្រវត្តិសាស្ត្រតស៊ូរបស់ខ្លួនយ៉ាងអង់អាចនិងសកម្មក្នុងការតស៊ូអាវុធនិងតស៊ូនយោបាយតាំងពីក្រោយសង្គ្រាមលោកលើកទីពីរមក ។

## ៣) នាទីរបស់នារីក្នុងការកសាងរណសិរ្សឯកភាពជាតិ

ក្នុងការកសាងរណសិរ្សឯកភាពជាតិ ប្រមូលកម្លាំងបដិវត្តន៍វាយឲ្យខ្លាំង នារីមានសារសំខាន់ទាំងគុណភាពទាំងបរិមាណក្នុង÷

◆ សម្ព័ន្ធភាពកម្មករកសិករ

◆ កម្លាំងជំនួយសំខាន់

◆ និងកម្លាំងជំនួយបន្ទាប់បន្សំ

ដូច្នេះ នៅគ្រប់ប្រភេទកម្លាំងនៃរណសិរ្សឯកភាពជាតិ នារីមាននាទីសំខាន់ណាស់ ជាកម្លាំងធំសម្បើមនិងខ្លាំងក្លាណាស់ ។ ហេតុនេះបានជាភារកិច្ចរបស់បក្សទាំងមូលត្រូវតែប្រមូលកម្លាំងនារីឲ្យបានកុះករនៅក្នុងរណសិរ្សឯកភាពជាតិ តាមស្រទាប់និងប្រភេទកម្លាំងនីមួយៗ ជាមូលដ្ឋាននិងជាជំនួយ ។

## ៤) នាទីរបស់នារីក្នុងការកសាងបក្ស

ទន្ទឹមនឹងសារសំខាន់របស់នារីក្នុងការកសាងកម្លាំងរណសិរ្ស នារីមាននាទីសំខាន់ណាស់ក្នុងការកសាងបក្ស ក្នុងជួរបក្សជនធម្មតា ក៏ដូចជាក្នុងជួរកម្មាភិបាលដឹកនាំគ្រប់ថ្នាក់ ។

កាលបើនារីមកបំពេញជួយបក្សកាន់តែច្រើនឡើងៗក្នុងឋានៈជាកងទ័ពស្រួចនៃវណ្ណៈកម្មករនោះ នាទីរបស់នារី អត្តភាពរបស់នារី កាន់តែលេចត្រដែតឡើងគ្រប់ជីវភាពនយោបាយរបស់ប្រទេស ។ នារីក៏ប្រកាន់បាននូវឋានៈជាអ្នកកាច់ចង្កូតនៃនយោបាយប្រទេសពេញលេញ ជាអគ្គបញ្ជាការនៃបដិវត្តន៍ពេញលក្ខណៈ ។

ដូច្នេះ បក្សទាំងមូលមានភារកិច្ចពង្រឹងនិងពង្រីកជួរបក្សដោយប្រភេទនារីឲ្យបានកាន់តែច្រើនឡើងៗជាអតិបរមា ។

## ៥) ភារកិច្ចរបស់បក្សក្នុងការចលនានារី និងក្នុងការកសាងកម្មាភិបាលនារីគ្រប់ប្រភេទ

ក) ភារកិច្ចជាគោលនយោបាយរបស់បក្សត្រូវយកចិត្តទុកដាក់ឲ្យអស់កម្លាំងកាយចិត្តនិងកម្លាំងការងារ ចលនាកៀងគរនារីខាងនយោបាយនិងខាងចាត់តាំង ភារកិច្ចមានទំហំធំណាស់ដែលត្រូវធ្វើដោយស្មារតីទទួលខុសត្រូវខ្ពស់ជាដាច់ខាត ទស្សនៈអ្វី អំពើប្រព្រឹត្តអ្វី អាកប្បកិរិយាអ្វី ដែលមិនបម្រើភារកិច្ច ឬធ្វើឲ្យប៉ះពាល់ ឬធ្វើឲ្យអន្តរាយដល់ចលនាបដិវត្តន៍យ៉ាងធំសម្បើម ។

ខ) ទន្ទឹមនឹងភារកិច្ចចលនានារីនេះ បក្សទាំងមូលមានភារកិច្ចចម្បងមួយ កសាងកម្មាភិបាលនារីគ្រប់ប្រភេទនិងគ្រប់ថ្នាក់ឲ្យបានជាអតិបរមា ។ គោលនយោបាយកសាងកម្មាភិបាលនារីនេះឈរលើ÷

◆ ម្យ៉ាងលើកស្ទួយថែបំប៉នខាងស្មារតី ទាំងខាងនយោបាយទាំងខាងការងារ ទាំងខាងសម្ភារ ដោយយកចិត្តទុកដាក់ជាអនុគ្រោះ ជាបុរស ។

◆ តម្រង់ទិសកសាងកម្មាភិបាលនារីដើរឆ្ពោះទៅមុខកាន់តែក្រហមឡើងៗ ខាងជំហរបដិវត្តន៍រឹងប៉ឹង ខាងសតិអារម្មណ៍នយោបាយ និងខាងចាត់តាំង ។

## ៦) បណ្តាកត្តាសម្រេចជ័យជំនះក្នុងការកិច្ចចលនានិងកសាងកម្មាភិបាលនារី

ដើម្បីធ្វើឲ្យភារកិច្ចចលនានារីនិងកសាងកម្មាភិបាលនារីសម្រេចបានជោគជ័យជាលំដាប់ លុះត្រាតែនារីក្តី បុរសក្តី បក្សទាំងមូលក្តី យល់ច្បាស់និងក្តាប់ឲ្យជាប់នូវបណ្តាកត្តាសំខាន់ៗដូចតទៅនេះ÷

ក) ក្តាប់នាទីដឹកនាំរបស់បក្ស

បក្សជាកត្តាសម្រេចក្នុងចលនានារី និងកសាងកម្មាភិបាលនារី ។ ព្រោះបក្សមានមាគ៌ានយោបាយ មានគោលនយោបាយត្រឹមត្រូវ ហើយជាអង្គការខ្ពស់បំផុត ទទួលខុសត្រូវអំពីបញ្ហានារី ។ ដូច្នេះ នារីដើម្បីរំដោះខ្លួន ដើម្បីពង្រឹងពង្រីកអត្តភាពខ្លួន ហើយដើម្បីឲ្យខ្លួនមានសិទ្ធិគ្រប់បែបយ៉ាង លុះត្រាតែដាក់ទំនុកទុកចិត្តទាំងស្រុងលើបក្សដឹកនាំ ។ គ្រប់បក្សជននិងគ្រប់កម្មាភិបាលបក្ស ក៏ត្រូវជ្រួតជ្រាបនូវគោលនយោបាយនារីរបស់បក្ស ដើម្បីអនុវត្តវាឲ្យបានល្អជាអតិបរមា ។

*ខ) ក្តាប់គោលនយោបាយថែបំប៉ននិងកម្មាជីវូបនីយកម្មរបស់បក្ស*

គោលនយោបាយពីរមុខរបស់បក្សចំពោះនារី ត្រូវក្តាប់ឲ្យជាប់និងអនុវត្តត្រឹមត្រូវនោះ ចលនានារីនិងកសាងកម្មាភិបាលនារីប្រាកដជាផុសផុលដាច់ខាត ។ គឺ÷

◆ ថែបំប៉នលើកស្ទួយខាងស្មារតីនយោបាយនិងសម្ភារតាមលទ្ធភាព ដោយអនុគ្រោះ យល់អធ្យាស្រ័យ និងដោយយកចិត្តទុកដាក់ឲ្យដល់កម្រិត ។

◆ កម្មាជីវូបនីយកម្មនារីដោយគេកសាងក្នុងចលនាគ្រប់បែបយ៉ាង ដោយបក្សហ៊ានប្រគល់ការងារឲ្យ ហើយបក្សណែនាំជួយនារីហ្វឹកហ្វឺនដោយខ្លួនឯង ។

◆ ទន្ទឹមនឹងនេះ បក្សត្រូវយកចិត្តទុកដាក់អប់រំគោលជំហរបដិវត្តន៍ឲ្យនារីជានិច្ចកាល ។

*គ) ក្តាប់នាទីរបស់នារីឲ្យជាប់ក្នុងការរំដោះភេទខ្លួនក្នុងបដិវត្តន៍*

ត្រូវក្តាប់ឲ្យជាប់ថា នារីត្រូវរំដោះខ្លួនពីចក្រពត្តិសក្តិភូមិនាយទុន ពីបិតុនិយម និងពីការមើលងាយមើលថោកពីបុរស និងក្នុងចលនាបដិវត្តន៍រំដោះជាតិ រំដោះប្រជាជន កម្មករកសិករទាំងមូល ។

លុះត្រាតែតាមបដិវត្តន៍និងនៅក្នុងបដិវត្តន៍របស់កម្មករកសិករជាបន្តបន្ទាប់ ទើបនារីរំដោះភេទខ្លួនបាន ទើបសមភាពខាងនយោបាយនិងខាងជីវភាពកើតមានពិតប្រាកដបានជាមួយភេទបុរស ។

ដូច្នោះនារីត្រូវជ្រួតជ្រាបអំពីគោលការណ៍នេះ ទើបខិតខំព្យាយាមខ្នះខ្នែងចូលរួមក្នុងបដិវត្តន៍កាន់តែកុះករ កាន់តែសកម្មឡើងៗ និងកាន់តែដាច់ខាតឡើងៗ ។ រីឯបុរសវិញក៏ត្រូវតែជ្រួតជ្រាបអំពីគោលការណ៍នេះ ទើបខិតខំព្យាយាមខ្នះខ្នែងអនុវត្តគោលនយោបាយនារីរបស់បក្ស ដើម្បីឲ្យគោលបំណងសមភាពរវាងនារីនិងបុរសគ្រប់មុខនយោបាយនិងជីវភាពបានទៅជាការជាក់ស្តែងពិតប្រាកដ ។

*ឃ) កម្ចាត់ទស្សនៈខុសឆ្គងរបស់បុរសនិងរបស់នារីខ្លួនឯងចំពោះស្ត្រីភេទ*

◆ កម្ចាត់ឲ្យអស់នូវទស្សនៈសក្តិភូមិនាយទុន បិតុនិយមមើលងាយមើលថោកនារី ដែលមាននៅក្នុងបុរស ពិសេសក្នុងឋានៈជាអ្នកបដិវត្តន៍ ជាបក្សជន និងជាកម្មាភិបាលរបស់បក្ស ។

◆ កម្ចាត់ឲ្យអស់នូវទស្សនៈមិនឃើញសារសំខាន់របស់នារីនៅក្នុងចលនាបដិវត្តន៍បច្ចុប្បន្ននិងអនាគត ត្រូវបំពាក់ឲ្យរឹងមាំនូវទស្សនៈមហាជនរបស់បក្ស ។ "នារីជាមហាជនជាង៥០%នៃប្រជាជនទូទៅ" ។

◆ កម្ចាត់ឲ្យអស់នូវទស្សនៈគិតតែពឹងផ្អែកលើបុរស ផ្ទុយទៅវិញ ត្រូវមើលឃើញឲ្យច្បាស់ ជឿជាក់ដាច់ខាតលើសារសំខាន់នារីនិងបដិវត្តន៍ សមត្ថភាពរបស់នារីក្នុងគ្រប់សកម្មភាពនៃជីវភាពទាំងអស់ ។

*ង) ក្តាប់នូវភារកិច្ចរបស់បក្សនិងរបស់នារីខ្លួនឯង ក្នុងការចលនានារីនិងកសាងកម្មាភិបាលនារី*

បក្សទាំងមូលមានភារកិច្ចអនុវត្តគោលនយោបាយរបស់បក្ស តែនារីខ្លួនឯងក៏មានសារសំខាន់ក្នុងកិច្ចអនុវត្តគោលនយោបាយនារីរបស់បក្សនេះ ដោយស្មារតីទីពឹងខ្លួនឯងជឿជាក់ខ្លួនឯង ចលនាខ្លួនឯង កសាងនូវកម្មាភិបាលខ្លួនឯង ក្រោមការដឹកនាំយ៉ាងជិតស្និទ្ធរបស់បក្ស ។

## ៧) **សន្និដ្ឋាន**

យើងបានឃើញច្បាស់នូវសារសំខាន់របស់នាទីនារីក្នុងបដិវត្តន៍ហើយ ។ យើងបានឃើញច្បាស់នូវគោលនយោបាយនារីរបស់បក្សហើយ ។ ដូច្នេះ បក្សទាំងមូល បុរសទាំងមូល នារីខ្លួនឯងទាំងមូល ត្រូវខិតខំអនុវត្តគោលនយោបាយនារីរបស់បក្សនេះ ឲ្យបានសម្រេចផលជាអតិបរមា ។

***(កំណត់ហេតុរបស់សមមិត្ត ស ម៉ឺន)***

# ទីតាំងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះ

## ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ (៧៧ទីតាំង)

### រៀបចំនិងចងក្រងដោយៈ ផេង ពង្សរ៉ាស៊ី

| ល.រ | ឈ្មោះ | ទីតាំង |
|---|---|---|
| ១ | វត្តកណ្តាល | ភូមិស្រះឈូកកណ្តាល ឃុំស្រះឈូក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ |
| ២ | វត្តសុភមង្គល | ភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសិរីសូផុន ខេត្តបន្ទាយមានជ័យ ។ |
| ៣ | ល្អាងគិរីរម្យ | ភូមិភ្នំសំពៅលិច ឃុំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ។ |
| ៤ | វត្តសំរោង | ភូមិសំរោង ឃុំសំរោង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ |
| ៥ | វត្តតាលាស់ចាស់ | ភូមិវត្តចាស់ ឃុំតាលាស់ ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។ |
| ៦ | វត្តជ្រៃ | ភូមិជ្រៃ ឃុំជ្រៃ ស្រុកមោងឬស្សី ខេត្តបាត់ដំបង ។ |
| ៧ | វត្តសម្តេចមុនី | ភូមិសម្តេច ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបង ។ |
| ៨ | វត្តគិរីបុប្ផារាម | ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម ។ |
| ៩ | គុកសន្តិសុខបាធាយ | ភូមិបាធាយ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម ។ |
| ១០ | វត្តពព្រែង | ភូមិវាល ឃុំស្ពឺ ស្រុកចំការលើ ខេត្តកំពង់ចាម ។ |
| ១១ | វត្តស្គន់ | ភូមិស្គន់ ឃុំសូទិព ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ |
| ១២ | វត្តភ្នំប្រុស | ភូមិត្រពាំងចារ ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ |
| ១៣ | វត្តស្ទឹងត្រង់ | ភូមិព្រែកបារាំង ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។ |
| ១៤ | គោកព្រីង | ភូមិគោកគ្រាម ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ |
| ១៥ | វត្តអូរត្រកួន | ភូមិអូរត្រកួន ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម ។ |
| ១៦ | វត្តជីហែ | ភូមិផ្សារថ្មី ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ |
| ១៧ | វត្តគោកចាស់ | ភូមិគោក ឃុំគគីរ ស្រុកមេមត់ ខេត្តកំពង់ចាម ។ |
| ១៨ | ព្រៃធុតង្គ | ភូមិលេខ២ ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ។ |
| ១៩ | វត្តជ័យមង្គល | ឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ |
| ២០ | វត្តនគរ | ភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ |
| ២១ | វត្តវិហារទន្ទឹម | ភូមិស្ងួន ឃុំស្ងួន ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ |
| ២២ | វត្តសម្តេចមុនី | ភូមិដក់ពរ ឃុំខុនរ៉ង ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង ។ |
| ២៣ | វត្តខ្សាម | ភូមិខ្សាម ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ |
| ២៤ | វត្តចំប៉ី | ភូមិប្រមុះជ្រូក ឃុំប្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ |
| ២៥ | បន្ទាយចាស់ | ភូមិស្រែតាជ័យ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ |
| ២៦ | វត្តបសេដ្ឋចាស់ | ភូមិក្រុមហ៊ុន ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។ |
| ២៧ | អំពែភ្នំ | ភូមិអំពែភ្នំ ឃុំស្វាយក្រវាន់ ស្រុកច្បាមន ខេត្តកំពង់ស្ពឺ ។ |
| ២៨ | វត្តបារាយណ៍ដាន់ដែក | ភូមិត្រស់ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ |

| | | |
|---|---|---|
| ២៩ | វត្តទួល | ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ |
| ៣០ | វត្តក្ដីដូង | ភូមិក្ដីដូង ឃុំក្ដីដូង(សង្កាត់លេខ៨) ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ។ |
| ៣១ | វត្តប្រាសាទសំបូរ | ភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។ |
| ៣២ | វត្តតាំងក្រសាំង | ភូមិតាំងក្រសាំង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។ |
| ៣៣ | ទួលតាភូង | ភូមិត្រាច ឃុំកំពង់ចិន(ជើង) ស្រុកស្ទោង ខេត្តកំពង់ធំ ។ |
| ៣៤ | មន្ទីរតាម៉ន | ភូមិឫស្សីជុំ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។ |
| ៣៥ | វត្តស្ទឹង | ភូមិស្ទឹង ឃុំឈូក ស្រុកឈូក ខេត្តកំពត ។ |
| ៣៦ | វត្តជុំគ្រៀល | ភូមិត្រពាំងធំ ឃុំជុំគ្រៀល ស្រុកកំពត ខេត្តកំពត ។ |
| ៣៧ | សាលាត្រពាំងស្វា | ភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ |
| ៣៨ | វត្តចំពុះក្អែក | ភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។ |
| ៣៩ | ពោធិ៍ទន្ទេ | ភូមិពោធិ៍ទន្ទេ ឃុំកោះធំ “ក” ស្រុកកោះធំ ខេត្តកណ្ដាល ។ |
| ៤០ | វត្តព្រែកដាច់ | ភូមិព្រែកដាច់ ឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្ដាល ។ |
| ៤១ | វត្តរកាកោង | ភូមិរកាកោង ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្ដាល ។ |
| ៤២ | វត្តស្ពួនពេជ្រ | ភូមិស្ពួនពេជ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្ដាល ។ |
| ៤៣ | ភ្នំខដុង្គ | ភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល ។ |
| ៤៤ | វត្តអង្គរសេរីសួស្ដី | ភូមិសំរោងត្បូង ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្ដាល ។ |
| ៤៥ | បាសិដ្ឋត្រើយត្រឹង្ស | ភូមិឈ្វាំង ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្ដាល ។ |
| ៤៦ | កោះគរ | ភូមិចុងកោះគរ(ជើង) ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល ។ |
| ៤៧ | កោះថ្មី | ភូមិកោះថ្មី ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល ។ |
| ៤៨ | ទួលស្លែង | សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ |
| ៤៩ | ជើងឯក | ភូមិរលួស សង្កាត់ជើងឯក ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។ |
| ៥០ | ភ្នំកំប៉ុក | ភូមិស្វាយសាមសិប ឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង ។ |
| ៥១ | វត្តពាម | ភូមិពាមកោះ ឃុំពាមរ ស្រុកពាមរ ខេត្តព្រៃវែង ។ |
| ៥២ | វត្តស្វា | ភូមិស្វា ឃុំកំពង់ឫស្សី ស្រុកពារាំង ខេត្តព្រៃវែង ។ |
| ៥៣ | វត្តរំលេច | ភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ។ |
| ៥៤ | ឡពិឃាតភ្នំទ្រង់បាត | ភូមិចំបក់ហែ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ |
| ៥៥ | វត្តខ្សាច់ | ភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ |
| ៥៦ | គីឡូម៉ែត្រលេខ៨ | ភូមិគីឡូម៉ែត្រ៨(ភូមិរាជនុកូល) ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។ |
| ៥៧ | បុស្ស | ភូមិបុស្ស ឃុំមេសថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។ |
| ៥៨ | គាណរ៍ | ភូមិគាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។ |
| ៥៩ | វត្តឫស្សីសាញ់ | ភូមិឫស្សីសាញ់ ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។ |
| ៦០ | វត្តកំពង់អំពិល | ភូមិកំពង់អំពិល ឃុំកំពង់អំពិល ស្រុករំដួល ខេត្តស្វាយរៀង ។ |
| ៦១ | ខ្ពបអំពិល | ភូមិកំពង់អំពិល ឃុំកំពង់អំពិល ស្រុករំដួល ខេត្តស្វាយរៀង ។ |
| ៦២ | វត្តបាក្រុង | ភូមិបាក្រុង ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង ។ |
| ៦៣ | វត្តកំពង់ត្រាច | ភូមិតាត្រាវ ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ។ |
| ៦៤ | ធ្លក | ភូមិធ្លក ឃុំធ្លក ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។ |

| | | |
|---|---|---|
| ៦៥ | វត្តស្វាយផ្អែម | ភូមិស្វាយអន្ទ ឃុំស្វាយអន្ទ ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។ |
| ៦៦ | វត្តចាស់ | ភូមិអណ្តូង ឃុំស្វាយអន្ទ ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។ |
| ៦៧ | វត្តបឹងរ៉ៃ | ភូមិវត្តបឹងរ៉ៃ ឃុំស្វាយអន្ទ ស្រុកស្វាយរៀង ខេត្តស្វាយរៀង ។ |
| ៦៨ | វត្តគីរំដួល | ភូមិអកនាគ ឃុំសង្ឃ័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ |
| ៦៩ | វត្តសូរភី ហៅ វត្តកកោះ | ភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ។ |
| ៧០ | វត្តទ្រពាំគរ | ភូមិត្រកៀត ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ ។ |
| ៧១ | វត្តព្រះធាតុសួស្តី | ភូមិក្បាលដំរី ឃុំគោកព្រេច ស្រុកគីរីវង្ស ខេត្តតាកែវ ។ |
| ៧២ | វត្តពោធិ៍មាសអណ្តែត | ភូមិឫស្សី ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ |
| ៧៣ | វត្តស្រះក្រាំងបន្ទាយ | ភូមិពេជឥន្ទ្រា ឃុំបឹងត្រាញ់ជើង ស្រុកសំរោង ខេត្តតាកែវ ។ |
| ៧៤ | ទួលអន្ទ | ភូមិអន្ទក្រូច ឃុំបុរីជលសារ ស្រុកបុរីជលសារ ខេត្តតាកែវ ។ |
| ៧៥ | វត្តក្រាំងតាចាន់ | ភូមិក្រាំងតាចាន់ ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។ |
| ៧៦ | ភ្នំសន្ទុង | ភូមិស្រះត្រកួន ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ ។ |
| ៧៧ | វត្តព្រៃផ្អាវ | ភូមិព្រៃផ្អាវ ឃុំសន្ទុង ស្រុកទ្រាំង ខេត្តតាកែវ ។ |



**បូជនីយដ្ឋានវត្តចំប៉ី**
**នៅភូមិច្រមុះជ្រូក ឃុំជ្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៣១៤ | សរិត ខែម | កូនសិស្ស | ចាក់អង្រែ | ៧-១១-៧៥ | ២០-៥-៧៦ | |
| ៣១៥ | ស៊ឹម ស៊ន | កូនសិស្ស | ព្រែកក្តាម | ១៦-១១-៧៥ | ២០-៥-៧៦ | |
| ៣១៦ | កែ កុសល ហៅ ពក | បុគ្គលិកឃ្លាំងប្រាក់ | តំបន់១៥ | ១-១២-៧៥ | ២០-៥-៧៦ | |
| ៣១៧ | ឌី វ៉ាម៉ា | ក្រសួងមហាផ្ទៃ | អូររាំងឪ | ២៩-១-៧៦ | ២០-៥-៧៦ | |
| ៣១៨ | ឡុង យ៉ាង | ពេទ្យស៊ីវិល | អូររាំងឪ | ២៩-១-៧៦ | ២០-៥-៧៦ | |
| ៣១៩ | រស់ សារ៉េត | សុរិយោដី | មុខកំពូល | ២៩-១-៧៦ | ២០-៥-៧៦ | |
| ៣២០ | កើត វឿន | ពេទ្យ | មុខកំពូល | ២៩-១-៧៦ | ២០-៥-៧៦ | |
| ៣២១ | ស៊ន ទ្រី | ដីដែនទី | តំបន់១៥ | ២៩-១-៧៦ | ២០-៥-៧៦ | |
| ៣២២ | ភិន ចាន់ថន | កសិកម្ម | តំបន់១៥ | ២៩-១-៧៦ | ២០-៥-៧៦ | |
| ៣២៣ | ម៉ៅ សំបូរ | អគ្គការ សេ.អ៊ែ.អែហ្វ | មុខកំពូល | ៣១-១-៧៦ | ២០-៥-៧៦ | |
| ៣២៤ | ឈឹម កុងស៊ិន | ស្មៀនសាធារណការ | តំបន់១៥ | ២៩-១-៧៦ | ២០-៥-៧៦ | |
| ៣២៥ | យុន ហរ ហៅ លឹម | អ្នកបកប្រែ | បាត់ដំបង | ១២-២-៧៦ | ២០-៥-៧៦ | |
| ៣២៦ | ស៊ីវ សាំង | វេជ្ជបណ្ឌិត | ព្រះនេត្រព្រះ | ១៣-២-៧៦ | ២០-៥-៧៦ | |
| ៣២៧ | កុង សៀវប៊ុន | និស្សិត | កំពង់ធំ | ១៣-២-៧៦ | ២០-៥-៧៦ | |
| ៣២៨ | អ៊ឹង ហួយខេង | អគ្គការយ៉ើរ | ព្រះនេត្រព្រះ | ១៤-២-៧៦ | ២០-៥-៧៦ | |
| ៣២៩ | អ៊ឹង តេក ហៅ តឹក | គ្រូបង្រៀន | ព្រែកពោធិ | ១៤-២-៧៦ | ២០-៥-៧៦ | |
| ៣៣០ | ពិនថារាគីម ហៅ ហេងហ៊ងគីម | វេជ្ជបណ្ឌិត | ព្រះនេត្រព្រះ | ១៣-២-៧៦ | ២០-៥-៧៦ | |
| ៣៣១ | ម៉ៅ សំបូរ | ពាណិជ្ជកម្ម | អូររាំងឪ | ១៥-២-៧៦ | ២០-៥-៧៦ | |
| ៣៣២ | ទក កាន | និស្សិតពេទ្យ | ព្រះនេត្រព្រះ | ១៤-២-៧៦ | ២០-៥-៧៦ | |
| ៣៣៣ | រស់ សេរីសំប៊ុន | គ្រូបង្រៀន | មុខកំពូល | ១៥-១-៧៦ | ២០-៥-៧៦ | |
| ៣៣៤ | ចាន់ សុភី ហៅ បូ | និស្សិត | មុខកំពូល | ១៤-១-៧៦ | ២០-៥-៧៦ | |
| ៣៣៥ | ឈន ស្រ៊ូល ហៅ ស្រ៊ន | សាធារណការ | ព្រះនេត្រព្រះ | ១៤-២-៧៦ | ២០-៥-៧៦ | |
| ៣៣៦ | យី ហ៊ី | វិស្វករអណ្តូងរ៉ែ | មុខកំពូល | ១៤-២-៧៦ | ២០-៥-៧៦ | |
| ៣៣៧ | លាវ ហ៊ីសែ | ឃោសនាការ | ភ្នំស្រុក | ១៤-២-៧៦ | ២០-៥-៧៦ | |
| ៣៣៨ | អ៊ូ វិនឌី ហៅ ខូច | ការបរទេស | ល្វាឯម | ១៣-២-៧៦ | ២០-៥-៧៦ | |
| ៣៣៩ | កៅ ហាយ | វិស្វករអណ្តូងរ៉ែ | ព្រះនេត្រព្រះ | ១៣-២-៧៦ | ២០-៥-៧៦ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៤០ | ស្រ៊ុន សាមិ | កសិកម្ម | បាត់ដំបង | ១៦-២-៧៦ | ២០-៥-៧៦ | |
| ៣៤១ | ទា វើងថៃ ហៅ ថៃជា | បើកយន្តហោះ | បាត់ដំបង | ១៣-២-៧៦ | ២០-៥-៧៦ | |
| ៣៤២ | ម៉ៅ ប៊ុនណា | កូនសិស្ស | អូររាំងឪ | ១៣-២-៧៦ | ២០-៥-៧៦ | |
| ៣៤៣ | ស្តុក សុផល | បុរាណវិជ្ជា | ភ្នំស្រុក | ២៩-២-៧៦ | ២០-៥-៧៦ | |
| ៣៤៤ | ឈឹម ធុល | វិស្វករសាធារណការ | ព្រះនេត្រព្រះ | ១៣-២-៧៦ | ២១-៥-៧៦ | |
| ៣៤៥ | ទេស ចិនតេង | ប៉ុស្តិខ្សែលួស | ភ្នំស្រុក | ១៨-២-៧៦ | ២១-៥-៧៦ | |
| ៣៤៦ | លឹម ឡៃ | វិស្វករកសិកម្ម | ព្រះនេត្រព្រះ | ១៩-២-៧៦ | ២១-៥-៧៦ | |
| ៣៤៧ | ថោង សារ៉ាត ហៅ ពៅ | វិស្វករកសិកម្ម | ព្រះនេត្រព្រះ | ១៩-២-៧៦ | ២១-៥-៧៦ | |
| ៣៤៨ | រស់ ឆន | មេព្រៃ | ភ្នំស្រុក | ១៩-២-៧៦ | ២១-៥-៧៦ | |
| ៣៤៩ | ហាក់ ឈុនហ៊ | និស្សិត | ព្រះនេត្រព្រះ | ១៩-២-៧៦ | ២១-៥-៧៦ | |
| ៣៥០ | នួន កប ហៅ គ្រ | ?? | ភ្នំស្រុក | ១៩-២-៧៦ | ២១-៥-៧៦ | |
| ៣៥១ | ហាក់ ខេង | អ្នកថតភាពយន្ត | ភ្នំស្រុក | ១៩-២-៧៦ | ២១-៥-៧៦ | |
| ៣៥២ | ព្រុំ ចោបន | កូនសិស្ស | ព្រះនេត្រព្រះ | ១៩-២-៧៦ | ២១-៥-៧៦ | |
| ៣៥៣ | អ៊ុក សុផាត | កូនសិស្ស | ព្រះនេត្រព្រះ | ១៩-២-៧៦ | ២១-៥-៧៦ | |
| ៣៥៤ | ចាន់ ស៊ីថា | យុទ្ធជន | ពោធិចិនតុង | ២៧-៣-៧៦ | ២១-៥-៧៦ | |
| ៣៥៥ | ណី ណែម | គ្រូបង្រៀន | តំបន់៣៣ | ២២-២-៧៦ | ២១-៥-៧៦ | |
| ៣៥៦ | សុក វ៉ាត | ?? | តំបន់២៥ | ២២-២-៧៦ | ២១-៥-៧៦ | |
| ៣៥៧ | ផេត ប៊ុនលឹម | កម្មករ | អគ្គិសនីចាក់អង្រែ | ២៧-៣-៧៦ | ២២-៥-៧៦ | ឈឺស្លាប់ |
| ៣៥៨ | នួន ហេង | វេជ្ជបណ្ឌិត | ព្រះនេត្រព្រះ | ២១-២-៧៦ | ២២-៥-៧៦ | |
| ៣៥៩ | យក់ សាម៉េត | ក្រឡាបញ្ជី | ភ្នំស្រុក | ១៨-២-៧៦ | ២២-៥-៧៦ | |
| ៣៦០ | ដួង សុខសាន | វិស្វករ | ខ្សាច់កណ្តាល | ២២-២-៧៦ | ២២-៥-៧៦ | |
| ៣៦១ | ឈឹម តេកស្រ៊ាង | វិស្វករអគ្គិសនី | ?? | ២២-២-៧៦ | ២២-៥-៧៦ | |
| ៣៦២ | តាន់ ផេង | វេជ្ជបណ្ឌិត | ព្រះនេត្រព្រះ | ?? | ២៣-៥-៧៦ | |
| ៣៦៣ | សាន សុផល្លី | ហិរញ្ញវត្ថុ | ភ្នំស្រុក | ?? | ២៣-៥-៧៦ | |
| ៣៦៤ | រស់ លាង | វិស្វករសាធារណការ | ព្រះនេត្រព្រះ | ?? | ២៣-៥-៧៦ | |
| ៣៦៥ | ហេង តេង | គ្រូបង្រៀន | ក្រុងបាត់ដំបង | ?? | ២៣-៥-៧៦ | |
| ៣៦៦ | ថាច់ នួន | គ្រូបង្រៀន | ភ្នំស្រុក | ?? | ២៣-៥-៧៦ | |
| ៣៦៧ | គឹម ធី | គ្រូបង្រៀន | ភ្នំស្រុក | ?? | ២៣-៥-៧៦ | |
| ៣៦៨ | ឈឹម សំណាង | តំណាងរាស្ត្រ | ភ្នំស្រុក | ?? | ២៣-៥-៧៦ | |
| ៣៦៩ | ចេង ហួ | វិស្វករ | ព្រះនេត្រព្រះ | ?? | ២៣-៥-៧៦ | |
| ៣៧០ | ឡុង លុន | សាធារណការ | ព្រះនេត្រព្រះ | ?? | ២៣-៥-៧៦ | |
| ៣៧១ | គោ ឈុន | សាស្ត្រាចារ្យ | ភ្នំស្រុក | ?? | ២៣-៥-៧៦ | |
| ៣៧២ | ស៊ូ ណែម | វេជ្ជបណ្ឌិត | បាត់ដំបង | ?? | ២៣-៥-៧៦ **(នៅមានត)** | |

# ការជួបសន្ទនារវាងសមមិត្ត អៀង សារី

## ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងកិច្ចការបរទេស និងគណៈប្រតិភូពាណិជ្ជកម្ម សាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយអនុរដ្ឋមន្ត្រីពាណិជ្ជកម្មក្រៅប្រទេស

***ថ្ងៃទី ២ ខែធ្នូ ឆ្នាំ១៩៧៨ ម៉ោង៥ល្ងាច***

*អមសមមិត្ត អៀង សារី មានសមមិត្ត រិត សេន រុំ សាន អ៊ុន និង លុត ។*

*អមសមមិត្តអនុរដ្ឋមន្ត្រីពាណិជ្ជកម្មក្រៅប្រទេសចិនមានអគ្គរដ្ឋទូត ស៊ុន ហា សមាជិកទាំងអស់នៃគណៈប្រតិភូពាណិជ្ជកម្មចិន ព្រមទាំងបុគ្គលិកមួយចំនួននៃស្ថានទូតចិន ។*

*ស.ម អៀងសារីៈ ក្នុងនាមបក្សកុម្មុយនិស្តកម្ពុជារដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងក្នុងនាមប្រជាជនកម្ពុជា យើងខ្ញុំសូមស្វាគមន៍គណៈប្រតិភូពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិនដែលមានសមមិត្តអនុរដ្ឋមន្ត្រីពាណិជ្ជកម្មក្រៅប្រទេសជាអ្នកដឹកនាំ សូមជូនពរឲ្យសមមិត្តទាំងអស់សុខសប្បាយ និងទទួលជ័យជម្នះក្នុងពេលស្នាក់អាស្រ័យនៅកម្ពុជាយើងខ្ញុំ ។*

*មិត្តចិនៈ សមមិត្ត លី ឈាង រដ្ឋមន្ត្រីពាណិជ្ជកម្មក្រៅប្រទេសយើងបានផ្ដាំផ្ញើមកសួរសុខទុក្ខដល់សមមិត្ត អៀង សារី ។ យើងខ្ញុំមកកម្ពុជាពេលនេះគឺមកធ្វើទស្សនកិច្ចផង មករៀនសូត្រពីមិត្តកម្ពុជាផង នេះជាកិត្តិយសដ៏ធំដល់យើងខ្ញុំទាំងអស់គ្នា ។ បក្សយើងទាំងពីរមានចំណងមិត្តភាពនឹងគ្នាយ៉ាងជ្រាលជ្រៅ ។ យើងខ្ញុំរីករាយណាស់ដោយសង្កេតឃើញបក្សនិងប្រជាជនកម្ពុជាបានទទួលគណៈប្រតិភូបក្សយើងខ្ញុំដែលដឹកនាំដោយសមមិត្ត វ៉ាង កុង សុិញ យ៉ាងរាក់ទាក់កក់ក្ដៅជាទីបំផុតនៅពេលកន្លងទៅថ្មីៗនេះ ។*

*ស.ម អៀងសារីៈ សមមិត្ត វ៉ាង កុង សុិញ បានទុកអនុស្សាវរីយ៍ឲ្យយើងខ្ញុំច្រើនណាស់ ។ សមមិត្តបានពង្រឹងមិត្តភាពជាភាតរៈបដិវត្តន៍និងយុទ្ធសាមគ្គីភាពរវាងបក្សយើងទាំងពីរ ។ យើងទាក់ទងគ្នាដូចបងប្អូន ។ គណៈប្រតិភូពាណិជ្ជកម្មលើកនេះក៏ពង្រឹងពង្រីកយុទ្ធសាមគ្គីភាពបដិវត្តរវាងចិននិងកម្ពុជាមួយកម្រិតទៀត ។ យើងខ្ញុំចង់ឲ្យសមមិត្តអនុរដ្ឋមន្ត្រីស្នាក់នៅកម្ពុជាបានយូរបន្តិច ប៉ុន្តែតាមកម្មវិធី សមមិត្តនៅបានតែមួយអាទិត្យ យើងខ្ញុំក៏យល់អធ្យាស្រ័យដែរ ។*

*មិត្តចិនៈ ខ្លួនខ្ញុំផ្ទាល់នឹងស្នាក់នៅកម្ពុជាតែ១អាទិត្យមែន តែអនុប្រធានគណៈប្រតិភូនិងសមាជិក៦ទៀតនឹងស្នាក់អាស្រ័យនៅយូរទៅទៀត ដើម្បីបន្តធ្វើការងារជាមួយមិត្តកម្ពុជា ។ ខាងវិស័យពាណិជ្ជកម្ម ប្រទេសយើងទាំងពីរក៏មានការទាក់ទងគ្នាជិតស្និទ្ធដែរ ។ យើងខ្ញុំមកនេះក៏ដើម្បីពិភាក្សាអំពីពាណិជ្ជកម្មឆ្នាំ ១៩៧៩ ហើយបើមិត្តកម្ពុជាត្រូវការអ្វី ស្នើធ្វើបញ្ជីឲ្យបានត្រឹមត្រូវមក យើងខ្ញុំនឹងបំពេញសំណូមពរមិត្តកម្ពុជាតាមសេចក្ដីត្រូវការរបស់មិត្តនិងតាមលទ្ធភាពរបស់យើងខ្ញុំ ។ ចំពោះការងារកន្លងមក ត្រង់ណាយើងខ្ញុំខ្វះខាត ក៏សូមមិត្តកម្ពុជាបញ្ចេញមតិដែរ ដូចជាលើបញ្ហាគុណភាពទំនិញ ពេលវេលាប្រគល់ទំនិញ ជាដើម ។ យើងខ្ញុំយល់ការលំបាករបស់មិត្តកម្ពុជាដែលកំពុងប្រឆាំងការឈ្លានពានរបស់យួន ហើយយើងខ្ញុំរីករាយចំពោះជ័យជម្នះរបស់មិត្តកម្ពុជានៅរណសិរ្សខាងមុខលើខ្មាំងយួនឈ្លានពាន ។*

*ស.ម អៀង សារីៈ យើងខ្ញុំជឿជាក់ថាការចរចាខាងពាណិជ្ជកម្មពេលនេះគ្មានអ្វីស្មុគស្មាញទេ ដោយបក្សទាំងពីរយើងឈរលើមិត្តភាព ។ យើងខ្ញុំទុកចិត្តលើមិត្តចិន ហើយមានតែមិត្តចិនទេដែលយោគយល់យើងខ្ញុំក្នុងសភាពការណ៍សព្វថ្ងៃ ។ ការពិភាក្សាលើកនេះក៏ជាបទពិសោធន៍យើងខ្ញុំសម្រាប់ឆ្នាំក្រោយទៀត ។*

*កន្លងមកយើងខ្ញុំបានមានឱកាសជួបសន្ទនាជាមួយសមមិត្តឧបនាយករដ្ឋមន្ត្រី លី សៀន នៀន នៃប្រទេសចិន ហើយបានលើកពីការខ្វះខាតរបស់យើងខ្ញុំជម្រាបសមមិត្តក្នុងការអនុវត្តកិច្ច*

សន្ធិសញ្ញាដោះដូរពាណិជ្ជកម្មផ្សេងៗជាមួយមិត្តចិន ។ មូលហេតុគឺឆ្នាំនេះយើងខ្ញុំបានជួបប្រទះទឹកជំនន់ដែលមិនធ្លាប់មានជាង៧០ឆ្នាំមកហើយ ដល់ទៅពីរលើកដួនៗ ។

*មិត្តចិនៈ* ប្រទេសកម្ពុជាកំពុងទប់ទល់ការឈ្លានពានពីខ្មាំងយួន ហើយក៏មានទឹកជំនន់ទៀត បើមានការប្រែប្រួលក្នុងការអនុវត្តកិច្ចសន្ធិសញ្ញាដោះដូរ វាជាការធម្មតាទេក្នុងសភាពការណ៍បែបនេះ ។

*ស.ម អៀង សារីៈ* ចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសយើងទាំងពីរ បើមិត្តចិនយល់ថាចំណេញខាងនយោបាយ យើងខ្ញុំក៏មិនយល់ទាស់អ្វីដែរ ។ ពីមុនយើងខ្ញុំបារម្ភក្រែងយើងខ្ញុំអនុវត្តកិច្ចព្រមព្រៀងនោះមិនបាន ។ ខាងស្ថិតិយើងខ្ញុំមិនទាន់ច្បាស់លាស់ទេ យើងត្រូវកសាងមួយរយៈទៀតចំពោះតួលេខផ្សេងៗ ។ ពីឆ្នាំ១៩៧៥ យើងខ្ញុំមិនបានប៉ាន់ប្រមាណថាសង្គ្រាមជាមួយយួនមានទំហំដូចសព្វថ្ងៃនេះទេ ហើយយើងបានប៉ាន់ថាទៅដល់ឆ្នាំ១៩៨០ យើងនឹងមានតួលេខច្បាស់លាស់ហើយ ។ តែឥឡូវនេះ ដោយសង្គ្រាមឈ្លានពានរបស់យួន យើងខ្ញុំមិនច្បាស់ជាយ៉ាងណាទេក្នុងបញ្ហានេះ ។ ក្នុងរយៈពេលបីឆ្នាំកន្លងទៅនេះ យើងខ្ញុំមានពិសោធន៍ក្នុងការគ្រប់គ្រងរក្សារដ្ឋអំណាចបដិវត្ត សព្វថ្ងៃយើងខ្ញុំម្ចាស់ការទាំងសមរភូមិមុខទាំងសមរភូមិក្រោយ ។ តែយួននៅតែ...

...ពិភាក្សាអំពីការទិញដូរជាក់ស្តែង ។ កិច្ចព្រមព្រៀងធ្វើឲ្យបរទេសយល់ថាយើងជិតស្និទ្ធគ្នា ប៉ុន្តែផ្ទៃក្នុងយើង យើងជិតស្និទ្ធគ្នាទៅហើយ ។

*ស.ម អៀង សារីៈ* យើងខ្ញុំយល់ថាការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មជាបញ្ហានយោបាយ ហើយក៏ជាបញ្ហាបច្ចេកទេសខ្លះដែរ ។ ដូចជាការជំពាក់ប្រាក់ជាដើម ជំពាក់ក្រុមហ៊ុនផលិតសម្ភារៈមិនកើតទេ បើជំពាក់ធនាគារជំពាក់បាន ។ ដូចនេះយើងខ្ញុំក៏យល់ស្របឲ្យមានកិច្ចព្រមព្រៀងពាណិជ្ជកម្មដែរ ។ ការណ៍នេះធ្វើឲ្យយើងកាន់តែយល់គ្នាឡើង ហើយយើងខ្ញុំកាន់តែយល់បញ្ហាពាណិជ្ជកម្មច្រើនឡើងដែរ ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មនេះនាំឲ្យចំណេញចំពោះមតិសាកលលោកដែរ ប៉ុន្តែដល់អនុវត្តយើងខ្ញុំមុខជាខុះខាតហើយ ដោយមកពីសង្គ្រាម ។

*មិត្តចិនៈ* បើមិត្តកម្ពុជាមិនយល់ទាស់ទេ យើងខ្ញុំអាចជូនគម្រោងកិច្ចព្រមព្រៀងមួយ ហើយភាគីយើងទាំងពីរនឹងពិភាក្សាគ្នាលើគម្រោងនោះ តែនៅពេលនេះធ្វើបានឬមិនបានក៏មិនអ្វីដែរ ។ យើងខ្ញុំសូមបញ្ជាក់ថា កិច្ចព្រមព្រៀងគ្រាន់តែជាគោលការណ៍ប៉ុណ្ណោះ គ្មានលេខចំនួនទេ ។ ការអនុវត្ត យើងធ្វើទៅតាមការជាក់ស្តែងជាការផ្ទៃក្នុងរបស់យើង ។

*ស.ម អៀង សារីៈ* យើងខ្ញុំយល់ថាយើងអាចធ្វើកិច្ចព្រមព្រៀងបាននៅពេលនេះ ព្រោះជាគោលការណ៍យើងយោគយល់គ្នាទៅហើយ ។ យើងខ្ញុំគិតថា សមមិត្តអនុមន្ត្រីនឹងធ្វើការពីរថ្ងៃ គឺថ្ងៃទី៣និងទី៤ ហើយអញ្ជើញទៅធ្វើទស្សនកិច្ចនៅអន្តរវត្តនៅថ្ងៃទី៥, ៦ និង ៧ ។ នៅឱកាសពិភាក្សា យើងនឹងលើកតែគោលការណ៍រួម ឯការងារជាក់ស្តែងលម្អិតទុកឲ្យសមមិត្តឯទៀតក្នុងគណៈប្រតិភូបន្តការពិភាក្សាចុះ ។

*មិត្តចិនៈ* សូមថ្លែងអំណរគុណចំពោះសមមិត្ត អៀង សារី ដែលបានលៃពេលដ៏មានតម្លៃរបស់សមមិត្តជួបយើងខ្ញុំ និងចំពោះស្វាគមន៍ករុណារបស់ស.ម ។ យើងខ្ញុំជឿជាក់ថា ការពិភាក្សាជាមួយសមមិត្ត វ៉ាន់ រិត ក៏នឹងប្រព្រឹត្តទៅដ៏ល្អប្រពៃដែរ ហើយនឹងសម្រេចភារកិច្ចដ៏ល្អដែលសមមិត្ត លី ឈាង បានផ្តាំផ្ញើដល់យើងខ្ញុំ ។

ការជួបសន្ទនាបានប្រព្រឹត្តទៅក្នុងបរិយាកាសស្និទ្ធស្នាលពោរពេញទៅដោយមនោសញ្ចេតនាជាភាតរភាពបដិវត្ត និងយុទ្ធសាមគ្គីភាពយ៉ាងជ្រាលជ្រៅ ហើយបានបញ្ចប់នៅម៉ោង ៥ និង៥០ នាទីល្ងាច ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២ ធ្នូ ១៩៧៨

## ថ្ងៃទី៣ ធ្នូ ១៩៧៨ ម៉ោង ៣ រសៀល

សមាសភាពគណៈប្រតិភូទាំងសងខាងដូចពេលព្រឹក

មុននឹងបន្តការចរចា ភាគីទាំងពីរបានសំណេះសំណាលគ្នាពីបញ្ហាពាណិជ្ជកម្មកម្ពុជា-ចិន ពីព្រឹត្តការណ៍សកលលោកមួយចំនួនដែលជាអំណោយផលដល់បដិវត្តន៍និងការកសាងសង្គមនិយមនៅកម្ពុជានិងនៅប្រទេសចិននិងជាបរាជ័យខាងនយោបាយទូតលើឆាកអន្តរជាតិរបស់ពួកវាតទីនិយមសូវៀត និងរំពៃបម្រើរបស់វាគឺយួនឈ្លានពានលេបទឹកដី ។ **(តទៅទំព័រ៤៦)**


ថតដោយៈ ចូសេហ្វ កុហ្វម៉ាន់



# ការសន្ទនារបស់សមមិត្ត អៀង សារី នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦

(តចប់)

អៀង សារី បន្តថា «យើងខ្ញុំយល់ឃើញថា អ្នកប្រចាំការសម្រេចបានត្រឹមតែក្របខ័ណ្ឌខ្លួន ។ ដូច្នេះត្រូវការពេលវេលាពិចារណាថែមទៀត ។ ការដែលសមមិត្តយល់ថាត្រូវពន្យារពេលហើយបានទូរលេខពីស្រុកថែមទៀតឃើញថាយើងឯកភាពគ្នាទាំងស្រុង ។ ពិតមែនតែសមមិត្ត នាយ សារ៉ាន់ សេង ហុង និងសែ ពុំបាននៅ តែក្រសួងការបរទេសនៅទីនេះជំនួសគណៈប្រតិភូសូមសម្តែងអំណរគុណចំពោះសមមិត្តដែលបានខិតខំប្រឹងប្រែងធ្វើការដើម្បីពង្រឹងសាមគ្គីភាពមិត្តភាពរវាងបក្សយើងទាំងពីរប្រជាជនយើងទាំងពីរ ។ ឯការងារជាក់ស្តែងទៅថ្ងៃក្រោយយើងនឹងទាក់ទងតាមទូរលេខទៅវិញទៅមក ។ ថ្ងៃណា ខែណា នៅឯណា យើងនឹងជម្រាប ។ ពិតមែនតែទូរលេខអាចបែកការណ៍សម្ងាត់ខ្លះ តែយើងមានអក្សរសម្ងាត់ជាការធានាដែរ» ។

អំពីបណ្តាំរបស់សមមិត្ត ទ្រិញ ដែលសមមិត្ត ផាន ហៀង បានខទេ្ទសនាមជាដំបូងបង្អស់ អៀង សារី បានសម្តែងអំណរគុណ ហើយតាមរយៈសមមិត្ត ផាន ហៀន អៀង សារី ក៏បានផ្តាំសួរសុខទុក្ខទៅសមមិត្តទ្រិញ សមមិត្ត ឡេ ឌឹកថ ប្រកបដោយមនោសញ្ចេតនាបដិវត្តនិងជូនពរសុខភាពបរិបូរណ៍និងជ័យជម្នះដ៏ថ្ងៃថ្លាខត្តុង្គខត្តមក្នុងរយៈកាលបដិវត្តថ្មីនិងរយៈកាលប្រវត្តិសាស្ត្របង្រួបបង្រួមប្រទេសវៀតណាម ។

ប៉ុន្តែ អៀង សារី មានចម្លល់ថា «សមមិត្ត ង្វៀង ធ្វៀង បានជួបសមមិត្តលេខាឬយ៉ាងណា ។ សមមិត្តលេខាបានទូរលេខឲ្យខ្ញុំផ្តាំផ្ញើការសួរសុខទុក្ខរបស់គាត់ចំពោះសមមិត្ត ឡេ យន់, ត្រឿង ជិញ, ផាំ វ៉ាន់ដុង និង វ៉ី ង្វៀងយ៉ាប់ ហើយសូមជូនពរសុខភាពបរិបូរណ៍និងជ័យជម្នះ» ។

អំពីសេក្តីរាយការណ៍ស្តីអំពីការបោះឆ្នោតនៅវៀតណាម អៀង សារី បានសន្យាថានឹងរាយការណ៍ជូនគណៈអចិន្ត្រៃយ៍ ហើយបញ្ជាក់ថា «ដូចសមមិត្តលេខាមានប្រសាសន៍ ក្រោយពីសង្គ្រាមលោកលើកទី២ មានប្រទេសមួយចំនួនបែកជាពីរ ដូចជាអាល្លឺម៉ង់ កូរ៉េ តែពុំទាន់បានរួបរួម ។ មានតែវៀតណាមទេបានរួបរួមជាប្រវត្តិ ។ នេះដោយសារការតស៊ូអង់អាចក្លាហានរបស់ប្រជាជនវៀតណាមក្រោមការដឹកនាំរបស់បក្សពលករវៀតណាមនិងប្រធាន ហូ ជីមិញ» ។

អៀង សារី បានចាត់ទុកជ័យជម្នះរបស់ប្រជាជនវៀតណាមរបស់បក្សពលករវៀតណាមថាជាជ័យជម្នះដែលយើងរីករាយបំផុតក្នុងឋានៈជាយុទ្ធមិត្តដ៏ជិតស្និទ្ធបំផុត ។ ដូច្នេះខ្មាំងចង់បង្កហេតុ ហើយមានឧបាយកលយ៉ាងណាក៏ដោយ តែដោយស្មារតីរបស់បក្សពលករវៀតណាម ក៏កម្ទាត់ឧបាយកលខ្មាំងបានទាំងអស់ ។ ចំពោះវៀតណាម អៀង សារី មានជំនឿជាក់ថា ទៅអនាគត ក្នុងដំណើរការរបស់ខ្លួន ប្រជាជនវៀតណាមនឹងដណ្តើមបានជ័យជម្នះថ្មីថែមទៀត ។

អំពីសំណូមពររបស់សមមិត្ត ទ្រិញ ដែលចង់ឲ្យមានកិច្ចសហប្រតិបត្តិការរវាងក្រសួងការបរទេសទាំងពីរនៅលើឆាកអន្តរជាតិ ។ អៀង សារី យល់ថា សហប្រតិបត្តការនេះតាមលក្ខណៈប្រទេសនីមួយៗ ធ្វើយ៉ាងណាឲ្យបានជិតស្និទ្ធ ។ ដូច្នេះការផ្លាស់ប្តូរមតិគ្នាជាបន្តបន្ទាប់តាមការចាំបាច់ ។

អំពីសន្និសីទកូឡុំបូ អៀង សារី សន្យានឹងរាយការណ៍ជូនគណៈអចិន្ត្រៃយ៍ដោយជម្រាបថា «យើងខ្ញុំមិនសូវមានឯកសារច្បាស់លាស់ទេ ។ កាលនៅលីម៉ា យើងខ្ញុំគិតគូរតែបញ្ហាកម្ពុជា ។ ឯបញ្ហាធំៗលើសកលលោក យើងកំពុងតែប្រមូលឯកសារថែមទៀត ។ ដូច្នេះការផ្តាំផ្ញើរបស់សមមិត្ត ទ្រិញ នាំឲ្យយើងខ្ញុំឃើញបញ្ហាថ្មីថែមទៀត ។ និយាយរួម ចក្រពត្តិអាមេរិកមិនទាន់ប្រែធាតុអ្វីទេ ។ វានៅជាចក្រពត្តិ វារកគ្រប់វិធីនិងមធ្យោបាយកម្ទេចបដិវត្ត ។ នេះយើងខ្ញុំគ្មានស្រពិចស្រពិលទេ ។ ដូច្នេះ

ទស្សនៈគោលជំហររបស់សមមិត្តវៀតណាមដែលថាត្រូវប្រមូលកម្លាំងប្រឆាំងនឹងចក្រពត្តទាំងចាស់ទាំងថ្មី យើងខ្ញុំឯកភាពទាំងស្រុង ហើយគាំទ្រចលនាឯករាជ្យនិងរំដោះជាតិ» ។

អំពីបញ្ហាដែលជាប់នឹងប្រទេសកម្ពុជា អៀង សារី បានសន្យាថានឹងត្រិះរិះពិចារណាថែមទៀតអំពីមូលនិធិជួយកម្ពុជា វៀតណាម និងលាវ ហើយ អៀង សារី យល់ឃើញថា «ធ្វើយ៉ាងណាឲ្យពង្រឹងសាមគ្គីភាពក្នុងចលនាមិនចូលបក្សសម្ព័ន្ធជាសំខាន់ ។ នៅក្នុងចំណោមប្រទេសមិនចូលបក្សសម្ព័ន្ធមានប្រទេសច្រើននៅក្រ ហើយមួយចំនួននៅមានសង្គ្រាម ជាពិសេសនៅអាហ្វ្រិក ។ ដូច្នេះបើគិតជារួមល្អជាង ។ ធ្វើយ៉ាងណាកុំឲ្យគេច្រណែនថា គិតគូរតែបីប្រទេសយើង ។ យើងខ្ញុំនឹងត្រិះរិះពិចារណាតាមឯកសារ មើលបច្ច័យល្អអាក្រក់យ៉ាងណា» ។

អំពីអាស៊ានវិញ អៀង សារី យល់ថា «ប្រទេសទាំងនេះជាប្រទេសនាយទុន ហើយជារណបចក្រពត្តិ ។ ដូច្នេះពុំមែនជាមិត្តយើងទេ ។ យើងក៏យល់ស្របនឹងសមមិត្តវៀតណាមថាមានសារសំខាន់នៅអាស៊ី-អាគ្នេយ៍ ។ អង្គការអាស៊ានមិនមែនជាអង្គការបម្រើនទេ ។ វាមិនមែនជួយបដិវត្តទេ វាប្រឆាំងនឹងបដិវត្តន៍ដាច់ខាត ។ រូបភាពវានៅឆ្នាំ១៩៦៧ ឆ្នាំ១៩៧០ និងឆ្នាំ១៩៧២ ខុសគ្នានឹងបច្ចុប្បន្ននេះ ។ ឯសកម្មភាពវាក៏ខុសគ្នាដែរ ។ ដោយបដិវត្តន៍យើងឈ្នះក្នុងប្រទេសទាំងបីរូបភាពវាក៏ផ្លាស់ប្តូរ ។ ដូច្នេះយើងខ្ញុំយល់ថាវាពុំមែនជាមិត្ត ។ ប៉ុន្តែយើងខ្ញុំយល់ថា ការទាក់ទងខ្លះជាគូភាគីគឺដូចជាសមមិត្តវៀតណាមថាជាការរួមរស់ដោយសន្តិភាព» ។

អៀង សារី យល់ឃើញទៀតថា «នេះគ្រាន់តែជាការជំរុញបដិវត្ត ពីព្រោះបើរួមរស់ហើយបោះបង់ចោលបដិវត្តក៏មិនបានដែរ ។ យើងទាក់ទង តែយើងរក្សាគោលជំហររបស់យើង ។ សមមិត្ត ផាន ហៀន បានទៅបាងកក ហើយបានស្គាល់ឆាតឆៃ ឈុនហាវ៉ាន ដូចគ្នា ។ ក្រោយពីបានជួបគ្នានៅប៉ោយប៉ែត គេបានសុំជួបយើងខ្ញុំ៧ដង ។ តែដោយឃើញថាគ្មានប្រយោជន៍អី យើងខ្ញុំពុំបានជួបទេ ។ ឥឡូវ ពិច័យ រត្តាគលបានសុំជួបយើងខ្ញុំពីរដងហើយ ។ ប៉ុន្តែជួបក៏មិនបានការអ្វីមិនជួបក៏មិនជាការអ្វី ។ ដូច្នេះចំពោះរដ្ឋាភិបាលថៃ យើងខ្ញុំកំពុងពិនិត្យដូចបានជម្រាបសមមិត្ត ហាយសូ ។ យើងខ្ញុំក៏បានជម្រាបសមមិត្តលាវដែរ ។ យើងខ្ញុំធ្វើយ៉ាងដូចម្តេចដើម្បីកុំឲ្យខ្មាំងវាឯកោយើងខ្ញុំបានលើឆាកអន្តរជាតិ ។ ឯការដែលយើងខ្ញុំប្រកាសដាក់ការទាក់ទងជាមួយម៉ាឡេស៊ីនិងហ្វីលីពីន គឺគ្រាន់តែប្រកាសមិនទាន់ដឹងពេលណាដាក់ទូតទេ» ។

អៀង សារី បានបញ្ជាក់ថា «ទស្សនៈនិងគោលជំហរប្រទេសយើងទាំងពីរនៅលើឆាកអន្តរជាតិប្រហាក់ប្រហែលគ្នាគ្មានអ្វីខ្វែងគ្នាទេ» ។

អំពីបញ្ហាជាក់ស្តែង អៀង សារី បានលើកឡើងថា «ដោយប្រទេសយើងទាំងពីរនៅជិតគ្នា សមមិត្ត ហាយសូ និងបងតាំ ក៏បានលើកស្នើឲ្យមានកាសែតនិងអ្នកថតកុនមកកម្ពុជា ។ យើងខ្ញុំក៏បានគិត ។ ក្នុងនាមនៃក្រសួងការបរទេស យើងខ្ញុំសូមអញ្ជើញអ្នកកាសែតនិងអ្នកថតរូបទាំងខាងជើងទាំងខាងត្បូងពី៣-៥នាក់ក្នុងរយៈពី១អាទិត្យទៅ១០ថ្ងៃ ។ អំពីពេលវេលាស្រេចតែសមមិត្តកំណត់ ។ ខែមិថុនាក៏បាន ពិតមែនតែខែនេះមានភ្លៀងបន្តិច» ។

អំពីបញ្ហាអាកាសចរណ៍ អៀង សារី ក៏បានពិចារណាថាជាគោលការណ៍យើងខ្ញុំមិនយល់ទាស់ ។ ប៉ុន្តែខាងបច្ចេកទេសយើងខ្ញុំត្រូវរៀបចំឲ្យបានល្អបន្តិច ។ ដូច្នេះក្នុងខែកក្កដា បើមានគណៈប្រតិភូអាកាសចរណ៍វៀតណាមមកក៏បាន ។ យើងធ្វើយ៉ាងណាឲ្យចំណោញដល់សាមគ្គីភាពមិត្តភាពរវាងប្រទេសទាំងពីរ ។ អំពីបញ្ហានេះ យើងខ្ញុំបានគិតយូរ ប៉ុន្តែមានការលំបាកខាងបច្ចេកទេសដែលយើងខ្ញុំមិនទាន់កសាងបាន ។ ដូច្នេះដល់ពេលវេលាជជែកគ្នា សូមសមមិត្តអាធ្យាស្រ័យខាងបច្ចេកទេសផង ។

សមមិត្ត ផាន ហៀន បានថ្លែងអំណរគុណចំពោះ អៀង សារី ហើយបានសន្យាថានឹងយកមតិនេះទៅរាយការណ៍ជូនសមមិត្ត ទ្រិញ និងការិយាល័យនយោបាយ ។

ការសន្ទនាត្រូវបានភាគីទាំងពីរចាត់ទុកថាជាជំហានទីមួយ ហើយទទួលបានលទ្ធផលដ៏ប្រសើរនិងសមស្របតាមបំណងបក្សរបស់ទាំងពីរ ។ ការពិភាក្សានឹងបន្តទៀតនៅក្នុងជំនួបលើកក្រោយ ។

**ឌុង សុភារិទ្ធ**

# នួន ជា បដិសេធថាមិនបានសម្លាប់មនុស្ស

នួន ជា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលជារបបមួយ ល្បីល្បាញក្នុងការធ្វើឲ្យប្រជាជនអស់រាប់លាននាក់ស្លាប់បាត់បង់ជីវិត។ សព្វថ្ងៃនេះ នួន ជា មានអាយុ៧៧ឆ្នាំទៅហើយ ។ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ នួន ជា បាននិយាយថា "ខ្ញុំមានការសោកស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតរបស់ប្រជាជនដោយអចេតនា ដែលបក្សយើងខ្ញុំជាអ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យគ្មានគោលបំណង គ្មានចេតនាទៅសម្លាប់ប្រជាជនឯងទេ" ។ ជាមួយនឹងការទទួលស្គាល់នេះ នួន ជា ក៏បានបដិសេធចំពោះការចោទប្រកាន់ពីរឿងសម្លាប់មនុស្សថា "ការចោទប្រកាន់នេះខ្ញុំទទួលមិនបានទេ ប៉ុន្តែការស្លាប់របស់ប្រជាជនបណ្តាលមកពីភាពអត់ឃ្លាននិងជំងឺតម្កាត់ប៉ុណ្ណោះ" ។ ការបដិសេធរបស់ នួន ជា មានភាពផ្ទុយស្រឡះនឹងឯកសារចម្លើយសារភាពមួយចំនួនដែលមានចំណារថ្នាក់ក្រោមផ្ញើមកថ្នាក់លើ រួមមាន នួន ជា ផង ឲ្យទទួលដឹងពុ ឬបញ្ជាឲ្យសម្រេចកិច្ចការផ្សេងៗ ។

◆ ខែក ពិន ហៅ ស៊ូ មានតួនាទីជាគណៈតំបន់៤ ត្រូវបានក្រសួងសន្តិបាលចាប់ខ្លួនមកមន្ទីរស-២១ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ ។ ចម្លើយសារភាពរបស់ ស៊ូ ចម្លងចេញពីខ្សែអាត់ស្តីអំពីសកម្មភាពក្បត់បក្សនិងឈ្មោះអ្នកចូលរួមសកម្មភាពក្បត់ចំនួន៧៥នាក់ ។ ឈ្មោះមួយចំនួនដែលជាប់ពាក់ព័ន្ធ ត្រូវបានចារថា "ចាប់ហើយ" ។ នៅលើចម្លើយសារភាពរបស់ ខែក ពិន មានចំណារបញ្ជាក់ថា "នួន ជា បានទទួលឯកសារនេះមួយច្បាប់ហើយ" ។ ខ្ញុំបានរកឃើញឈ្មោះ ខែក ពិន ហៅ ស៊ូ នៅក្នុងបញ្ជី



ប៉ុល ពត និង នួន ជា ក្នុងដំណាក់កាលតស៊ូក្នុងព្រៃម៉ាគី

កម្ទេចនៅថ្ងៃទី១៨ ខែ១០ (ខែតុលា) ឆ្នាំ១៩៧៧ នេះបញ្ជាក់ថា បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេលជិត៤ខែ និងត្រូវលើ្បចយកចម្លើយរួចហើយ ខែក ពិន ក៏ត្រូវអង្គការយកទៅកម្ទេចចោល ។

◆ ញឹម ស៊ឹម ហៅ សួត ជាសមាជិកវរសេនាតូច៧០១ វរសេនាធំ៦០១ (កងពលភូមិភាគកណ្តាល) ត្រូវចាប់ខ្លួននៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៧ និងសួរចម្លើយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៧ ។ បន្ទាប់ពីបានសួរចម្លើយចប់ អត្ថបទចម្លើយសារភាពរបស់អ្នកទោសរូបនេះត្រូវបានផ្ញើមក “ភូមិភាគកណ្តាល ជូនបងនួនមួយច្បាប់ ថ្ងៃទី១១-១១-៧៧” ។

◆ សៀង ផុន ហៅ ផា ស្រុកកំណើតនៅភូមិខ្សាច់ទប់ ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ តំបន់៤២ ភូមិភាគកណ្តាល តួនាទីជាជំនួយការវរសេនាតូច៧០១ វរសេនាធំ៦០១ កងពល១៧៤ ភូមិភាគកណ្តាល ។ តាមចម្លើយសារភាពបាននិយាយថា សៀង ផុន ត្រូវបានចាប់ខ្លួនពីបទរួមគំនិតលួចដុតឃ្លាំងគ្រាប់និងលបកម្ទេចបងពក (កែពក) ។ ផា ត្រូវចាប់ខ្លួននៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៧ ។ ចម្លើយសារភាពរបស់ ផា ក៏ត្រូវបានផ្ញើមក “សមមិត្តនួនមួយច្បាប់ សម្រាប់ភូមិភាគកណ្តាល ថ្ងៃ១១-១១-៧៧” ។ នៅក្នុងអត្ថបទនោះមានបញ្ជីឈ្មោះកម្លាំងក្បត់៣៨នាក់ ។ ២៦នាក់មានសរសេរក្នុងរង្វង់ក្រចកថា “ចាប់” និងម្នាក់ “កម្ទេចចោល” ។ ចំណែក ផា ត្រូវអង្គការកម្ទេចនៅថ្ងៃ៩-១២-៧៧ ។

◆ អាន កន ហៅ កុល បញ្ជាការវរសេនាតូច៧០២ វរសេនាធំ៦០១ ត្រូវអង្គការចាប់នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៧ និងសួរចម្លើយនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ បន្ទាប់ពីបានចម្លើយហើយ អត្ថបទសារភាពរបស់អ្នកទោសម្នាក់នេះត្រូវបានផ្ញើទៅ “ភូមិភាគកណ្តាល ជូនបងនួន១ច្បាប់ ថ្ងៃ១១-១១-៧៧” ។

◆ ដួត ញ៉ៅ មានអាយុ២៨ឆ្នាំ ស្រុកកំណើតនៅភូមិជ្រលង ឃុំជ្រលង ស្រុកតាំងគោក ខេត្តកំពង់ចាម (បច្ចុប្បន្ន ភូមិតាំងគោក ឃុំសូយោង ស្រុកបារាយណ៍ ខេត្តកំពង់ធំ) មុនពេលចាប់ខ្លួនមាននាទីជាសមាជិកវរសេនាតូច វរសេនាធំ៦០១ កងពល១៧៤ ភូមិភាគកណ្តាល ចាប់ខ្លួននៅខែកញ្ញា ឆ្នាំ១៩៧៧និងសួរចម្លើយថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៧ ។ ដួត ញ៉ៅ ត្រូវបានក្រុមអ្នកសួរចម្លើយធ្វើទារុណកម្មឲ្យទទួលសារភាពថាខ្លួនក្បត់ និងបង្ខំឲ្យសារភាពអំពីខ្សែបណ្តាញរបស់ខ្លួនតាមខ្សែសន្ទាក់ ។ បន្ទាប់ពី ដួត ញ៉ៅ សារភាពហើយ ចម្លើយសារភាពនេះក៏បានផ្ញើទៅភូមិភាគកណ្តាល ជូនបងនួនមួយច្បាប់ នៅថ្ងៃ១១-១១-៧៧ ដែរ ។

យោងតាមចម្លើយរបស់អ្នកទោសទាំងបួនរូបនេះ បង្ហាញថា ចម្លើយសារភាពទាំងអស់របស់អ្នកទោសត្រូវបានផ្ញើមក បងនួន នៅក្នុងថ្ងៃ-ខែ-ឆ្នាំតែមួយ ។ ដូច្នេះការសម្រេចនិងការដាក់បញ្ជាក៏ស្ថិតនៅក្នុងពេលតែមួយដែរ ។ នៅក្នុងបញ្ជីសម្លាប់ មានឈ្មោះអ្នកទោសទាំងបួននាក់ត្រូវបានកម្ទេចនៅក្នុងថ្ងៃតែមួយទៀតគឺនៅថ្ងៃទី៩-១២-៧៧ ។

ថ្វីដ្បិតតែអ្នកទោសមួយចំនួនមិនត្រូវបានយកទៅសម្លាប់ក្នុងថ្ងៃតែមួយឬមិនមានឈ្មោះនៅក្នុងបញ្ជីកម្ទេចក៏ដោយ ក៏ប៉ុន្តែមានអ្នកទោសប្រហែល១៤រូបប៉ុណ្ណោះដែលមានវាសនារួចផុតពីសេចក្តីស្លាប់នៅមន្ទីរស-២១ ។ ដូចករណីអ្នកទោសខាងក្រោមពុំបានរកឃើញឈ្មោះនៅក្នុងបញ្ជីកម្ទេចនៅឡើយ ប៉ុន្តែនៅលើចម្លើយរបស់អ្នកទោសទាំងអស់សុទ្ធតែបានផ្ញើជូន នួន ជា និងពាក់ព័ន្ធជាមួយ នួន ជា ដែរ៖

◆ គង់ គៀន ហៅ អ៊ីង វ៉េត លេខាវរសេនាតូច៦៣១ វរសេនាធំ៦៣ កងពល១៦៤ ត្រូវចាប់ខ្លួននៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៨ ។ នៅក្នុងនោះឈ្មោះ អឿន ហៅ សុផល, អ៊ីង វ៉េត បានសរសេរថា ឈ្មោះនេះស្ថិតនៅក្នុងកងប្រដាប់ចលនាជាមួយខ្ញុំ ។ ឈ្មោះ អឿន នេះត្រូវបាន ឌុច ចារថា “អានេះយើងកម្ទេចហើយ...អា តាន់ ម៉េង តាមដំណឹងថា បង១៥ (ម៉ុក) គាត់កម្ទេចហើយក្នុង(ឆ្នាំ) ៧៤ដែរ” ។ ចំណារមួយផ្សេងទៀតសរសេរថា “សំ នេះ ខាងមូលដ្ឋានកម្ទេចហើយ” ក្រោយពីចាររួចនៅថ្ងៃទី២១-៥-៧៧ ឌុច បានផ្ញើអត្ថបទនេះទៅថ្នាក់លើថា “បងជាទីគោរព ក្នុងអត្ថបទនេះខ្ញុំមានចារខ្លះ ដោយគោរព!” ។ ចំណារនិងអត្ថបទនេះត្រូវបានផ្ញើមក នួន ជា តាមរយៈចំណារមួយទៀតដែលសរសេរនៅខាងលើថា **“ជូនបងនួន (ផ្ទាល់)”** ។

◆ ដេង សីន់ ហៅ ជ័យ ជាប្រធានក្រសួងពាណិជ្ជកម្មភូមិភាគកណ្តាល ត្រូវអង្គការចោទថាបានធ្វើសកម្មភាពក្បត់ ។ នៅលើចម្លើយសារភាពរបស់ ជ័យ មានសរសេរថា “អានហើយ ជូនអង្គការ២ច្បាប់ហើយ ថ្ងៃទី១៦-១០-៧៧ សំខាន់ជាទស្សនៈសម្រាប់ពង្រឹងជំហរភូមិភាគកណ្តាល” ។ នៅចុងបញ្ចប់នៃចម្លើយសារភាព ជ័យ ក៏បានសរសេររាយឈ្មោះខ្មែរ សេ.អ៊ី.អាជាប់ពាក់ព័ន្ធជាមួយខ្លួន ដែលឈ្មោះទាំងនោះភាគច្រើនត្រូវបានចាប់ខ្លួន ។

◆ អ៊ីង ប៊ុនហួ ហៅ ខ្មៅ ធ្វើការនៅក្រសួងឧស្សាហកម្ម ស្រុកកំណើតនៅភូមិអូរ ឃុំពុទ្រា ស្រុកភ្នំស្រួច (បច្ចុប្បន្ន ឃុំអូរ ស្រុកភ្នំស្រួច) ខេត្តកំពង់ស្ពឺ ត្រូវចាប់ខ្លួននៅថ្ងៃ ទី១២ ខែមីនា ឆ្នាំ១៩៧៧ ។ ចម្លើយរបស់ អ៊ីង ប៊ុនហួ បានរៀបរាប់ពីទស្សនៈនិងគោលជំហរបរិសុទ្ធរបស់ខ្លួនចំពោះបក្សកុម្មុយនិស្តកម្ពុជា ដោយសារភាពថា ក្រោមការដឹកនាំរបស់បង ប៉ុលនិងបងនួន ក្នុងបក្សកុម្មុយនិស្តកម្ពុជា បានធ្វើឲ្យខ្លួនជ្រះស្រឡះ ពេញចិត្ត គោរពស្រឡាញ់ និងដើរតាមមាគ៌ាបក្សរហូតលុះអវសានជីវិតរបស់គាត់ ។ កន្លងមក គាត់បានយកមាគ៌ាបក្សទៅអនុវត្តផ្ទាល់ ឃើញថា ទទួលបានជ័យជម្នះជាក់ស្តែង ។ ដូចជាមាគ៌ាជម្លៀសប្រជាជនកាលជំនាន់អាចេនឡា(ចេនឡាជាឈ្មោះដែល លន់ ណុល ដាក់ឲ្យប្រតិបត្តិការសឹកធំៗចំនួនពីរគឺចេនឡាទី១និងចេនឡាទី២) មាគ៌ាប្រយុទ្ធក្នុងសង្គ្រាមប្រជាជន មាគ៌ាតស៊ូដាច់ខាតគ្មានចរចា នៅឆ្នាំ១៩៧៣ មាគ៌ាចាត់តាំងសហករណ៍ មាគ៌ា ជម្លៀសប្រជាជនចេញពីក្រុង គ្មានផ្សារ មិនចាយលុយ មាគ៌ាបន្តធ្វើបដិសង្គមនិយមដឹកនាំកសាងសង្គមនិយម ពិសេសមាគ៌ាឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនឯង ។ អ៊ីង ប៊ុនហួ បានបន្តថាក្រោមការឈ្លាសវៃប៉ិនប្រសប់របស់បងប៉ុលនិងបងនួន មហាជោគជ័យមហាអស្ចារ្យលើការបោសសម្អាតពួកអាខ្មែរក្បត់ សេ.អ៊ី.អា កា.សេ.បេ និងយួនលេបទឹកដីនេះ នាំឲ្យមានជំនឿជឿជាក់មានមោទនភាពយ៉ាងខ្ពង់ខ្ពស់បំផុត ។ មិនតែប៉ុណ្ណោះ អ៊ីង ប៊ុនហួ បានបញ្ជាក់ពីភាពស្មោះត្រង់ចំពោះអង្គការថា ខ្លួនគ្មានទាក់ទិនផ្លូវក្បត់ជាមួយពួកក្បត់ណាឬក្បត់ចំពោះបក្សកុម្មុយនិស្តកម្ពុជា ដើម្បីផ្តួលរំលំបក្សដែលមានបងប៉ុលនិងបងនួនដឹកនាំទេ ។

◆ ជូ ជេត ហៅ ស៊ី អតីតលេខាភូមិភាគបស្ចិមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានរៀបរាប់គាំទ្រអំពីគោលនយោបាយបោសសម្អាតខ្មាំងរបស់គណៈកម្មាធិការមជ្ឈិមឲ្យកាន់តែច្បាស់មួយកម្រិតថែមទៀត ។ ចម្លើយសារភាពនេះបញ្ជាក់ថាៈ “ថ្ងៃមួយ បង នួន ជា ទៅជួបនៅសាលាភ្នំចតុរស គាត់ប្រាប់ពីខ្មែរក្បត់នៅក្នុងភូមិភាគបស្ចិម ។ គាត់ណែនាំថា ទាហានចាស់កុំជឿអ្វី ព្រោះអានេះវាមិនងាយលះបង់នូវគំនិតចាស់ទេ ដូច្នេះត្រូវកម្ទេចទាំងអស់ចុះ ។ ពេលនោះខ្ញុំឆ្លើយតបថាៈ ឥឡូវនេះឲ្យតែអ្នកណាប្រឆាំងនឹងបដិវត្តគឺបោសសំអាតទាំងអស់ នៅសល់តែក្មេងៗជំនាន់ក្រោយក៏យកដែរ” ។

◆ ឯកសារផ្សេងទៀតបានបង្ហាញពីទំនាក់ទំនងគ្នារវាងថ្នាក់លើនិងថ្នាក់ក្រោម និងការទទួលដឹងឮ ដែលថ្នាក់ក្រោមផ្ញើទៅកាន់ថ្នាក់លើ សុទ្ធតែមានចារស៊េរីតែគ្រប់បន្ទាត់ចុងក្រោយថា ចម្លងជូនៈ អ៊ំ, អ៊ំនួន, បងវ៉ាន់, បងវន, បងខៀវ, មន្ទីរឯកសារ ។ នៅក្នុងទូរលេខមួយចុះថ្ងៃទី១២-១០-៧៦ ឡាំង បានឆ្លើយតបនឹងទូរលេខរបស់ នួន ជា ដែលផ្ញើមកឲ្យខ្លួន ។ ខ្លឹមសារទូរលេខនោះនិយាយថា “ជូនបងនួនជាទីស្នេហានឹករលឹក ១) យើងខ្ញុំបានទទួលទូរលេខរបស់បងហើយ ទាំងខ្លឹមសារណែនាំទាំងអស់យើងខ្ញុំបានចាប់អារម្មណ៍ខ្លាំងក្លាដែរ ២) យើងខ្ញុំបានចាត់តាំងក្រុមពាណិជ្ជកម្មមួយក្រុមប្រចាំភ្នំពេញ សមមិត្តជួនទទួល ។ ៣) អំពីវិទ្យុទាក់ទងថាខូចនេះ ជួសជុលបានវិញហើយ មិនបានជូនទេ ទុកប្រើ ឯវិទ្យុថ្មីមិនបានប្រើទេ ទុកដដែល ។ ដោយភាតរភាពបដិវត្តយ៉ាងកក់ក្តៅបំផុត” ។ ឯកសារនេះបានចម្លងជូនបងនួន និងមន្ទីរ ទុកជាឯកសារ ។ ឯកសារលេខ១៦ផ្ញើជូនប៉ុលពត ហើយត្រូវបានចម្លងជូន នួន ជា រៀបរាប់អំពីលទ្ធផលក្នុងសមរភូមិ “៤៧” រាយការណ៍ថា “យើងកម្ទេចខ្មាំងរស់បានប្រហែល១០០ក្បាលហើយ ។ ខ្មាំងត្រូវកាត់ជា៣កង់ ។ យើងចាប់បាន៣ក្បាល ។ បាញ់ចោល២ក្បាល ដោយវាលោតទឹកទន្លេ សល់១ក្បាលបញ្ជូនទៅស-២១ល្ងាចនេះ” ។

យោងតាមឯកសារដែលខ្ញុំលើកយកមកនេះ គេអាចបង្ហាញថា នួន ជា មានចំណែកទទួលខុសត្រូវក្នុងការសម្រេចនិងសម្លាប់មនុស្សជាតិដែរឬទេ?

**លី សុផល**

# នៅពេលដែលការអត់ឃ្លានចូលមកដល់

នៅថ្ងៃទី១៧ មេសា ១៩៧៥ អ្នកស្រី គ្រួច សំអាន ត្រូវអង្គការខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ឲ្យទៅរស់នៅខេត្តពោធិសាត់ ។

ពោធិសាត់គឺជាខេត្តមួយស្ថិតនៅទិសពាយ័ព្យនៃប្រទេសកម្ពុជា សម្បូរព្រៃភ្នំនិងតំបន់មួយចំនួន ផ្ទុកទៅដោយមេរោគគ្រុនចាញ់ និងខ្វះខាតទឹកនៅរដូវប្រាំង ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទឹកដីខេត្តពោធិសាត់ត្រូវបានខ្មែរក្រហមហៅថាដីខ្លាញ់ ។ កម្ពុជាប្រជាធិបតេយ្យបានបញ្ចូលខេត្តពោធិសាត់ទៅក្នុងភូមិភាគពាយ័ព្យ និងចែកចេញជាពីរតំបន់គឺ តំបន់៦ និងតំបន់៧ ។ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ ត្រូវជម្លៀសឲ្យទៅរស់នៅតាមបណ្ដាខេត្តនានា រួមមានខេត្តខេត្តពោធិសាត់និងបាត់ដំបង ។ ប្រជាជនទីក្រុង ត្រូវបានខ្មែរក្រហមដាក់ឈ្មោះថា ប្រជាជន១៧មេសា ឬប្រជាជនថ្មី ។ នៅទូទាំងប្រទេសកម្ពុជា ទីកន្លែងដែលប្រជាជន១៧មេសាត្រូវលត់ដំខ្លាំងបំផុតគឺខេត្តពោធិសាត់ ។ ដោយសារទឹកដីខេត្តពោធិសាត់ជាទឹកដីពិបាករស់នៅផង និងដោយសារការគ្រប់គ្រងមានសភាពរឹតបន្តឹងជាងតំបន់នានាផងនោះ បានធ្វើឲ្យប្រជាជនមួយចំនួនធំត្រូវស្លាប់នៅទីនោះ ។


អ្នកស្រី គ្រួច សំអាន

នៅក្នុងខេត្តពោធិសាត់ ក្រុមគ្រួសាររបស់អ្នកស្រី គ្រួច សំអាន និងគ្រួសារអ្នកជម្លៀសជាច្រើនទៀត ត្រូវរស់នៅកណ្ដាលវាលព្រៃរបោះនិងវាលស្បូវដ៏ធំល្វឹងល្វើយ គឺជាតំបន់ដែលមិនធ្លាប់មានមនុស្សរស់នៅពីមុនមក ។ តំបន់ដែលអ្នកស្រីរស់នៅមានឈ្មោះថា សហករណ៍ស្វាយស ស្ថិតនៅក្នុងឃុំស្វាយស ស្រុកក្រគរ ខេត្តពោធិសាត់ ។ ប្រជាជនដែលរស់នៅសហករណ៍ស្វាយស សុទ្ធសឹងជាអ្នក១៧មេសាទាំងអស់ ។ សហករណ៍ ស្វាយសចែកចេញ ជាច្រើនកង ហើយសមាជិកគ្រួសារនីមួយៗត្រូវរស់នៅបែកខ្ញែកគ្នាទៅធ្វើការតាមកងផ្សេងៗ ។ ខ្លួនអ្នកស្រីនិងប្អូនស្រីម្នាក់ត្រូវទៅរស់នៅក្នុងកងចល័ត ។ ប្អូនប្រុសម្នាក់ត្រូវទៅធ្វើការនៅក្នុងកងភ្ជួរ ។ ប្អូនប្រុសពៅ២នាក់ទៀតដែលជាកូនក្មេង ត្រូវទៅនៅក្នុងកងកុមារ ។ ចំណែកឪពុកម្ដាយរបស់អ្នកស្រី ត្រូវរស់នៅក្នុងសហករណ៍ ។ នៅឆ្នាំ១៩៧៦ ឪពុកម្ដាយរបស់អ្នកស្រីបានស្លាប់ ដោយសារតែការអត់ឃ្លាន ។ អ្នកស្រីបានបញ្ជាក់ថា នៅដង្ហើមចុងក្រោយរបស់ឪពុកម្ដាយអ្នកស្រីគឺគាត់ស្រែករកអ៊ីហូប ព្រោះគាត់ឃ្លានណាស់! ឃ្លានណាស់! ។ ចំណែកប្អូនប្រុសម្នាក់របស់អ្នកស្រីដែលកាលណោះនៅជាកុមារនៅឡើយ ក៏បានស្លាប់ដោយសារតែទារុណកម្មពីសំណាក់កុមារដូចគ្នា ។

នៅសហករណ៍ស្វាយស អ្នកស្រី គ្រួច សំអាន មានប្រសាសន៍ថា នៅពេលទៅរស់នៅទីនោះដំបូង ខ្មែរក្រហមឲ្យប្រជាជនហូបបាយឆ្អែតជានិច្ច ។ ក្នុងប្រជាជនម្នាក់បានទទួលរបបអង្ករ១កំប៉ុងកន្លះក្នុងមួយថ្ងៃ ។ ពេលវេលាឆ្អែតស្កប់ស្កល់នេះមានរយៈពេលតែ១ខែកន្លះប៉ុណ្ណោះ របបអង្ករក៏ចាប់ផ្ដើមបន្ថយមកនៅត្រឹម១កំប៉ុង២នាក់ក្នុង១ថ្ងៃ បន្ទាប់មក១កំប៉ុង៣នាក់ បន្ទាប់មក១កំប៉ុង៤នាក់ បន្ទាប់មកទៀត១កំប៉ុង៨នាក់ រហូតដល់ទីបំផុតគឺបបរ១ខ្ទះដាក់អង្ករតែ១កំប៉ុងប៉ុណ្ណោះសម្រាប់មនុស្សមួយសហករណ៍ ។ ដើមឆ្នាំ១៩៧៦ របបអាហារសម្រាប់ប្រជាជននៅសហករណ៍ស្វាយសគឺអង្ករ១កំប៉ុងសម្រាប់បបរ១ខ្ទះត្នោត ។ របបសម្រាប់មនុស្សម្នាក់ៗគឺបបរមួយវែកត្រឡោកដែលចុងភៅផ្ទះបាយសមូហភាពដួសដាក់ចូលក្នុងចាន ។ ម៉្លោះហើយ ប្រជាជនដែលរស់នៅក្នុងសហករណ៍ស្វាយសទាំងមូលត្រូវជួបប្រទះនឹងការអត់ឃ្លានយ៉ាងខ្លាំង ។ អ្នកស្រីមានប្រសាសន៍ថា ដោយសាររបបអាហារហូបមិនឆ្អែត មនុស្ស

ម្នាក់ៗខិតខំដើរបេះបោចបន្លែបន្លា ស្លឹកឈើព្រៃ រកចាប់ត្រីក្តាមខ្យង សត្វល្អិតល្អោចដែលអាចហូបបាន ដើម្បីយកមកបំពេញក្រពះ ។ ប៉ុន្តែរបស់ទាំងអស់នេះមិនអាចបំបាត់ភាពស្រេកឃ្លានរបស់ប្រជាជនទេ ។ នៅពេលដែលការអត់ឃ្លានឈានដល់ដំណាក់កាលខ្លាំងក្លាបំផុត ប្រជាជនមួយចំនួនបានបរិភោគសាច់មនុស្សដូចគ្នា ជួនកាលគឺជាសាច់របស់សមាជិកក្នុងគ្រួសារខ្លួនតែម្តង ។ ប្រសិនបើនៅក្នុងគ្រួសារមួយមានសមាជិកណាម្នាក់ឈឺជិតស្លាប់ សមាជិកដទៃទៀតមិនទុកឲ្យអ្នកជំងឺស្លាប់ទាន់ទេ គេនឹងសម្លាប់អ្នកជំងឺនោះធ្វើជាម្ហូបសម្រាប់គ្រួសារ ប៉ុន្តែសកម្មភាពនេះត្រូវធ្វើដោយលួចលាក់មិនឲ្យអ្នកដទៃដឹងឡើយ ព្រោះអង្គការហាមផ្តាច់មិនឲ្យមានការបរិភោគជាឯកជនក្បត់សមូហភាពទេ ។ ប្រសិនបើនរណាម្នាក់ឬគ្រួសារណាមួយត្រូវបានរកឃើញថាលួចហូបក្បត់សមូហភាព នឹងត្រូវមានទោសដល់ស្លាប់ ។ មានមនុស្សមួយចំនួនទៀតបានលួចគាស់សាកសពដែលទើបតែកប់ថ្មីៗ ដើម្បីយកសាច់ធ្វើជាអាហារ ។ អ្នកស្រីបានបញ្ជាក់ឲ្យដឹងថា នៅក្នុងកងទី២០នៃសហករណ៍ស្វាយស ស្ត្រីមេម៉ាយម្នាក់បានសម្លាប់កូនរបស់គាត់ដែលឈឺជិតស្លាប់ ដើម្បីធ្វើសម្លទទួលទាន ។ នៅក្នុងកងទី១៩ ពីរនាក់ប្តីប្រពន្ធបានសម្លាប់កូនរបស់ខ្លួនចំនួន២នាក់ជាបន្តបន្ទាប់គ្នាធ្វើជាអាហារ ។ នៅក្នុងកងទី២៣ កូនប្រុស៣នាក់បានសម្លាប់ឪពុករបស់ខ្លួនដែលជិតស្លាប់ ហើយព្រលះយកសាច់ឪពុកទុកសម្រាប់បរិភោគ ។ ករណីមួយទៀត អ្នកស្រី គ្រួច សំអាន បញ្ជាក់ថាបានកើតឡើងចំពោះប្អូនប្រុសរបស់អ្នកស្រីផ្ទាល់តែម្តង ។ ក្នុងអំឡុងខែ៥ ឆ្នាំ១៩៧៦ ជាដំណាក់កាលដែលរបបអាហារត្រូវបន្ថយរហូតដល់បបរ១ខ្ទះមានតែអង្ករ១កំប៉ុង ។ ដោយអត់ឃ្លានខ្លាំងពេក ប្អូនប្រុសរបស់អ្នកស្រីបានទៅសុំរស់នៅក្នុងមណ្ឌលកុមាររបស់សហករណ៍ទឹកជុំដែលស្ថិតនៅចម្ងាយប្រមាណ២០គីឡូម៉ែត្រពីសហករណ៍ស្វាយស ប៉ុន្តែត្រូវប្រធានមណ្ឌលកុមារបដិសេធ មិនតែប៉ុណ្ណោះថែមទាំងត្រូវកុមារនៅក្នុងមណ្ឌលនោះរករឿងវាយតប់រហូតមានរបួសនៅកំភួនជើងថែមទៀត ។ វិលវិញបានមួយថ្ងៃ ប្អូនប្រុសរបស់អ្នកស្រីក៏ស្លាប់ដោយសារជំងឺតេតាណូសមុខរបួសនោះ ។ នៅពេលដែលអ្នកស្រីយកសពប្អូនប្រុសទៅកប់រួចថ្មីៗ ស្រាប់តែមានមនុស្សលួចគាស់សពនោះយកទៅកាប់ចិញ្ច្រាំធ្វើជាម្ហូបអាហារ ។ ១សប្តាហ៍ក្រោយមក អ្នកស្រីបានស្គាល់មុខអ្នកដែលលួចគាស់សាកសពប្អូនប្រុសរបស់គាត់ នៅពេលដែលជននោះយកសាច់មកអាំង ហើយត្រូវឈ្លបសង្ស័យក៏ឆែករកឃើញពាងដាក់សាច់មនុស្សនៅលើផ្ទះ ។ ជនល្មើសនោះគឺជាកុមារម្នាក់ដែលមានអាយុទើបតែជាង១០ឆ្នាំ ។

យប់មួយនាឆ្នាំ១៩៧៧ នៅឯសហករណ៍កោះជុំ ពេលដែលមនុស្សទាំងអស់ក្នុងសហករណ៍កំពុងតែប្រជុំជីវភាព ស្រាប់តែមានភាពផ្អើលឆោឡោដោយសារមានមនុស្សព្រៃមកចាប់ក្មេងយកទៅ ។ បន្ទាប់ពីឈ្លបព័ទ្ធចាប់បាន ជនល្មើសបានសារភាពថា ពីមុនខ្លួនជាកងទ័ពរំដោះ ហើយនៅក្រោយថ្ងៃ


សាច់សាលោហិតជនរងគ្រោះក្រោមរបបខ្មែរក្រហម

១៧មេសា ឆ្នាំ១៩៧៥ ក៏ត្រូវរំសាយឲ្យទៅធ្វើការនៅក្នុងកងដឹកជញ្ជូន បានតែមួយរយៈខ្លីក៏គេចខ្លួនទៅរស់នៅក្នុងព្រៃរហូត ។ ក្រុមមនុស្សព្រៃនេះមានគ្នា៧នាក់ គឺជាក្រុមមនុស្សដែលគេចពីការគ្រប់គ្រងរបស់របបខ្មែរក្រហម ។ ម្ហូបអាហាររបស់ក្រុមមនុស្សព្រៃនេះ គឺជាសាច់មនុស្សដែលគេតែងតែចូលមកលបលួចចាប់ពីភូមិយកទៅ ។

នៅក្នុងសៀវភៅកំណត់ហេតុរបស់សមមិត្ត ញ៉ុក សាខុន ជាកម្មាភិបាលខ្មែរក្រហមមួយរូប បានសរសេរពាក្យស្លោកមួយឃ្លាថា «សេចក្តីអត់ឃ្លានជារោគមានអានុភាពជាងគេទាំងឡាយ» ។ ជាមួយនឹងទ្រឹស្តីនេះ ខ្មែរក្រហមពិតជាយល់ច្បាស់ណាស់ថា អ្វីដែលមនុស្សត្រូវការបំផុតសម្រាប់ជីវិតគឺអាហារ ។ បើគ្មានអាហារ មនុស្សមិនអាចរស់បានទេ ។ ទោះបីជាយល់ច្បាស់យ៉ាងនេះក៏ដោយ ក៏ខ្មែរក្រហមបែរជាផ្តល់អាហារឲ្យប្រជាជនតិចបំផុត ក្នុងខណៈដែលខ្លួនបង្ខំឲ្យប្រជាជនធ្វើការច្រើនបំផុត ។ នៅពេលដែលបរិមាណអាហារមិនមានតុល្យភាពនឹងទំហំនៃការងារ ប្រជាជនត្រូវទទួលរងនូវគ្រោះទុរ្ភិក្ស បាក់កម្លាំង និងការរាគត្បាតពីជំងឺផ្សេងៗ ដែលទាំងអស់នេះជាមូលហេតុនាំដល់ការស្លាប់បាត់បង់ជីវិតប្រជាជនអស់ជាច្រើនសែននាក់ ។ សម្រាប់សហករណ៍ស្វាយសនៅក្នុងឃុំស្វាយស ស្រុកក្រគរ ខេត្តពោធិសាត់ អ្នកស្រី គ្រួច សំអាន បានឲ្យដឹងថា គ្រាន់តែនៅក្នុងកងទី២០ដែលអ្នកស្រីរស់នៅ ពីដំបូងមានមនុស្សប្រមាណ២០០នាក់ ក្រោយមកនៅសល់ប្រហែលតែ៣៥នាក់ប៉ុណ្ណោះ ។ គ្រួសាររបស់អ្នកស្រីដែលមានសមាជិក៨នាក់ នៅសល់តែ៤នាក់ប៉ុណ្ណោះដែលរស់រានមានជីវិត ។


ធ្វើដំណើរមកស្រុកកំណើតវិញនៅឆ្នាំ១៩៧៩

ប៉ុល ពត លេខាបក្សកុម្មុយនិស្តកម្ពុជា និងជារដ្ឋមន្ត្រីទី១នៃកម្ពុជាប្រជាធិបតេយ្យ តែងតែប្រកាសក្តែងៗប្រាប់សកលលោកថា នៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលកម្ពុជាប្រជា-ធិបតេយ្យ ប្រជាជនកម្ពុជាមានជីវភាពរស់នៅសម្បូររុងរឿង មានអាហារហូបចុកយ៉ាងបរិបូរណ៍ មានលំនៅឋានសមរម្យ មានសម្លៀកបំពាក់គ្រប់គ្រាន់ មានសេវាសង្គមយ៉ាងប្រសើរ មានស្មារតីបដិវត្តខ្ពស់ ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន មិនពឹងពាក់បរទេស និងមានភាពស្មើៗគ្នា ។ ធាតុពិតនៅពីក្រោយពាក្យសម្តីទាំងនេះ ប្រជាជនរស់នៅប្រៀបបានទាសករនៅក្នុងខ្ទមតូចៗ ដែលមិនស័ក្តិសមជាផ្ទះ បរិភោគអាហារនិងធ្វើការងារដូចសត្វធាតុ ។ ប្រទេសកម្ពុជាទាំងមូលត្រូវប្រែក្លាយទៅជាគុកឥតជញ្ជាំង ហើយប្រជាជនទាំងអស់ក្លាយទៅជាអ្នកទោសរបស់គុកនេះ ។

ការស្លាប់ដែលបណ្តាលមកពីអត់អាហារ ធ្វើការបាក់កម្លាំង រស់នៅគ្មានផាសុក សេវាសង្គមកិច្ចនិងសុខាភិបាលមិនត្រឹមត្រូវ បូករួមទាំងការកាប់សម្លាប់ប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់ទៀត បានធ្វើឲ្យចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកើនដល់ជិត៣លាននាក់ ស្មើនឹងជាង៤០ភាគរយនៃចំនួនប្រជាជនទាំងអស់ ។

**សាន់ កល្យាណ**

# ថ្នាំអាចម៌ទន្សាយ

ថ្នាំអាចម៌ទន្សាយជាថ្នាំដែលផលិតឡើងដោយឱសថការិនី មិនសូវចេះអក្សររបស់ខ្មែរក្រហម ។ ថ្នាំអាចម៌ទន្សាយផ្សំចេញពីឫសឈើសំបកឈើផ្សេងៗតាមការនឹកឃើញរបស់អង្គការខ្មែរក្រហម ។ ការផលិតថ្នាំពេទ្យដោយគ្មានការពិសោធន៍តាមលក្ខណៈវិទ្យាសាស្ត្រសុខាភិបាល បានធ្វើឲ្យបាត់បង់ជីវិតនិងខូចសុខភាពប្រជាជនអស់មួយចំនួនធំ ។

ថ្នាំអាចម៌ទន្សាយជាថ្នាំដែលប្រជាជនកម្ពុជាបានដាក់ឈ្មោះឲ្យ បញ្ជាក់ពីរូបលក្ខណៈនិងអសមត្ថភាពនៃថ្នាំ ។ លោកពូអ៊ុក ឡាយអ៊ីម បានឲ្យដឹងថា មូលហេតុដែលប្រជាជនដាក់ឈ្មោះថ្នាំនេះថាថ្នាំ«អាចម៌ទន្សាយ» ព្រោះថ្នាំទាំងនេះធ្វើឡើងពីឫសឈើព្រៃមួយចំនួនកិនឲ្យម៉ដ្ឋលាយជាមួយជ័រឆ្នង់ពណ៌ខ្មៅ រួចសូនជាគ្រាប់តូចៗមានសណ្ឋានដូចអាចម៌ទន្សាយ ។ ម្យ៉ាងទៀតថ្នាំនេះគ្មានប្រសិទ្ធភាពទេ ប្រៀបដូចជាលេបអាចម៌ទន្សាយ ហេតុដូច្នេះហើយទើបប្រជាជនកម្ពុជា ហៅថា «ថ្នាំអាចម៌ទន្សាយៗ» ។

ថ្នាំអាចម៌ទន្សាយត្រូវបានអគ្គលេខាបក្សកុម្មុយនិស្តកម្ពុជា និងជារដ្ឋមន្ត្រីទី១នៃរបបកម្ពុជាប្រជាធិបតេយ្យ «ប៉ុល ពត» ប្រកាសឲ្យប្រើប្រាស់ជាផ្លូវការ ។ ថ្នាំអាចម៌ទន្សាយត្រូវបានផ្សព្វផ្សាយឲ្យផលិតនៅគ្រប់មន្ទីរពេទ្យទាំងអស់ទូទាំងកម្ពុជាប្រជាធិបតេយ្យ ដើម្បីបម្រើផ្នែកសុខភាពជូនប្រជាជនដោយឥតលក្ខខណ្ឌ ។ ទ្រឹស្តីរបស់អង្គការខ្មែរក្រហមបានអះអាងយ៉ាងច្បាស់ថា «យើងមិនផ្អែកលើបច្ចេកទេសទេ យើងឈរលើគោលជំហរបដិវត្តដើម្បីកសាងប្រទេស អ្វីៗមិនបដិវត្ត មិនធ្វើ ។» «ពេទ្យសង្គមនិយមត្រូវកម្ចាត់កាលសំណល់ពីសង្គមចាស់ កម្ចាត់ទស្សនៈសតិអារម្មណ៍គោលជំហរប្រើប្រាស់ថ្នាំសម័យសំបូរបែប» ។ ប៉ុល ពត បានបញ្ជាក់យ៉ាងច្បាស់ថា «យើងត្រូវរៀបចំចាត់តាំងក្រុមស្រាវជ្រាវដោយរួមផ្សំវិជ្ជា យើងរួមផ្សំចលនាដាក់ស្តែងនិងពិសោធន៍សកលផង ។ ទោះបីរូបមន្តមិនទាន់ចងក្រងក៏ដោយ ក៏យើងអាចផលិតថ្នាំបានដែរ ។ យើងអនុវត្តគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនខាងថ្នាំសង្កូវ» ។


សុក គីម

បងស្រី សុក គីម អតីតនារីពេទ្យរបស់ខ្មែរក្រហមនៅខេត្តតាកែវ បាននិយាយថា អង្គការឲ្យផលិតថ្នាំបុរាណ «ថ្នាំអាចម៌ទន្សាយ» ព្រោះអង្គការចង់ឲ្យប្រជាជនប្រើថ្នាំពេទ្យផលិតក្នុងស្រុក ។ អង្គការមិនចង់ពឹងពាក់បរទេស ។ ម្យ៉ាងទៀតអង្គការនិយាយថា «បើប្រើតែថ្នាំបរទេស យើងអត់ចេះផលិតថ្នាំពេទ្យប្រើដោយខ្លួនឯងឡើយ» ទោះបីមានថ្នាំពេទ្យមកពីបរទេសក៏ដោយ ក៏អង្គការមិនឲ្យប្រើដែរ ។ អង្គការចង់ឲ្យឯករាជ្យម្ចាស់ការដោយខ្លួនឯង ។

រូបមន្តថ្នាំដែលក្រសួងសុខាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យបង្រៀនឱសថការីខ្មែរក្រហមឲ្យចេះផលិតមានជាអាទិ៍ គឺថ្នាំគ្រុនក្តៅ ថាំឈឺក្បាល ថ្នាំឈឺពោះ ថ្នាំគីនីន និងថ្នាំខ្យល់ ។ ឧទាហរណ៍រូបមន្តថ្នាំបំបាត់គ្រុនក្តៅគឺយកជំឡូងមី ដើមកំប៉ោយចិន និងដើមប្រមោយដំរី ហាលឲ្យស្ងួតរួចកិនបញ្ចូលគ្នាឲ្យម៉ដ្ឋ ទើបយកមកលាញ់ជាមួយទឹកដើម្បីសូនជាថ្នាំគ្រាប់ ។ បងស្រី ញឹម ហាន អតីតនារីពេទ្យនៅភូមិភាគពាយ័ព្យ បានឲ្យដឹងថា រូបមន្តធ្វើថ្នាំបំបាត់គ្រុនក្តៅមានលក្ខណៈខុសៗគ្នា នៅកន្លែងរបស់គាត់ របៀបធ្វើថ្នាំគ្រុនក្តៅ គឺយកដើមបណ្តូលពេជ្រនិងគ្រាប់ស្វែងទៅលីងបុកប្របល់ឲ្យ


ញឹម ហាន



មៀច ផាន

ម្ទ័ដជាមួយដំឡូងមី រួចទើបយកទៅលាយស្ករក្រហមតិចៗ ហើយបោះពុម្ពចេញជាថ្នាំគ្រាប់ដែលមានពណ៌សៗ ។ បងស្រីបន្ថែមថា ថ្នាំទាំងនោះស័ក្តិសិទ្ធិឬមិនស័ក្តិសិទ្ធិគាត់មិនដឹងទេ គាត់ធ្វើតាមតែបញ្ជាអង្គការប៉ុណ្ណោះ ។ ចំពោះរូបមន្តថ្នាំឈឺក្បាល គឺពេទ្យខ្មែរក្រហមយកតែដំឡូងមីកិនឲ្យម្ទ័ដលាយសាច់ដូត្រាំបុ្កទឹកក្រូចឆ្មារ រួចសូនជាគ្រាប់ហាលឲ្យស្ងួត ។ ថ្នាំត្រជាក់ធ្វើពីទឹកប្រមាត់មនុស្សលាយជាមួយម្សៅមីនិងដើមឈើច្រើនមុខកិនលាយបញ្ចូលគ្នា រួចសូនជាគ្រាប់ៗ ។ ថ្នាំដែលផលិតបាន ជួនកាលមានពណ៌ស ជួនកាលមានពណ៌ខ្មៅ ។ ថ្នាំដែលមានពណ៌ខ្មៅ ជាថ្នាំដែលយកជ័រធ្នង់លាយបញ្ចូលគ្នាទើបបណ្តាលឲ្យមានពណ៌ខ្មៅ ។ បងស្រី មៀច ផាន នារីពេទ្យនៅមន្ទីរពេទ្យស្រុកត្រាំកក់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាពូន ។ គាត់ជាបុគ្គលិកធ្វើថ្នាំបុរាណដែលមិនចេះអក្សរទាល់តែសោះ ប៉ុន្តែគាត់អាចផលិតថ្នាំជូនអង្គការបាន ។ បងស្រីបញ្ជាក់ថា កងឈ្លបខ្មែរក្រហមបានសម្លាប់មនុស្សនៅនរាយណ៍ រួចបានបញ្ជូនប្រមាត់មនុស្សណាដែលល្អមកឲ្យមន្ទីរពេទ្យស្រុកត្រាំកក់ជារៀងរាល់ខែ ដើម្បីធ្វើថ្នាំបំបាត់គ្រុនក្តៅ ។ នៅក្នុងសៀវភៅជំនុំជម្រះរបស់តុលាការប្រជាជនបដិវត្តន៍ ខែសីហា ឆ្នាំ១៩៧៩ សាក្សីឈ្មោះ ខឹម មាលិសច័ន្ទ អាយុ៣៧ឆ្នាំ បានឲ្យដឹងថា



នារីពេទ្យខ្មែរក្រហមកំពុងកាប់ចិញ្ច្រាំដើមឈើធ្វើថ្នាំ

កងឈ្លបខ្មែរក្រហមវះមនុស្សទាំងរស់ដើម្បីយកប្រមាត់ធ្វើថ្នាំ ។ តាហៀង ប្រធានឈ្លបនៅឃុំស្អាងភ្នំ និងជាអតីតសង្ឃរាជនៅវត្តស្អាងភ្នំ បានយកប្រមាត់មនុស្សដែលទើបវះរួចមកបង្ហាញឲ្យបងស្រីមើល ។ តាហៀង និយាយថា ប្រមាត់មនុស្សដែលមានសុខភាពល្អគឺមានទឹកពេញ ឯប្រមាត់មនុស្សមានសុខភាពមិនល្អមានទឹកតែកន្ទះឬបន្តិចបន្តួចប៉ុណ្ណោះ ។

ទោះបីពេទ្យខ្មែរក្រហមខិតខំសម្លាប់មនុស្សដើម្បីយកប្រមាត់មកធ្វើថ្នាំព្យាបាលឲ្យអ្នកជំងឺយ៉ាងណាក៏ដោយ ក៏ថ្នាំពេទ្យរបស់ខ្មែរក្រហមពុំសូវមានប្រសិទ្ធភាពដដែល ។ ជួនកាល ថ្នាំពេទ្យជាមូលហេតុបណ្ដាលឲ្យអ្នកជំងឺមានគ្រោះថ្នាក់ដល់ជីវិត ដោយសារតែដាក់លាយគ្រាប់ស្វែងច្រើនហួសកំណត់ ។ នៅក្នុងកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងសិក្សាធិការ បានរាយការណ៍ប្រាប់អង្គប្រជុំអំពីបញ្ហាដែលពេទ្យខ្មែរក្រហមផលិតថ្នាំពេទ្យពុំសូវមានប្រសិទ្ធភាព ។ ទោះជាមានរបាយការណ៍យ៉ាងនេះក៏ដោយ ក៏ ប៉ុល ពត នៅតែបន្តជំរុញឲ្យពេទ្យផលិតថ្នាំឲ្យប្រជាជនប្រើប្រាស់ដដែល ។ ប៉ុល ពត បាន លើកហេតុផលថា «ទោះបីជាថ្នាំមានប្រសិទ្ធភាពឬអត់ប្រសិទ្ធភាពត្រូវតែធ្វើតទៅទៀតដើម្បីដកពិសោធន៍» ។ លោកយាយ អឿន រិះតែនឹងបាត់បង់ជីវិតនៅក្នុងមន្ទីរពេទ្យព្រៃល្វា ឃុំលាយបូរ ដោយសារតែថ្នាំអាចម៍ទន្សាយ ។ ថ្នាំអាចម៍ទន្សាយបានធ្វើឲ្យលោកយាយវិលក្រឡាប់ចាក់និងវង្វេងស្មារតីនៅពេលលេបវាចូលទៅក្នុងពោះម្ដងៗ ។ លោកយាយបន្ថែមថា បើពេទ្យចែកថ្នាំអាចម៍ទន្សាយឲ្យហើយយើងមិនព្រមលេប យើងនឹងទទួលការស្ដីបន្ទោស និងវិន័យបណ្ដេញចេញពីពេទ្យទៅធ្វើការនៅការដ្ឋានវិញ ។ គាត់ខំទ្រាំលេបថ្នាំតាមបញ្ជារបស់ពេទ្យ ទោះបីដឹងថាថ្នាំទាំងនោះធ្វើឲ្យសុខភាពរបស់គាត់កាន់តែទ្រុឌទ្រោមក៏ដោយ ។ នៅពេលដែលថ្នាំមានប្រតិកម្ម នារីពេទ្យបានយកស្ករត្នោតមកឲ្យគាត់ពីសាដើម្បីបន្សាបជាតិពុលរបស់ថ្នាំ ។ នៅក្នុងមន្ទីរពេទ្យ គ្មានអ្នកជំងឺណាម្នាក់ចង់លេបថ្នាំដែលអង្គការផលិតដោយឫសឈើឫសព្រៃនោះទេ ។ ជួនកាលអ្នកជំងឺបានលួចយកថ្នាំទាំងនេះទៅបោះចោលតែម្ដង ។ សមមិត្ត គ្រិន ដែលជាប្រធានពេទ្យរបស់ខ្មែរក្រហមនៅជីផ្នាំង ភូមិភាគបស្ចិម ត្រូវស្លាប់មួយរំពេចដោយសារលេបថ្នាំអាចម៍ទន្សាយ ។ គាត់លេបថ្នាំចំនួន៣គ្រាប់ដួនៗគ្នា៣ដង ព្រោះតែគាត់ចង់ឆាប់ជាសះស្បើយពីជំងឺគ្រុនញាក់ ប៉ុន្តែ គ្រិន បែរជាស្លាប់បន្ទាប់ពីលេបថ្នាំភ្លាម ។ នៅមន្ទីរពេទ្យខេត្តកំពង់ចាម ស្ត្រីមានផ្ទៃពោះចំនួន៣នាក់ត្រូវរលូតកូនភ្លាមបន្ទាប់ពីប្រើប្រាស់ថ្នាំបុរាណ«អាចម៍ទន្សាយ»របស់ខ្មែរក្រហម ។


អៀង ធីរិទ្ធ

ដោយសារតែយកថ្នាំបុរាណធ្វើជាថ្នាំដកពិសោធន៍តាមបញ្ជារបស់ ប៉ុល ពត ទើបមានប្រជាជនជាច្រើនត្រូវស្លាប់បាត់បង់ជីវិតដោយសារការពិសោធន៍នេះ ។ បើតាមការសិក្សាបានឲ្យដឹងថា ការផលិតថ្នាំបែបបុរាណរបស់ខ្មែរក្រហមធ្វើឡើងដោយគ្មានបច្ចេកទេសឬក្បួនច្បាប់ច្បាស់លាស់ឡើយ ។ អង្គការគ្រាន់តែប្រមូលតាៗសង្គមកិច្ចដែលចេះរូបមន្តថ្នាំបុរាណ មកឲ្យជួយបង្រៀនពីវិធីធ្វើថ្នាំពេទ្យដល់បុគ្គលិកនៅតាមមន្ទីរពេទ្យប៉ុណ្ណោះ ។ តាពូន ជាគ្រូថ្នាំបុរាណ ត្រូវខ្មែរក្រហមលើកបន្តុបឲ្យធ្វើជាប្រធានសង្គមកិច្ច (ប្រធានផ្នែកផលិតថ្នាំបុរាណ) នៅមន្ទីរពេទ្យស្រុកត្រាំកក់ ដើម្បីបង្រៀនអំពីវិធីធ្វើថ្នាំដល់នារីពេទ្យដែលមិនសូវចេះអក្សរនិងខ្លះមិនចេះអក្សរតែម្ដង ។ ហែម អាងអតីតពេទ្យរបស់ខ្មែរក្រហមនៅក្រុងភ្នំពេញ បានឲ្យដឹងថានៅពេលដែលអង្គការឲ្យគាត់មកស្រាវជ្រាវនិងផលិតថ្នាំបុរាណខ្លួនគាត់មិនស្គាល់ដើមថ្នាំទាល់តែសោះ ។ ហេតុដូច្នេះហើយ ទើបធ្វើឲ្យការផលិតថ្នាំចេះតែខូចគុណភាពនិងខ្វះប្រសិទ្ធភាពក្នុងការព្យាបាល ។ ទោះជា ប៉ុល ពត ដឹងថាថ្នាំដែលខ្លួនបញ្ជាឲ្យផលិតពុំសូវមានប្រសិទ្ធភាពនិងធ្វើឲ្យប្រជាជនមួយចំនួនស្លាប់ក៏ដោយក៏ ប៉ុល ពត នៅតែបន្តជំរុញឲ្យមន្ទីរពេទ្យទាំងអស់អនុវត្តនូវការផលិតថ្នាំឲ្យទាន់ផែនការដដែល ថែមទាំងបានអះអាងថាមានរូបមន្តផ្សំថ្នាំពេទ្យជាច្រើនដែលអង្គការចងក្រងទុកជាសៀវភៅសម្រាប់ឲ្យក្រសួងសុខាភិបាលកម្ពុជាប្រជាធិបតេយ្យយកទៅអនុវត្តទៀតផង ។

**វ៉ែម សុខឃីម**

**(តពីលេខមុន)**

## ជំពូកទី៦: បរិយាយអំពីមន្ទីរស-២១

ក្រោយពីបានដឹងនូវអ្វីដែលទាក់ទងនឹង "ស្ថាប័នស្វ័យត" មួយ ពោលគឺមន្ទីរស-២១ដែលចងក្រងឯកសារទាក់ទិននឹងអំពើគួរឲ្យព្រឺព្រួចនិងប្រវត្តិសាស្ត្រសម្រាប់បម្រើរបបមួយដែលសាហាវនិងគួរឲ្យស្អប់ខ្ពើម តើយើងត្រូវយកមកពន្យល់ឬបរិយាយយ៉ាងណាដើម្បីឲ្យមានផលប្រយោជន៍ចំពោះអ្នកដែលនៅរស់រានមានជីវិត អ្នកប្រវត្តិសាស្ត្រ និងអ្នកអានទូទៅ?

ចម្លើយគឺមាននៅក្នុងជំពូកនេះតែម្តង ។ ដោយប្រកាន់យកនូវគំនិតមិនលម្អៀងទៅលើអ្វីដែលកើតឡើងនៅមន្ទីរស-២១ ខ្ញុំមិនចង់បង្រួញអំពើឃោរឃៅដែលធ្វើឡើងនៅក្នុងគុក ឬបទឧក្រិដ្ឋរបស់មជ្ឈិមបក្សឡើយ ។ ជំពូកមុនៗបានចងក្រងឬបកស្រាយនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ ។ ប៉ុន្តែរឿងដែលត្រូវយល់ដឹងអំពីមន្ទីរស-២១មានច្រើនជាងការបដិសេធថាវាជារឿងអាក្រក់ ។ ការព្យាយាមស្វែងយល់អំពីអ្វីដែលកើតឡើងនៅទីនោះ "តើកើតឡើងយ៉ាងដូចម្តេចនិងហេតុអ្វី" វាមានសារប្រយោជន៍ជាងការវិនិច្ឆ័យថាល្អអាក្រក់ភ្លាមៗ ។




**សម្លេងពីមន្ទីរ ស-២១**
**ជំពូកទី៦: បរិយាយអំពីមន្ទីរស-២១**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

អ្នកនិពន្ធភាគច្រើនបានធ្វើការប្រៀបធៀបមន្ទីរស-២១ទៅនឹងជំរំមរណៈណាហ្ស៊ី នៅក្នុងសង្គ្រាមលោកលើកទី២ ។ អ្នកនិពន្ធដែលបានពិនិត្យជំរំណាហ្ស៊ី បានបញ្ជាក់នូវវប្បធម៌នៃការគោរពបញ្ជាដែលបានជះឥទ្ធិពលដល់ស្ថាប័នស្វ័យតនានា និងបង្ហាញពីការបំបាត់ភាពជាមនុស្សដែលកើតឡើងទាំងចំពោះជនដៃដល់និងជនរងគ្រោះ ។ ការសិក្សាអំពីការសម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វ ក៏នាំយើងឲ្យយល់អំពីភាពមិនអើពើដែលពួកណាហ្ស៊ីក៏ដូចជាជនជាតិកម្ពុជាបង្ហាញដល់ជនរងគ្រោះរបស់ផងខ្លួន ហើយមានករណីខ្លះអ្នកទាំងនោះសម្តែងចេញនូវសេចក្តីរីករាយដែលបានមកពីការបង្កការឈឺចាប់ទៅលើអ្នកដទៃ ។ ភាពឥតមេត្តាធ្វើឡើងចំពោះ"អ្នកមានកំហុស" និងការសប្បាយដែលបានមកពីការធ្វើឲ្យអ្នកដទៃឈឺចាប់ គឺបង្ហាញចេញតាមរយៈចៅក្រមនៅទីក្រុងមូស្គូដែលចូលរួមនៅក្នុងតុលាការជម្រះក្តីធ្វើឲ្យតែល្អមើលក្នុងទសវត្សរ៍ឆ្នាំ១៩៣០ ការសម្លាប់រង្គាលនៅប្រទេសឥណ្ឌូណេស៊ីនៅឆ្នាំ១៩៦៥ និង១៩៦៦ អ្នកធ្វើទារុណកម្មយោធានៅប្រទេសអាហ្សង់ទីន និងអ្នកដែលរៀបចំការសម្លាប់នៅបូស្នៀនិងរ៉្វាន់ដាក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ។ ដូច្នេះមន្ទីរ ស-២១ មិនមែនជាអ្វីដែលថ្មីមានតែមួយនោះទេ ។

ទោះបីជាយ៉ាងនេះក្តី នៅពេលយើងកកាយឯកសាររបស់គុកនេះ យើងបានប្រទះភាពគួរឲ្យព្រឺព្រួចយ៉ាងច្រើនលើសលប់ ។ យើងរកនិយាយអ្វីក៏មិនចេញ ។ ប្រវត្តិវិទូជនជាតិបារាំងម្នាក់ឈ្មោះ អាឡាំងហ្វ័ររ៉េស ដែលបានចូលមកទស្សនាសារមន្ទីរនេះនៅឆ្នាំ១៩៨២ បានសរសេរថា "ខ្ញុំទទួលអារម្មណ៍មិនបានទាល់តែសោះ ហើយគ្មានឱកាសថានឹងគិតដល់ឬសរសេរអំពីរឿងនេះឡើយ ។ ខ្ញុំហួសចិត្តនឹងរកពាក្យអ្វីមកនិយាយបាន" ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៣០ លោក បូរីស ប៉ាស្ទ័រណាក បានទៅទស្សនាកសិដ្ឋានសហករណ៍នៅអតីតសហភាពសូវៀត ដែលនៅទីនោះមានមនុស្សរាប់ពាន់នាក់បានស្លាប់បាត់បង់ជីវិតដោយសារការអត់ឃ្លាន ។ ប៉ាស្ទ័រណាក បាននិយាយថា "អ្វីដែលខ្ញុំបានឃើញ មិនអាចរកពាក្យអ្វីមកនិយាយបានទេ ។ ដោយសាររឿងនេះមានភាពអមនុស្សធម៌និងទុក្ខសោកមិនអាចនឹកស្មានដល់យ៉ាងដូច្នេះ ធ្វើឲ្យមានអារម្មណ៍ថាគ្រោះគួរឲ្យរន្ធត់នេះហាក់ក្លាយ

ជារឿងអរូបិយគ្មានសតិសម្បជញ្ញៈ ។ នៅពេលនោះខ្ញុំចង់ឈឺតែម្តង» ។

នៅពេលយើងជួបប្រវត្តិជាច្រើនដែលផុតរលត់អស់ហើយនេះ យើងចាំបាច់ត្រូវតែនិយាយអ្វីដែលត្រឹមត្រូវជាក់ស្តែងជាមួយនឹងមន្ទីរស-២១និងជាភ័ស្តុតាងសម្រាប់ជនរងគ្រោះ ។ ប៉ុន្តែ ចូណាថាន ស្ពិន បានរំឭកយើងដោយមើលពីជ្រុងម្ខាងទៀតថា «នេះជាសោកនាដកម្មមួយក្នុងការសរសេរអំពីសោកនាដកម្មដែលទម្ងន់និងការរៀបចំស្រេះពាក្យមានបញ្ហាយ៉ាងខ្លាំងដោយសារការឈឺចាប់ ត្រូវការថ្លឹងថ្លែងតាមពាក្យពេចន៍ឲ្យបានសមរម្យចំពោះអ្នកដទៃ» ។ ក្នុងន័យម្យ៉ាង កិច្ចខិតខំប្រឹងប្រែងរបស់ ម៉ៃ ឡាំ ក្នុងការប្រែក្លាយមន្ទីរស-២១ឲ្យក្លាយជាសារមន្ទីរ គឺជាការប៉ុនប៉ងធ្វើឲ្យមន្ទីរនេះក្លាយជាកន្លែងផ្ទុកទៅដោយភាពគួរឲ្យព្រឺព្រួចពិតៗសម្រាប់អ្នកដទៃទស្សនា ។ ផែនទីក្បាលខ្មោចដាក់តាំងនៅមន្ទីរស-២១ដែល ម៉ៃ ឡាំ ជាអ្នករៀបចំផ្ទាល់មានលក្ខណៈអាក្រក់ក្រៃណាស់រហូតដល់ធ្វើឲ្យយើងឃ្លាតកាន់តែឆ្ងាយពីគុកនេះ ។ ដូចគ្នានេះដែរ ចេតិយដែល ម៉ៃ ឡាំ សង់ជិតនួសនៅជើងឯក វាផ្ទុយនឹងការបកស្រាយតាមធម៌ព្រះពុទ្ធចំពោះលលាដ៍ក្បាលដែលដាក់តាំងនៅក្នុងចេតិយនោះ ។ គ្រប់រឿងដែលយើងនិយាយឬសរសេរអំពីមន្ទីរស-២១ ឬអំពីសារមន្ទីរហាយនភាព គឺមានខ្លឹមសារងាយយល់ និងត្រឹមត្រូវទៅនឹងអ្វីដែលបានកើតឡើងកន្លងមក ។ វាជារឿងច្រំដែលៗនិងនិយាយតែអំពីភាពឃោរឃៅនៅមន្ទីរស-២១ និងសារមន្ទីររបស់ ម៉ៃ ឡាំ ដែលមិនខុសគ្នានឹងការនិយាយអំពីកន្លែងនិងពេលវេលាផ្សេងទៀតដែលគេយកមកប្រៀបប្រដូចជាមួយនឹងមន្ទីរស-២១នោះឡើយ ។ យើងក៏មិនដឹងនិយាយយ៉ាងម៉េចដែរពីព្រោះ ដូឌីត សក្លា បានសរសេរថា «យើងនិយាយកុងកេវតែពីរឿងឃោរឃៅ ពីព្រោះយើងមិនដឹងនិយាយយ៉ាងម៉េច» ។

ដូច្នេះតើហេតុអ្វីបានជាយើងនៅតែពុះពារតស៊ូពីរឿងនេះ? តើវាមានសារប្រយោជន៍នាំយើងឲ្យខិតកាន់តែជិតនិងកាន់តែស្គាល់ច្បាស់នូវភាពគួរឲ្យព្រឺព្រួចនៅមន្ទីរស-២១ឬ? ប្រសិនបើយ៉ាងដូច្នេះមែន តើក្រៅពីអ្នកអានរបស់ខ្ញុំនិងរូបខ្ញុំផ្ទាល់ អ្នកណាជាអ្នកទទួលផលប្រយោជន៍? ជានិច្ចកាល ប្រវត្តិវិទូតែងតែលូកដៃលូកជើងចូលមក ។ ខ្ញុំសរសេរជំពូកនេះក្នុងខណៈពេលដែលខ្ញុំជាអ្នកទស្សនាមន្ទីរស-២១ដោយគ្មានការអញ្ជើញ ។ ខ្ញុំបាននាំមកនូវភ័ស្តុតាងដែលបានមកពីជនរងគ្រោះនិងអ្នកធ្វើបាបជនរងគ្រោះនៅក្នុងគុកផ្ទាល់ ។ នៅក្នុងឯកសារនេះ ខ្ញុំរៀបរាប់«ជុំវិញភាពឃោរឃៅ» ហើយនេះគឺជាការអនុវត្តជាក់ស្តែងប្រកបដោយគ្រោះថ្នាក់ ដូចលោក សក្លា បានសង្កត់ធ្ងន់ថា «ទោះជាទ្រព្យសម្បត្តិ បទពិសោធន៍ខាងប្រវត្តិសាស្ត្ររបស់យើងមានច្រើនប៉ុនណាក៏ដោយ ក៏យើងមិនអាចដឹងថាតើត្រូវគិតយ៉ាងម៉េចដែរអំពីភាពជាអ្នករងគ្រោះនេះ ។ ស្ទើរតែគ្រប់ចំណុចទាំងអស់គេអាចនិយាយបានថា វាជារឿងមិនយុត្តិធម៌បម្រើឲ្យផលប្រយោជន៍ផ្ទាល់ខ្លួន មិនថ្លៃថ្នូរ មិនពិតក្បត់ខ្លួនឯង មានភាពផ្ទុយគ្នាឬមានគ្រោះថ្នាក់ ។ ដូច្នេះការ







ឆ្លើយតបតាមបែបអ្នកសិក្សាជាន់ខ្ពស់ គឺត្រូវសរសេរប្រវត្តិសាស្ត្ររបស់ជនរងគ្រោះនិងអ្នកធ្វើបាបជនរងគ្រោះឲ្យបានត្រឹមត្រូវតាមខ្លឹមសារពិតតាមតែអាចធ្វើទៅបាន...» ។

នៅក្នុងស្នាដៃនិពន្ធរបស់ខ្ញុំនេះ ខ្ញុំបានព្យាយាមអស់ពីសមត្ថភាពក្នុងការដើរតាមការណែនាំដ៏ល្អរបស់ សក្វា ធ្វើយ៉ាងណាបញ្ជាក់ជាកសិណដល់ជនរងគ្រោះ ក្តោបនូវអ្វីដែលនាំឲ្យមន្ទីរ ស-២១ កើតឡើង និងគិតពិចារណាអំពីអ្វីដែលនាំឲ្យស្ថាប័នប្រហាក់ប្រហែលគ្នានេះកើតឡើងក្នុងអតីតកាល និងដែលអាចកើតឡើងសាជាថ្មី ។ ដើម្បីធ្វើកិច្ចការនេះបាន ខ្ញុំត្រូវតែពុះពារជម្នះរាល់ការរួញរាស្ទាក់ស្ទើរមិនហ៊ានចូលទៅជិត ការរួញរាមិនហ៊ានចូលរួមទទួលខុសត្រូវនូវអ្វីដែលបានកើតឡើង និងការចង់រក្សានូវតុល្យភាពឲ្យដល់កម្រិត ។ ខ្ញុំចាំបាច់ត្រូវព្យាយាមរកពាក្យអ្វីឲ្យសម ប៉ុន្តែអ្វីដែលបានកើតឡើងនៅក្នុងគុកនោះ វាពិតជាមានទម្ងន់ខ្លាំងជាងពាក្យដែលយកមកប្រើទៅទៀត ។ ក្នុងនាមជាប្រវត្តិវិទូនិងជានិស្សិតផ្នែកអក្សរសាស្ត្រ ខ្ញុំបានព្យាយាមអស់ជាច្រើនឆ្នាំក្នុងការគ្រប់គ្រងទិន្នន័យដែលខ្ញុំយកមកសរសេរ ហើយស្វែងយល់នូវរាល់សំណេរដែលខ្ញុំបានអាន ។ នៅពេលដែលខ្ញុំជ្រមុជខ្លួនចូលទៅក្នុងបណ្ណសារមន្ទីរ ស-២១ ភាពព្រឺព្រួចដែលសំងំលាក់ខ្លួននៅខាងក្នុងបានធ្វើឲ្យខ្ញុំទៅនេះបន្តិចទៅនោះបន្តិច ធ្វើឲ្យជំនាញផ្ទាល់ខ្លួនរបស់ខ្ញុំរេចរឹល និងធ្វើឲ្យខ្សោះដល់ការទុកចិត្តរបស់ខ្ញុំ ។ បទពិសោធន៍កាលនោះគឺត្រូវលិចលង់អស់ហើយ ។

ម៉ាសេឡូ ស៊ូរ៉េ អូរ៉ូស្កូ ដែលបានសរសេរប្រធានបទនៃអំពើឃោរឃៅនៅប្រទេសអាហ្សង់ទីននៅទសវត្សរ៍ឆ្នាំ១៩៧០ បានលើកឡើងអំពីបុគ្គលដែលមានការស្ទាក់ស្ទើរក្នុងការប្រឈមមុខនិងវិភាគលើបាតុភូតនេះ ។ លោកបានសរសេរថា ជនកំសាកទាំងនេះបានអះអាងថា «ឯកសារទាំងនេះគួរឲ្យខ្លាចណាស់ មិនអាចធ្វើការវិភាគដោយគ្មានភាពលម្អៀងបានទេ ។ រាល់ការប៉ុនប៉ងក្នុងការវិភាគឯកសារនេះ នឹងរំលោភដល់ប្រធានបទដ៏ធំនិងស្មុគ្រស្មាញនេះមិនខាន ។ នៅចុងបញ្ចប់ ការវិភាគបង្កើតសាជាថ្មីនូវអំពើឃោរឃៅតាមវោហារស័ព្ទផ្សេងទៀត» ។ ស៊ូរ៉េ អូរ៉ូស្កូ ទាញសេចក្តីសំអាងទៀតថា ការវិភាគទៅលើភាពគួរឲ្យព្រឺព្រួចត្រូវតែបន្តទៅមុខ ទោះបីជាឯកសារទាក់ទងនឹងប្រធានបទនេះ«ខុះនូវទំនុកចិត្តថាវានឹងឃ្លាតចាកពីភាពព្រឺព្រួចពិតប្រាកដ»យ៉ាងណាក៏ដោយចុះ ។ នេះមិនមែនដោយសារការយល់នូវអ្វីដែលបានកើតឡើងនេះ ធ្វើឲ្យយើងអត់ឱនទោសឲ្យជនដៃដល់ទេ ប៉ុន្តែគឺដោយសារ«ភាពព្រឺព្រួចគឺជាផ្នែកមួយនៃជីវិតរស់នៅប្រចាំថ្ងៃ» ។ លោកមានប្រសាសន៍ថា នៅពេលប្រឈមមុខនឹងភាពព្រឺព្រួចនេះ យើងកំពុងតែប្រឈមមុខនឹងអ្វីដែលមិនត្រឹមតែមាន«នៅទីនោះ»ទេ តែក៏មាននៅក្នុងខ្លួនរបស់យើងដែរ ។ មន្ទីរស-២១នៅជិតយើងជាងយើងគិត ។ ហេតុនេះទន្ទឹមពេលនៃការព្យាយាមសរសេរប្រវត្តិសាស្ត្រកន្លែងនេះឲ្យ«ត្រូវតាមសភាពពិតតាមតែអាចធ្វើទៅបាន» ខ្ញុំបានព្យាយាមស្វែងរកពត៌មានទាក់ទងនឹង«ភាពធម្មតា»ដែលលោក ស៊ូរ៉េ អូរ៉ូស បានលើកឡើងនេះ ។ ប្រសិនបើ«មន្ទីរស-២១»មាននៅគ្រប់ទីកន្លែង ហើយយើងនៅក្នុងនោះដែរ ពិតជាវីវរជាមិនខាន ប៉ុន្តែវាងាយស្រួលក្នុងការពន្យល់ឲ្យបានក្បោះក្បាយ ។

នៅឆ្នាំ១៩៧១ អ្នកសារពត៌មានជនជាតិអង់គ្លេសម្នាក់ឈ្មោះ ហ្គីតា សឺរីនី បានចំណាយពេលជាច្រើនសប្តាហ៍ធ្វើកិច្ចសម្ភាសន៍ជាមួយឧត្តមសេនីយ៍ឯកម្នាក់ដែលគ្រប់គ្រងជំរំមរណៈនៅត្រេប្លីងកា ។ នៅទីនោះមានមនុស្សជាង១លាននាក់ដែលភាគច្រើនជាជនជាតិជ្វីហ្វ ត្រូវបានសម្លាប់ចាប់ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤៣ ។ ស្តាងហ្គល ត្រូវចាប់ខ្លួននៅឆ្នាំ១៩៦៧ នៅប្រទេសប្រេស៊ីល ដែលនៅក្នុងប្រទេសនោះ គាត់រស់នៅក្រោមឈ្មោះពិតរបស់គាត់ ពោលគឺគាត់មិនបានដូរឈ្មោះថ្មីទេ ។ នៅពេលដែល សឺរីនី និយាយជាមួយ ស្តាងហ្គល, ស្តាងហ្គល ត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិតរួចហើយនៅឌូសេលដូហ្វ ពីបទបានធ្វើសកម្មភាពនៅក្នុងសង្គ្រាមលោកលើកទី២ ។ ស្តាងហ្គលបានស្លាប់បាត់បង់ជីវិតនៅក្នុងគុកនាឆ្នាំ១៩៧២ ដោយសារជំងឺគាំងបេះដូង ក្រោយពេលដែល សឺរីនី សម្ភាសន៍ គាត់រួចនិងមុនពេលនាងចេញផ្សាយសៀវភៅនេះ ។

នៅក្នុងកិច្ចសម្ភាសន៍ ស្តាងហ្គល បានខ្នះខ្នែងជួយនិងរៀបរាប់ប្រៀបធៀបពីការចិញ្ចឹមបីបាច់របស់កាតូលិកនិងកិត្តិយសរបស់ខ្លួនឯងដែលធ្លាប់ធ្វើជាប៉ូលិស ជាមួយនឹងអ្វីដែល

គាត់បានឃើញនិងបានធ្វើនៅក្នុងសង្គ្រាមលោកលើកទី២ ។ សឺរីនី គួរសមជាមួយគាត់ណាស់ ប៉ុន្តែព្យាយាមស្រង់យកព័ត៌មានពីគាត់អស់ពីសមត្ថភាពដែលអាចធ្វើទៅបាន ។ នៅពេលសួរចំណុចថា ហេតុអ្វីបានជាណាហ្ស៊ីសម្លាប់ជនជាតិជ្វីហ្វ ស្តាងហ្គល ឆ្លើយថា ពីព្រោះពួកណាហ្ស៊ី "ចង់បានលុយពីជនជាតិជ្វីហ្វ" ។ បន្ទាប់មក សឺរីនី ក៏សួរទៀតថា "ប្រសិនបើគេចង់សម្លាប់ជនជាតិជ្វីហ្វចោលទាំងអស់ តើចាំបាច់ធ្វើអំពើគួរឲ្យអាម៉ាស់និងឃោរឃៅយ៉ាងនេះធ្វើអ្វី?" ។ ស្តាងហ្គល តបវិញថា "គឺដើម្បីលត់ដំអ្នកដែលត្រូវអនុវត្តនយោបាយ ។ ដើម្បីឲ្យគេអាចធ្វើអ្វីដែលគេបានធ្វើកន្លងមកនេះ" ។

ស្តាងហ្គល បញ្ជាក់ថា ពេលវេលាចេះតែកន្លងទៅ អ្នកធ្វើការនៅទ្រឹប្លឹងកាក៏លត់ដំសម្របខ្លួនបានក្នុងការអនុវត្តភារកិច្ចដ៏គួរឲ្យព្រឺព្រួចទាំងអស់នេះ តាមរយៈការយល់ព្រមនិងការជំរុញលើកទឹកចិត្ត ហើយពេលនោះជនរងគ្រោះគ្មានន័យសម្រាប់អ្នកទាំងនេះឡើយ ហើយជាទូទៅ ជនរងគ្រោះថែមទាំងត្រូវបានចាត់ទុកថាមិនមែនជាពូជសាសន៍មួយក្នុងចំណោមមនុស្សជាតិទាំងមូលទៀតផង ។ ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរ "កូនប៉ូលិសធម្មតា" នៅវរសេនាតូចប៉ូលិសបម្រុង ស-ស ដែល គ្រីសស្តូហ្វ័រ ប្រោននីង បានលើកមករៀបរាប់ មុនដំបូងមានការប្រឆាំងជំទាស់មិនព្រមអនុវត្តអំពើបែបនេះទេ តែក្រោយមក បានសម្លាប់ស្នូលជនជាតិជ្វីហ្វរាប់ពាន់នាក់នៅប្រទេសប៉ូឡូញក្នុងឆ្នាំ១៩៤១ ។ ចំណែកឯអ្នកធ្វើការនៅមន្ទីរ ស-២១វិញ ដំណើរការតឹងតែងប្រហាក់ប្រហែលគ្នានេះត្រូវបានរឹតបន្តឹងមិនមែនត្រឹមតែដោយសារការគិតថាមាន "ខ្មាំង" គ្រប់ទីកន្លែងនៅពាសពេញប្រទេសកម្ពុជាប៉ុណ្ណោះទេ តែដោយវិន័យគ្មានមេត្តានៅមន្ទីរនេះផ្ទាល់តែម្តង ។ ប្រសិនបើអ្នកធ្វើការក្នុងគុកមិនព្រមធ្វើការប្តេជ្ញាធ្វើការឃើត ឆ្មាំនិងអ្នកសួរចម្លើយនៅមន្ទីរស-២១ប្រហែលជាក្លាយជាជនរងគ្រោះមួយរំពេច មិនដូចអ្នកធ្វើការនៅជំរំណាហ្ស៊ីទេ ។ មិនយូរប៉ុន្មាន ជនរងគ្រោះទាំងនេះទទួលរងនូវការងារជាទម្ងន់ ។ ដូចដែល គក ស្រស់ បានរំឭករឿងចាស់ថា "ខ្ញុំព្យាយាមធ្វើការយ៉ាងសកម្ម ។ បើខ្ញុំស្លាប់ក៏ស្លាប់ទៅចុះ ។ ធ្វើប៉ុណ្ណឹងដែរបើនៅតែស្លាប់ទៀតក៏ស្លាប់ចុះ វាប្រសើរជាងស្លាប់ដោយសារមិនបានធ្វើការគ្រប់គ្រាន់" ។

ចំពោះ គក ស្រស់, ស្តាងហ្គល និង "កូនប៉ូលិសធម្មតា" ដែល ប្រោននីង បានលើកឡើង សារសំខាន់នៃការធ្វើការងារបានល្អវាលុបលើអ្វីដែលអ្នកទាំងនេះបានធ្វើបាត់ទៅហើយ ។ ក្នុងនាមជានាយកទ្រឹប្លឹងកា ស្តាងហ្គល ជឿជាក់ថា គាត់បានទប់ស្កាត់មិនឲ្យមានអំពើឃោរឃៅដ៏ព្រៃផ្សៃនេះកើតឡើង តាមរយៈការធ្វើការងារយ៉ាងខ្លាំងនិងសម្របខ្លួនតាមរបៀបបញ្ជាការមិនលម្អៀង និងមានមនសិការ ។ ស្តាងហ្គល បានប្រាប់ទៅ សឺរីនី ថា "ពិតណាស់ ការគិត (ដល់អ្វីដែលកើតឡើងនៅទ្រឹប្លឹងកា) ក៏មានដែរ ។ ប៉ុន្តែខ្ញុំបានបង្ខំការគិតនេះឲ្យចេញពីក្បាលអស់ ។ ខ្ញុំគិតតែពីរឿងការងារ ធ្វើហើយធ្វើទៀតធ្វើមិនឈប់ឈរ" ។ ប៉ុន្តែ ស្តាងហ្គល និយាយថា ទោះជាយ៉ាងដូច្នេះក៏ដោយ ក៏គាត់ត្រូវការផឹកស្រាជាច្រើនកែវដែរនៅពេលយប់ ដើម្បីបំបាត់ភាពស្មុគស្មាញមុនពេលចូលដេក ។

ក្រោយយល់ស្របនឹងអ្វីដែល ស្តាងហ្គល បាននិយាយនេះ សឺរីនី បានសរសេរថា "ដើម្បីសម្រេចនូវការសម្លាប់មនុស្សរាប់លាន ទាំងស្រីទាំងប្រុស ទាំងចាស់ទាំងក្មេង ណាហ្ស៊ីបានសម្លាប់ទាំងរាងកាយនិងស្មារតីទៅលើអ្នកដែលខ្លួនសម្លាប់ អ្នកដែលធ្វើការកាប់សម្លាប់មនុស្ស អ្នកដែលដឹងថាការសម្លាប់កំពុងតែកើតឡើង ហើយក្នុងកម្រិតណាមួយនោះ...សម្លាប់ទាំងរាងកាយនិងស្មារតីមកលើយើងរាល់គ្នាតែម្តងដែលមានជីវិតនិងជាសត្វលោកមានសតិសម្បជញ្ញៈនៅគ្រានោះ" ។ យោបល់របស់ សឺរីនី បញ្ជាក់ថា ដើម្បីសម្រេចគោលដៅមនុស្សឃាតនៅទ្រឹប្លឹងកា ណាហ្ស៊ីអាចពឹងផ្អែកទៅលើការស្លាប់ខាងស្មារតីរបស់ពិភពលោកទាំងមូលតែម្តង ។ នៅក្នុងន័យប្រហាក់ប្រហែលគ្នានេះ ខ្ញុំសូមនិយាយថា យើងបង្កើតឲ្យមានសំណេរអំពីមន្ទីរ ស-២១ឡើង ពីព្រោះភាគច្រើននៃយើងទាំងអស់គ្នា ព្រងើយកន្តើយទៅនឹងបាតុភូតមានចរិតបែបនេះដែលកើតឡើងនៅឆ្ងាយពីអ្នកដទៃ ។ យើងគិតថា អំពើអាក្រក់កើតឡើងនៅគ្រប់កន្លែង ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រោននីង, សឺរីនី និងអ្នកនិពន្ធផ្សេងទៀត អះអាងថា ដោយស្ថិតនៅក្រោមសភាពធ្ងន់ធ្ងរ



គុកទួលស្លែង ឆ្នាំ១៩៧៩

ដូចជាអ្វីដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ កម្រិតប្រាំដែននៃការប្រព្រឹត្តបែបនេះមិនអាចទាញចេញជារូបភាពពិតបានឡើយ ។ ប្រ៊ីម៉ូលីវី បានសរសេរថា "តំបន់ស្រអាប់" បានបង្កើតឲ្យមានឆ្មាំនិងអ្នកទោសជាច្រើននាក់នៅអ៊ូស្វ៊ីត ។ ប្រ៊ោននីង ហៅ"តំបន់"នេះតាមទស្សនៈរបស់ជនដៃដល់ថាជា"ពិភពមិនច្បាស់លាស់មួយ ប្រកបដោយហេតុផលជំរុញសតិអារម្មណ៍ទំនាស់និងអាទិភាពចម្រុះ ជម្រើសស្មុគស្មាញនិងឱកាសនិយម សម្រាប់បម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ព្រមទាំងការសម្របខ្លួនទៅនឹងទម្លាប់មួយដែលភូតកុហកនិងបដិសេធខ្លួនឯង" ។ ក្នុងន័យម្យ៉ាង នៅមន្ទីរស-២១គ្មានតំបន់បែបនេះទេ ពីព្រោះគ្មានការសមគំនិតគ្នារវាងជនរងគ្រោះ ជនដៃដល់ និងអ្នកមកពីពិភពខាងក្រៅ ក្នុងការកសាងតំបន់នេះ ។ អ្នកទោសនៅមន្ទីរស-២១មិនអាចក្លាយជាអ្នកសួរចម្លើយឬឆ្មាំគុកក៏ពិតមែន ប៉ុន្តែបុគ្គលិកគុកនៅមន្ទីរស-២១អាចក្លាយជាអ្នកទោសមួយរំពេច ។ ក្នុងន័យនេះ ម្នាក់ៗនៅមន្ទីរស-២១សុទ្ធតែរស់នៅក្នុងតំបន់ស្រអាប់គ្រប់ពេលវេលា ។

ដើម្បីឲ្យកាន់តែស៊ីជម្រៅថែមទៀត យើងចាំបាច់ត្រូវចាំថាមនុស្សធ្វើការនៅជំរំណាហ្ស៊ីនិងមន្ទីរស-២១មិនសាហាវនិងផ្តាច់ការដូចគ្នាទេ ។ ភាគច្រើននៃអ្នកទាំងនោះមានលក្ខណៈដូចគ្នាត្រង់ថា មិនចេះអក្សរ ឬមិនសូវបានរៀនសូត្រ ។ បុរសស្ត្រីទាំងនេះត្រូវបានបង្ហាត់ឲ្យដើរតួយ៉ាងសាហាវយង់ឃ្នង ។ ពិបាកកំណត់ណាស់ថាតើការជ្រើសរើសដោយសេរី ការគាបសង្កត់ប្រហាក់ប្រហែលគ្នា ការគោរពបញ្ជា និងមហិច្ឆតា មានកម្រិតត្រឹមណាទេ នៅក្នុងអ្វីដែលគេបានធ្វើកន្លងមក ។ អ្វីដែលយើងដឹងអំពីអ្នកធ្វើការនៅមន្ទីរស-២១ ក្នុងករណីភាគច្រើនដូចដែលការសិក្សាស្រាវជ្រាវរបស់លោកប្រ៊ោននីង បញ្ជាក់ស្រាប់ គឺភាពសាមញ្ញនិងភាពគ្មានខ្លឹមសាររបស់អ្នកធ្វើការនៅក្នុងមន្ទីរ ។ ដោយស្ថិតនៅជាមួយមនុស្សដូចខ្លួនឯងដែរ និងគោរពអ្នកទទួលខុសត្រូវដោយឱនក្បាលដល់ដីអ្នកធ្វើការនៅមន្ទីរស-២១ក៏ដូចជាអ្នកទោសដែរ ត្រូវជាប់អន្ទាក់នៅក្នុងកន្លែងមួយដែលគ្មានក្តីមេត្តានិងគ្មានការអាណិតអាសូរ ។

ការស្ថិតនៅក្នុងអន្ទាក់និងការប្រព្រឹត្តអំពើយ៉ាងដូច្នេះមិនចាំបាច់តែនិយាយដល់រឿងនៅទ្រីប្លីងកា អ៊ូស្វ៊ីត ឬនៅមន្ទីរស-២១ឡើយ ។ ដំណើរការនេះត្រូវបានស្តែងចេញគួរឲ្យភ្ញាក់ផ្អើលក្រោមលក្ខខណ្ឌនៃការចេះដឹងសមរម្យនិងថ្លៃថ្នូរនៅប៉ាឡូអាល់តូ រដ្ឋកាលីហ្វ័រញ៉ា ពីរបីឆ្នាំមុនពេលមន្ទីរស-២១ចាប់ផ្តើមប្រវត្តិប្រតិបត្តិការរបស់ខ្លួន ។ នៅក្នុងការពិសោធន៍ដែលគេហៅថា ហ្ស៊ីមបាដូ នៅក្នុងឆ្នាំ១៩៧១ ក្រុមនិស្សិតបញ្ចប់ឧត្តមសិក្សាមួយក្រុមនៃសាកលវិទ្យាល័យ ស្តែនហ្វ័ដដែលសុទ្ធតែជាអ្នកស្ម័គ្រចិត្ត ត្រូវបានរៀបចំឲ្យដើរតួគ្រាប់តាមវប្បធម៌ ការអនុវត្តជាក់ស្តែង និងទំនាក់ទំនងអំណាចនៃគុកមួយរបស់អាមេរិកាំង ។ នៅខណៈពេលដែល"ឆ្មាំ"សប្បាយចិត្តនឹងការផ្តល់អំណាចមកឲ្យខ្លួន ហើយ"អ្នកទោស"មានការភ័យខ្លាចនឹងត្រូវបំបាត់ភាពជាមនុស្សចេញពីខ្លួននោះ ពិសោធន៍នេះចេះតែធ្វើទៅមុខដោយគ្មានអ្នកណាគ្រប់គ្រងបាន ។ ការសាកល្បងនេះត្រូវបានបង្រួញឲ្យខ្លីកុំឲ្យតួអង្គម្នាក់ៗមានការឈឺចាប់ទាន់ ។

**(នៅមានត)**


18



# អ្នកស្រុកអន្លង់វែងមិនជឿថា តាម៉ុក បានប្រឡាក់ប្រឡូសនឹងអំពើឧក្រិដ្ឋ

ប្រជាជនភាគច្រើននៅអន្លង់វែងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក មិនជឿសោះឡើយថា តាម៉ុក បានរួមគំនិតនិងប្រព្រឹត្តឧក្រិដ្ឋកម្មដែលបណ្តាលឲ្យប្រជាជនកម្ពុជាជាង២លាននាក់ស្លាប់បាត់បង់ជីវិត ក្នុងអំឡុងពេលដែលប្រទេសកម្ពុជាស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។

អតីតនាយទាហានផ្តាច់ខ្លួនម្នាក់ដែលធ្លាប់ធ្វើជាកងទ័ពខ្មែរក្រហមតាំងពីឆ្នាំ១៩៧០ បច្ចុប្បន្នរស់នៅស្រុកអន្លង់វែង បានទទួលស្គាល់ថា នៅក្នុងរបបខ្មែរក្រហមមានប្រជាជនស្លូតត្រង់ជាង២លាននាក់បានស្លាប់បាត់បង់ជីវិតដោយសារការចាប់យកទៅសម្លាប់ ការធ្វើទារុណកម្ម ការបង្អត់អាហារ និងការបង្ខំធ្វើពលកម្មហួសកម្លាំង ។ ក៏ប៉ុន្តែគាត់បដិសេធថា តាម៉ុក មិនបានសម្លាប់មនុស្សទេ ។

នាយទាហានរូបនោះបានអះអាងថា មនុស្សស្លាប់ជាង២លាននាក់ក្នុងរបបខ្មែរក្រហមគឺបណ្តាលមកពីខ្មាំងផ្ទៃក្នុងដែលចូលដៃចូលជើងជាមួយបរទេស ។ នៅក្នុងចំណោមកម្មាភិបាល ១០នាក់ មានខ្មាំងផ្ទៃក្នុងចំនួន៧នាក់ ។ ខ្មាំងផ្ទៃក្នុងតែងតែបំភ្លៃមាគ៌ារបស់អង្គការ ។ អង្គការបញ្ជាឲ្យយកប្រជាជនទៅអប់រំកសាង រៀនសូត្រ ក៏ប៉ុន្តែខ្មាំងបានយកប្រជាជនទៅសម្លាប់ចោល ។

នៅឆ្នាំ១៩៩៧ នាយទាហានរូបនោះធ្លាប់បានឮ ប៉ុល ពត និយាយប្រាប់អ្នកកាសែតអំពីការស្លាប់របស់ប្រជាជនកម្ពុជានៅក្នុងអំឡុងពេលរបបខ្មែរក្រហម ។ ប៉ុល ពត បានទទួលស្គាល់ថា នៅក្នុងសម័យកសាង (របបខ្មែរក្រហម) គាត់បានសម្លាប់ទាហាននិងមន្ត្រីរបស់ លន់ ណុល ចំនួន៣ម៉ឺននាក់ និងមានបញ្ជីឈ្មោះកម្ទេចថែមទៀត ។ បញ្ជីឈ្មោះទាហាននិងមន្ត្រីរបស់ លន់ ណុល ដែលបានកម្ទេចរួចហើយនោះ ប៉ុល ពត បានរក្សាទុករហូតដល់ឆ្នាំ១៩៩៨ ។ បន្ទាប់ពី ប៉ុល ពត ស្លាប់ បញ្ជីនោះត្រូវបានទាហានរបស់ប៉ុលពតដុតបំផ្លាញចោល ។ ចំពោះការស្លាប់ប្រជាជនរហូតដល់ជាង២លាននាក់ ប៉ុល ពត បានទម្លាក់កំហុសទៅលើខ្មាំងផ្ទៃក្នុងដែលបានចូលដៃចូលជើងជាមួយបរទេស ។

ប្រជាជនរស់នៅអន្លង់វែងដែលធ្លាប់រស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក មានការគោរពស្រឡាញ់និងតែងតែហៅ តាម៉ុក ថា «តា» ។ អ៊ួន វ៉ន ដែលត្រូវជាក្មួយប្រុសរបស់ តាម៉ុក សព្វថ្ងៃរស់នៅភាគខាងជើងទីរួមស្រុកអន្លង់វែង បាននិយាយថា «ខ្ញុំមិនជឿថាតាបានសម្លាប់មនុស្សទេ» ។

អ៊ួន វ៉ន បានបន្តថា តាម៉ុក តែងតែជួយសម្រួលដល់ការខ្វះខាតរបស់ប្រជាជននៅអន្លង់វែង ដូចជាផ្តល់សម្លៀកបំពាក់ មុងភួយ អង្រឹង ថ្នាំសង្កូវ និងម្ហូបអាហារ ។ នៅស្រុកអន្លង់វែង តាម៉ុក បានកសាងស្ពានបេតុងមួយកន្លែង មន្ទីរពេទ្យមួយកន្លែង សាលារៀនមួយខ្នង ទីបញ្ជាការកងទ័ពមួយកន្លែង ផ្លូវក្រាលក្រួសក្រហមចំនួន៣ខ្សែ រោងចក្រច្នៃគ្រាប់កាំភ្លើងមួយកន្លែង រោងចក្រអារឈើមួយកន្លែង និងរោងពុម្ពក្លែងក្រដាសប្រាក់រៀលមួយកន្លែង ។

តាម៉ុក ហៅ តា១៥ មានឈ្មោះដើម អ៊ុង ជឿន ឬ ឈិត ជឿន កើតនៅភូមិប្រគាប ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅមុនពេលចូលបម្រើបដិវត្តន៍ក្នុងអាយុ១៩ឆ្នាំ តាម៉ុក បានបួសនៅវត្តមហាមន្ត្រីអស់រយៈពេលជាង១០ឆ្នាំនិងចេះដឹងចប់គម្ពីរព្រះត្រៃបិដក ។

តាម៉ុក បានក្លាយជាគណៈស្រុកនៃក្រុមខ្មែរឥស្សរៈនៅខេត្តតាកែវក្នុងឆ្នាំ១៩៤៩ និងក្លាយជាសមាជិកបក្សកុម្មុយនិស្តកម្ពុជានៅឆ្នាំ១៩៦៣ ។ នៅឆ្នាំ១៩៦៨ តាម៉ុក បានទទួលនាទីជាលេខាភូមិភាគនិរតី ។ នៅខែកក្កដា ឆ្នាំ១៩៧១ តាម៉ុក

ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ តាម៉ុក ត្រូវបានចាត់តាំងជាអនុលេខាបក្សកុម្មុយនិស្តកម្ពុជា ។

នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលកម្ពុជាបានចាប់ខ្លួន តាម៉ុក ហើយឃុំឃាំងរហូតមកដល់សព្វថ្ងៃនេះ ។ បច្ចុប្បន្ននេះ តាម៉ុក កំពុងរង់ចាំតុលាការឯករាជ្យវិនិច្ឆ័យទោសនិងដាក់ទណ្ឌកម្មទៅតាមច្បាប់ពីបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

នៅមុនពេលត្រូវចាប់ខ្លួន តាម៉ុក ធ្លាប់បាននិយាយថា “នៅលើដីមានម៉ុក នៅលើម៉ុកមានមូក” ។ ក៏ប៉ុន្តែ តាម៉ុក ភ្លេចឈ្លោកមុខចុះក្រោមហើយសញ្ជឹងគិតថា នៅក្រោមបាតជើងរបស់ខ្លួនមានសុទ្ធតែរណ្តៅសាកសពមនុស្សរាប់សែននាក់ដែលបានស្លាប់ក្រោមស្នាដៃនិងខួរក្បាលរបស់ខ្លួន ហើយនៅលើក្បាលរបស់ តាម៉ុក គឺមានច្បាប់ ។

ក្រៅអំពី តាម៉ុក នៅមានមេខ្មែរក្រហមជាច្រើននាក់ទៀតដែលកំពុងបន្តចំអកដល់ប្រជាជនកម្ពុជាដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម ។ នួន ជា ដែលជាបងធំទីពីរ ធ្លាប់បាននិយាយថា “តើខ្ញុំសមជាឃាតករដែរឬទេ?” ។ នៅក្នុងសំបុត្រចំហជូនជនរួមជាតិកាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ខៀវ សំផន អតីតប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យបានអះអាងថា “ខ្ញុំគ្មានតួនាទីអ្វីទាំងអស់ទៅសួរបញ្ជាក់ពីរឿងកាប់សម្លាប់មនុស្ស ។ រឿងទាំងអស់នោះស្ថិតនៅលើដៃ ប៉ុល ពត, នួន ជា និង សុន សេន” ។

ចំណែកឯ អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងសកម្មភាពធិការ និងជាសមាជិកបម្រុងមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាបាននិយាយនៅក្នុងលិខិតតវ៉ាមួយច្បាប់ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៩៩ ថា “ក្នុងនាមជាអ្នកស្នេហាជាតិមួយរូប ខ្ញុំនៅតែគោរពនូវការលះបង់ដ៏ខ្ពង់ខ្ពស់និងគ្មានអ្វីប្រៀបបានរបស់អ្នកទាំងនោះ ទោះបីជាគេ (ខ្មែរក្រហម) ស្លាប់ឬក៏នៅរស់ក៏ដោយ ។ បើគ្មានពួកនោះ (ខ្មែរក្រហម) ប្រទេសកម្ពុជានឹងរលាយបាត់ពីពិភពលោក” ។

ការនិយាយបែបនេះបានបង្កការឈឺចាប់ដល់ជនរងគ្រោះនិងភាពអយុត្តិធម៌យ៉ាងធ្ងន់ធ្ងរចំពោះព្រលឹងជនរងគ្រោះស្លូតត្រង់ដែលបានបាត់បង់ជីវិតនៅក្រោមការដឹកនាំរបស់ខ្មែរក្រហមនិងចំពោះការពិតនៃប្រវត្តិសាស្ត្រ ។

ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ ឡាយព្រះហស្តលេខានៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ។ អស់រយៈពេលជាង២៣ឆ្នាំហើយដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំយុត្តិធម៌ តើច្បាប់នឹងដោះស្រាយយ៉ាងណាចំពោះករណីរបស់ តាម៉ុក និង មេដឹកនាំខ្មែរក្រហមដទៃទៀត ។

អ៊ួន វ៉ន ដែលសព្វថ្ងៃកំពុងព្រួយបារម្ភអំពីសុខភាពរបស់ តាម៉ុក បានទទូចសុំឲ្យមានតុលាការឯករាជ្យដើម្បីជំនុំជម្រះក្តី តាម៉ុក ។ គាត់បាននិយាយថា “ខ្ញុំចង់ឲ្យច្បាប់កាត់ទោសគាត់ បើសឲ្យឃើញស បើខ្មៅឲ្យឃើញខ្មៅ” ។ អ៊ួន វ៉ន បន្តទៀតថា ប្រសិនបើគាត់មានសោហ៊ុយសម្រាប់ធ្វើដំណើរ គាត់នឹងមកសួរសុខទុក្ខ តាម៉ុក នៅភ្នំពេញ ទោះជាមិនសង្ឃឹមថាប៉ូលិសអនុញ្ញាតឲ្យគាត់ចូលជួបក៏ដោយ ។

ការបន្តឃុំខ្លួន តាម៉ុក អូសបន្លាយពេលវេលាដ៏យូរអង្វែងដោយគ្មានការជំនុំជម្រះក្តី បានធ្វើឲ្យមានការចោទជាសំណួរថា តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់ប្រជាជនកម្ពុជានិងមនុស្សជាតិទាំងមូល? តើនរណាជាឃាតករពិតប្រាកដ ដែលបានសម្លាប់ប្រជាជនកម្ពុជាស្លូតត្រង់អស់ប្រមាណ២លាននាក់?

**ហ៊ុយ វណ្ណៈ**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្តី«ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥)(២៣)២១១៨៧៥
ទូរសារលេខ: (៨៥៥)(២៣)២១០៣៥៨
Email: dccam@bigpond.com.kh

# អប់រំកុមារបដិ

## ស្រុកត្រាំកក់ ខេត្តតាកែវ





ស្រុកត្រាំកក់គឺជាស្រុកមួយស្ថិតក្នុងខេត្តតាកែវ តំបន់១៣ ភូមិភាគនិរតី ។ នៅក្នុងសៀវភៅភូមិសាស្ត្រថ្នាក់ទី៧ដែលបោះពុម្ពដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៧៧ បានសរសេរថា ស្រុកត្រាំកក់មាន១៤ឃុំ និងក្លាយជាមូលដ្ឋានបដិវត្តន៍មុនគេក្នុងខេត្តតាកែវ គឺនៅភូមិត្រពាំងធំ (ឃុំត្រពាំងធំ) ភូមិជាងទង (ឃុំជាងទង) និងលើភ្នំជីរមៀល ។ ស្រុកត្រាំកក់មានជួរភ្នំជីរមៀលដែលមានព្រៃជុំជិតដាច់ឆ្ងាយពីទីប្រជុំជន ងាយស្រួលដល់ការលាក់ខ្លួនធ្វើការពង្រឹងកម្លាំងរបស់បដិវត្តន៍ខ្មែរក្រហម ។ ម្យ៉ាងទៀត ប្រជាជនភាគច្រើនជាកសិករដែលតែងជួបប្រទះការលំបាកចំពោះបញ្ហាជីវភាព ។ ដូច្នេះហើយ នៅពេលដែលមានការឃោសនារបស់ក្រុមអ្នកតស៊ូខ្មែរក្រហមថា ត្រូវបំបាត់វណ្ណៈជិះជាន់ បំបាត់មិនឲ្យមានអ្នកមានអ្នកក្រ ប្រជាជនទាំងអស់នឹងរស់នៅដោយស្មើគ្នា ហើយនិងលើកស្ទួយវណ្ណៈកសិករក្រីក្រនោះ បានធ្វើឲ្យប្រជាជនជាច្រើនក្នុងស្រុកត្រាំកក់ចូលរួមបម្រើចលនាបដិវត្តន៍ ទាំងកម្លាំងកាយ កម្លាំងចិត្តនិងទ្រព្យធន ។

ដោយសារលក្ខណៈភូមិសាស្ត្រអំណោយផល រួមជាមួយប្រជាជនងាយស្រួលទាក់ទាញ ស្រុកត្រាំកក់មួយភាគធំត្រូវខ្មែរក្រហមកាន់កាប់តាំងពីឆ្នាំ១៩៧០ ។ នៅពេលនោះខ្មែរក្រហមបានរៀបចំការសិក្សាសម្រាប់កុមារជាបណ្តើរៗ ។

ថ្វីដ្បិតតែកុមារមួយចំនួនក្នុងស្រុកត្រាំកក់បានទទួលការសិក្សាជាបណ្តើរៗតាំងពីឆ្នាំ១៩៧០ ក៏ប៉ុន្តែរហូតដល់អំឡុងឆ្នាំ ១៩៧៣-៧៤ ទើបមានការបង្កើតឡើងនូវគណៈសិក្សាស្រុកត្រាំកក់ នៅសម័យនោះហៅថាផ្នែកសិក្សាស្រុកឬវប្បធម៌ស្រុក ។ គណៈសិក្សាស្រុកត្រាំកក់គ្រប់គ្រងដោយ តាសារី ជាអតីតគ្រូបង្រៀននៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០និង៧០ ។

នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ មានការប្រជុំអចិន្ត្រៃយ៍ស្តីពីការគ្រប់គ្រងការសិក្សាទូទាំងប្រទេសដោយបែងចែកការងារ សមមិត្តអនុលេខា នួន ជា ទទួលបន្ទុកការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការនិងសិក្សាធិការ សមមិត្តនារី អៀង ធិរិទ្ធ ហៅ ភា ក៏ទទួលបន្ទុកផ្នែកសង្គមកិច្ចនិងការសិក្សាដែរ (ដែលសម័យនោះហៅផ្នែកវប្បធម៌) ។ ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣

ខែមេសា ឆ្នាំ១៩៧៦ អង្គប្រជុំសន្និបាតលើកទី១របស់សភាតំណាងប្រជាជនកម្ពុជា បានជ្រើសរើសសមាជិករដ្ឋាភិបាលថ្មី ដោយតែងតាំងសមមិត្តនារី យុន យ៉ាត (ប្រពន្ធរបស់ សុន សេន) ជារដ្ឋមន្ត្រីក្រសួងវប្បធម៌អប់រំនិងសិក្សាធិការ ។

នៅក្នុងឯកសារស្តីអំពី "ពិនិត្យ ក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារនិងរៀបចំកសាងប្រទេសគ្រប់ផ្នែក" ដែលធ្វើឡើងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ បានចែងថា វិស័យកសិកម្មគឺជាគន្លឹះធំបំផុតក្នុងការកសាងនិងការពារប្រទេស ។ ហេតុនេះទើបក្នុងទស្សនៈរបស់បដិវត្តន៍ចំពោះចំណេះដឹងបានចាត់ទុកថា "វិជ្ជាក្នុងការតស៊ូកែប្រែធម្មជាតិ បង្កបង្កើនផលនិងវិជ្ជាក្នុងការតស៊ូប្រជាជាតិនិងតស៊ូវណ្ណៈ" ជាចំណេះដឹងសំខាន់បំផុត ។ អ្នកដែលចេះវិជ្ជានេះច្បាស់លាស់និងធ្វើការងារល្អគឺប្រជាជន កម្មករ និងកសិករ ។

នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី៧ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ សមមិត្តនារី អៀង ធីរិទ្ធ បានទទួលស្គាល់ថា ការលំបាករបស់កម្មាភិបាលវ័យក្មេងក្នុងក្រសួងសង្គមកិច្ចនិងសុខាភិបាល មកពីភាពមិនចេះអក្សរនិងលេខ ។

នៅក្នុងបទថ្លែងនាមរបស់តំណាងបក្សក្នុងឱកាសអបអរសាទរខួបលើកទី១៧នៃកំណើតបក្សកុម្មុយនិស្តកម្ពុជាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៧ បាននិយាយថា ការសិក្សាកាលពីសង្គមចាស់ចម្លងតាមបរទេស ឃ្លាតពីសភាពការណ៍ជាក់ស្តែងរបស់សង្គមខ្មែរ មិនអាចយកមកបម្រើការងារកសាងការពារប្រទេសបានទេ ហើយនៅតែពឹងផ្អែកនិងរណបបរទេសមិនចេះចប់ ។ ដើម្បីបម្រើចលនាការពារនិងកសាងប្រទេសឲ្យបានឆាប់រហ័ស ការសិក្សា គឺត្រូវរៀនបណ្តើរអនុវត្តបណ្តើរ ដកបទពិសោធន៍បច្ចេកទេសបណ្តើរ ។ រៀនទ្រឹស្តីភ្ជាប់នឹងការអនុវត្តន៍ជាក់ស្តែង រៀនភ្ជាប់នឹងពលកម្មនិងការបង្កបង្កើនផល ។ រៀនវប្បធម៌ផងរៀនបច្ចេកទេសផងហើយចំណេះនេះគឺរៀនមកពីសាលាជាក់ស្តែងនៅតាមសហករណ៍និងរោងចក្រ ។ ទិសដៅសំខាន់ចំពោះមុខគឺបំបាត់ភាពមិនចេះអក្សរ និងពង្រីកខាងបច្ចេកទេសវិទ្យាសាស្ត្រដែលរួមមាន បច្ចេកទេសកសិកម្ម ស្រូវ កៅស៊ូ បច្ចេកទេសឧស្សាហកម្ម និងកសាងប្រព័ន្ធសំណង់ចែកចាយទឹក ។

នៅក្នុងគម្រោងកិច្ចដំណើរការវប្បធម៌អប់រំសិក្សាធិការវិទ្យាសាស្ត្រ បានកំណត់តម្រង់ទិសក្នុងការសិក្សា គឺដើម្បីបម្រើសេចក្តីត្រូវការចំពោះមុខ និងបម្រើខាងផលិតកម្មសម្ភារភាពជីវភាពប្រជាជន និងកិច្ចការពារប្រទេស ។

## ការសិក្សាអក្សរនិងលេខ

ការសិក្សាក្នុងស្រុកត្រាំកក់នៅក្រោមការគ្រប់គ្រងរបស់ចលនាតស៊ូ"ខ្មែរក្រហម" បានចាប់ផ្តើមបណ្តើរៗនៅឆ្នាំ១៩៧០ ប៉ុន្តែមិនទាន់រៀបចំជាទូទៅនៅឡើយទេ ។ មានតំបន់មួយចំនួនស្ថិតនៅក្រោមការកាន់កាប់របស់របបសាធារណរដ្ឋខ្មែរនៅឡើយ ហើយតំបន់ខ្លះទៀតមានសង្គ្រាមធ្ងន់ធ្ងរមិនអាចបង្កលក្ខណៈងាយស្រួលដល់ការរៀនសូត្ររបស់កុមារ ។ កុមាររៀនសូត្រពុំសូវបានជាប់លាប់ទេ ពីព្រោះពេលនោះកំពុងតែមានសង្គ្រាម ហើយកុមារត្រូវរត់គេចពីគ្រាប់ផ្លោងនិងគ្រាប់បែកទម្លាក់ពីយន្តហោះ ។

នៅក្នុងស្រុកត្រាំកក់មុនឆ្នាំ១៩៧៥ កុមារានិងកុមារីត្រូវរៀនជាមួយគ្នាក្នុងថ្នាក់តែមួយ ។ ចំណែកកម្មវិធីសិក្សាក៏ពុំទាន់បានរៀបចំនៅឡើយដែរ គឺគ្រូបង្រៀនទៅតាមអ្វីដែលខ្លួនចេះចាំ ។ នៅក្រោយពេលរំដោះឆ្នាំ១៩៧៥ កុមារត្រូវរស់នៅតាមកង មានកងកុមារានិងកុមារី និងត្រូវរៀនសូត្រទៅតាមកងរបស់ខ្លួន ។

## ការកំណត់អាយុរៀនសូត្រ

នៅស្រុកត្រាំកក់មានតែកុមារដែលរស់នៅក្នុងកងកុមារមានអាយុចាប់ពី៦-៧ឆ្នាំដល់១៥-១៦ឆ្នាំប៉ុណ្ណោះដែលបានរៀនសូត្រ ។ ការកំណត់អាយុកុមារឲ្យចូលរៀនគឺនៅអាយុ៦ឆ្នាំ ឬអ្នកដែលអាចយកដៃលូករំលងក្បាលទៅប៉ះនឹងត្រចៀកបាន ។ វិធីនេះ មាស សុផល្លា បានអះអាងថា ជាវិធីដែលមានតាំងពីបុរាណកាលមក ។


ហំ ហឹន

ហំ ហឹន ជាគ្រូបង្រៀនកុមារ បានរៀបរាប់ពីការសិក្សារបស់សិស្សនៅស្រុកត្រាំកក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ថា «មានតែកុមារទេដែលបានរៀនសូត្រ បើចូលដល់កងនារីអង្គការមិនឲ្យរៀនទេ ពីព្រោះនាំឲ្យខាតពេល កងនារីចាត់ចូលជាកម្លាំងស្រួចដែលត្រូវធ្វើពលកម្មច្រើន» ។


សោម ណារិន

ឆ្នាំ១៩៧៥ សោម ណារិន មានអាយុ១៥ឆ្នាំ ត្រូវអង្គការរៀបចំឲ្យគាត់ទៅរស់នៅក្នុងកងយុវជន ។ ក្នុងរយៈពេលជាង៣ឆ្នាំក្រោមការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ ណារិន មិនដែលបានរៀនសូត្រឡើយ ។


ប្រាក់ កៅ

នៅឆ្នាំ១៩៧៦ ប្រាក់ កៅ ត្រូវទៅរស់នៅក្នុងកងកុមារ ប៉ុន្តែមិនបានមួយឆ្នាំផង ត្រូវប្តូរទៅកងនារីវិញ ។ ពេលចូលកងនារី កៅ មិនបានរៀនទៀតទេ ពីព្រោះគ្មានការរៀនសូត្រនៅក្នុងកងនារីនៅស្រុកត្រាំកក់ ។

## ពេលវេលានិងទីកន្លែងសិក្សា

នៅឆ្នាំ១៩៧០ នៅក្នុងភូមិរបស់ មាស សុផល្លា កុមាររៀនសូត្រនៅក្នុងខ្ទមនិងក្នុងវត្ត ដោយសារខ្លាចយន្តហោះទម្លាក់គ្រាប់បែក ។ ឌិន ឌុន ធ្លាប់បានធ្វើជាគ្រូបង្រៀនកុមារ ហើយក៏ជាអ្នកបណ្តុះបណ្តាលគ្រូសម្រាប់បង្រៀនកុមារនៅក្នុងតំបន់រំដោះតាំងពីឆ្នាំ១៩៧០ ។ នៅពេលនោះ កុមារអាចរៀនបានមួយថ្ងៃពី២ទៅ៣ម៉ោង ឬជួនកាលរៀនកន្លះថ្ងៃ។ នៅឆ្នាំ១៩៧២ ក្នុងឃុំរបស់ ឌិន ឌុន មានការទម្លាក់គ្រាប់បែកបេ-៥២ ហេតុនេះហើយកុមារទាំងអស់ត្រូវរៀនក្នុងទីកំបាំងដូចជាក្នុងព្រៃជាដើម ។ នៅក្បែរកន្លែងរៀនរបស់កុមារតែងតែមានលេណដ្ឋានសម្រាប់លាក់ខ្លួនជានិច្ច នៅពេលមានយន្តហោះទម្លាក់គ្រាប់បែកមកដល់ ។ នៅពេលណាមានការទម្លាក់គ្រាប់បែកខ្លាំង កុមារត្រូវផ្អាកការរៀនសូត្រ រហូតដល់មានភាពស្ងប់ស្ងាត់ឡើងវិញ ។

ពេលវេលានៃការរៀនសូត្ររបស់កុមារនៅមុនឆ្នាំ១៩៧៥ មិនដូចគ្នាទេ ។ នៅកន្លែងខ្លះ កុមារបានរៀនមួយថ្ងៃពី៣ទៅ៤ម៉ោង គឺពាក់កណ្តាលថ្ងៃ ឬពេលព្រឹក ឬពេលល្ងាច ។ ប៉ុន្តែនៅកន្លែងខ្លះទៀត កុមាររៀនបានតែមួយម៉ោងពេលថ្ងៃត្រង់ប៉ុណ្ណោះ ។ ការបែងចែកពេលវេលាសិក្សានេះគឺអាស្រ័យទៅលើសភាពការណ៍អនុគ្រោះ និងគ្រូបង្រៀនដែលមានពេលទំនេរអាចបង្រៀនបាន ។

តាមឯកសារ «ពិនិត្យ ក្តាប់ និងអនុវត្តន៍មាគ៌ានយោបាយស្តារសេដ្ឋកិច្ចនិងរៀបចំកសាងប្រទេសគ្រប់ផ្នែក» ដែលធ្វើឡើងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ បានកំណត់ពេលវេលាសិក្សាគឺនៅម៉ោង១២ថ្ងៃត្រង់ ។ ការសិក្សានេះត្រូវឆ្លៀតពេលមិនឲ្យប៉ះពាល់ដល់ពេលវេលាធ្វើពលកម្មបង្កបង្កើនផលឡើយ ។ នៅពេលដែលកុមារចេះអាននិងសរសេរបានគ្រាន់បើហើយ ទើបមានបន្ថែមមុខវិជ្ជាភូមិវិទ្យាប្រទេសខ្មែរមួយមុខទៀត ។

ចំពោះការសិក្សារបស់កុមារក្នុងស្រុកត្រាំកក់ ឌុល ដឹម បាននិយាយថា «ការរៀនសូត្រសំខាន់របស់កុមារគឺរៀនខាងជាក់ស្តែង រៀនធ្វើស្រែធ្វើចម្ការ និងរៀនធ្វើជីធម្មជាតិ» ។


ឌុល ដឹម

ផាត់ សមុទ្រ ជាកុមារក្នុងកង គាត់រៀនមួយថ្ងៃបានប្រហែលកន្លះម៉ោង រៀនអក្សរបានតែ២-៣តួ ។ គាត់មិនសូវយកចិត្តទុកដាក់ទេ ពីព្រោះនឿយហត់នឹងការងារ ហើយគាត់តែងគេចទៅសម្រាកដើម្បីយកកម្លាំងរែកដីពេលរសៀលទៀត ។ សួរ ចំរើន ក៏បាននិយាយដែរថា គាត់រៀនមួយថ្ងៃបានមួយម៉ោងទៅមួយម៉ោងកន្លះ រៀនសូត្រមិនសូវបានជិតដល់ទេ ។


ផាត់ សមុទ្រ

នៅក្នុងឯកសារ«សភាពការណ៍នៃការកសាងប្រទេសជាតិយើងលើគ្រប់ផ្នែកទាំងអស់»ដែលធ្វើឡើងនៅឆ្នាំ១៩៧៦បានសរសេរថាៈ ក្នុងដំណើរការនៃការសិក្សា មិនមែនប្រព្រឹត្តក្នុងសាលារៀនទេ គឺរៀនក្នុងការងារជាក់ស្តែង ចំណែកសញ្ញាប័ត្រគឺ «ស្ទូងល្អ ថែដំណាំបានល្អ» ។

ដូចជាគោលការណ៍ដែលបានចេញដែរ ទីកន្លែងសម្រាប់កុមារក្នុងស្រុកត្រាំកក់រៀនសូត្រគឺគ្មានបន្ទប់ តុ និងកៅអីត្រឹមត្រូវទេ គឺកុមារត្រូវអង្គុយផ្ទាល់ដី ។

អ៊ូច ម៉ន បាននិយាយថា សិស្សរបស់គាត់គ្មានសាលា ឬថ្នាក់សម្រាប់រៀនត្រឹមត្រូវទេ កុមារត្រូវរៀននៅក្រោមម្លប់ឈើក្បែរកន្លែងធ្វើការ ។ ផាត់ សមុទ្រ ជាកុមាររស់នៅក្នុងកងក៏បាននិយាយដែរថា ពេលរៀនគាត់ត្រូវអង្គុយនៅក្រោមម្លប់ដើមដូង ។


អ៊ូច ម៉ន

## មុខវិជ្ជាដែលត្រូវរៀន

ក្នុងការសិក្សានេះមានបោះពុម្ពសៀវភៅពុម្ពមេរៀនសម្រាប់គ្រូបង្រៀនយកទៅប្រើប្រាស់ដែរ ។ ក្នុងឯកសារដែលនៅសល់ មានសៀវភៅរៀនលេខនិងរៀនអក្សរថ្នាក់ទី១និងទី២ សៀវភៅភូមិសាស្ត្រនយោបាយថ្នាក់ទី២ និងសៀវភៅភូមិវិទ្យាមួយក្បាលទៀតដែលមិនអាចដឹងបានថាសម្រាប់សិក្សានៅថ្នាក់ទីប៉ុន្មាន ពីព្រោះដាច់ក្រប ។ ការសិក្សានេះពុំមានការប្រឡងឡើងថ្នាក់ និងប្រឡងយកសញ្ញាប័ត្រឡើយ ។

ថ្នាក់ទី១មានសៀវភៅរៀនអក្សរនិងរៀនលេខ ។ នៅក្នុងសៀវភៅរៀនអក្សរដែលបោះពុម្ពនៅឆ្នាំ១៩៧៦ដោយរបបកម្ពុជាប្រជាធិបតេយ្យ មាន១០៨ទំព័រ ចែកជា៣ផ្នែក ផ្នែកទី១មាន៨៦មេរៀន គឺរៀនអំពីស្រៈ ព្យញ្ជនៈ និងរបៀបប្រកប ផ្នែកទី២មាន១មេរៀនគឺរៀនអំពីវេយ្យាករណ៍ ផ្នែកទី៣មាន១៥មេរៀន មានមេរៀននិងកំណាព្យដែលមានទិសដៅអប់រំឲ្យកុមារស្រឡាញ់បដិវត្តន៍ គោរពស្រឡាញ់អង្គការនិងខិតខំធ្វើការងារកសិកម្ម ។ សម្រាប់ថ្នាក់ទី១នេះ ក៏មានសៀវភៅរៀនលេខដែលបោះពុម្ពដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិប-តេយ្យនៅឆ្នាំ១៩៧៦ដែរ ។ សៀវភៅរៀនលេខថ្នាក់ទី១ ភាគ១ មានកម្រាស់៥៣ទំព័រ ចែកចេញជា២២មេរៀន ដែលរៀនអំពី

កុមារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ



ចំនួនពី១ដល់១០០០០ រៀនអំពីវិធីបូកលេខនិងគុណលេខ ។

នៅថ្នាក់ទី២ មានសៀវភៅរៀនអក្សរ រៀនលេខ និង ភូមិសាស្ត្រនយោបាយ ។ ក្នុងសៀវភៅរៀនអក្សរថ្នាក់ទី២ដែល បោះពុម្ពដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យនៅ ឆ្នាំ១៩៧៧ មានកម្រាស់១៣០ទំព័រ ចែកចេញជា៥ផ្នែក គឺ ផ្នែកកសិកម្ម ផ្នែកឧស្សាហកម្មនិងសិប្បកម្ម ផ្នែកកងទ័ពបដិវត្ត ផ្នែកសង្គមកិច្ចនិងសុខាភិបាល និងផ្នែកទូទៅ ។ នៅគ្រប់ផ្នែកទាំងអស់ មេរៀនបានលើកបង្ហាញអំពីការងារក្នុងសម័យបដិវត្តតាមផ្នែកនីមួយៗ ហើយឲ្យកុមារចូលរួមធ្វើការងារទាំងអស់នោះ ។ សៀវភៅរៀនលេខថ្នាក់ទី២បោះពុម្ពក្នុងឆ្នាំ១៩៧៧ ។ សៀវភៅរៀនលេខថ្នាក់ទី២មានកម្រាស់១១២ទំព័រ ចែកជា៣ផ្នែក ។ ផ្នែកទី១មាន១៧មេរៀនឲ្យកុមារសិក្សាអំពីចំនួនរបៀបគុណលេខច្រើនខ្ទង់ ទសភាគ ប្រភាគ ផ្នែកទី២មាន១មេរៀនស្តីអំពីរង្វាស់ផ្ទៃក្រឡា និងផ្នែកទី៣មាន៩មេរៀនស្តីអំពីផ្ទៃនៃរាងកោណផ្សេងៗ ។ សៀវភៅភូមិសាស្ត្រនយោបាយ ថ្នាក់ទី២ បានបោះពុម្ពនៅឆ្នាំ១៩៧៧ ដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ មានកម្រាស់៧០ទំព័រ ចែកចេញជា២ផ្នែក គឺផ្នែកទី១មាន១មេរៀនស្តីអំពីប្រជាជាតិនិងប្រជាជន កម្ពុជា ផ្នែកទី២មាន១១មេរៀនស្តីអំពីការចាត់តាំងរដ្ឋអំណាច អំពីសហការណ៍ សហជីព និងខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា ។

នៅក្នុងស្រុកត្រាំកក់ ការសិក្សារបស់កុមារចែកជា៣ថ្នាក់ គឺថ្នាក់ទី១ ទី២ និងទី៣ ។ សម្រាប់ថ្នាក់ទី១និងទី២ មានរៀនអក្សរនិងលេខ ចំណែកឯថ្នាក់ទី៣ កុមារអាចអាននិងសរសេរបានខ្លះ និងមានបន្ថែមនូវមុខវិជ្ជាភូមិវិទ្យាមួយមុខទៀត ។ ថ្វីដ្បិតតែការសិក្សានៅស្រុកត្រាំកក់មាន៣ថ្នាក់ ក៏ប៉ុន្តែនៅក្នុងរយៈពេល សិក្សាទាំង៣ថ្នាក់នោះប្រើប្រាស់តែសៀវភៅរៀនលេខ-អក្សរថ្នាក់ទី១ និងសៀវភៅភូមិវិទ្យាមួយក្បាលដាច់ក្រប ដែលមិនអាចដឹងថាបោះពុម្ពឆ្នាំណានិងសម្រាប់បង្រៀនថ្នាក់ទីប៉ុន្មានប៉ុណ្ណោះ ។

## អំពីគ្រូបង្រៀន

ក្នុងការបែងចែកវណ្ណៈក្នុងសង្គមខ្មែរ របបកម្ពុជាប្រជាធិបតេយ្យបានចាត់ទុកអ្នកដែលបានរៀនសូត្រខ្ពង់ខ្ពស់ មានសញ្ញាប័ត្រពីសង្គមចាស់ជា"វណ្ណៈអនុធន" ។ អ្នកដែលនៅក្នុងវណ្ណៈអនុធនគឺជាប្រភេទមនុស្សដែលមានជំហរមិននឹងន ច្រើនអួតអាង នៅពេលមានសភាពការណ៍ធូរស្រាលទើបសកម្មចំពោះការងារ នៅពេលមានសភាពការណ៍តឹងតែងច្រើនរេរា ។ គោលជំហរបែបនេះចាត់ទុកថាធ្វើឲ្យរាំងស្ទះដល់ដំណើរការបដិវត្ត ហេតុដូច្នេះហើយទើបមានការប្រុងប្រយ័ត្នចំពោះមនុស្សក្នុងវណ្ណៈអនុធនគ្រប់ទីកន្លែងនិងគ្រប់ការងារ ។

នៅក្នុង"គោលនយោបាយវប្បធម៌នាបច្ចុប្បន្ន" របស់ខ្មែរក្រហមមុនពេលបានឡើងកាន់អំណាច បានចេញគោលការណ៍ថា ការរៀនសូត្រត្រូវរៀបចំត្រឹមកម្រិតបឋមសិក្សា ហើយការសិក្សានេះត្រូវធ្វើតាមពាក្យស្លោក "អ្នកចេះច្រើនបង្ហាត់អ្នកចេះតិច" ។ ពាក្យស្លោកនេះក៏ត្រូវបានយកមកអនុវត្តនៅក្រោយពេលរំដោះឆ្នាំ១៩៧៥ច្រើនជាងមុនពេលរំដោះទៅទៀត ។

អ្នកចេះច្រើនដែលមានចែងក្នុងពាក្យស្លោកនេះគឺមិនបានរាប់បញ្ចូលនូវអ្នកចេះដឹងដែលបានរៀនសូត្រកាលពីសង្គមមុន ដែលត្រូវបានចាត់ទុកជាអ្នកឋិតក្នុង "វណ្ណៈអនុធន" ឡើយ ។ នៅក្នុងសៀវភៅរៀនសូត្ររបស់កម្មាភិបាលខ្មែរក្រហមដែលបានបើកវគ្គរៀនសូត្រនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៥ បានសរសេរនៅក្នុងផ្នែក"ត្រូវយកចិត្តទុកដាក់ជំហរវណ្ណៈរបស់បក្ស" ថា ចំពោះបញ្ញាជនមិនឲ្យបង្រៀនទេ លើកលែងបញ្ញាជនដែលបានរស់នៅក្នុងតំបន់រំដោះឬបានទទួលការអប់រំពីបក្សតាំងពីឆ្នាំ១៩៧០-៧៣ ។

ថ្វីដ្បិតគោលការណ៍ថា បញ្ញាជនដែលបានទទួលការអប់រំក្នុងតំបន់រំដោះតាំងពីឆ្នាំ១៩៧០-៧៣ត្រូវទុកឲ្យបម្រើការងារក៏ដោយ ក៏នៅក្នុងស្រុកត្រាំកក់នៅតែមានការរើសអើងចំពោះអ្នកដែលមានចំណេះដឹងពីមុនមកដដែល ។ ជា ទូច ធ្លាប់ត្រូវប្រធានភូមិជ្រើសរើសធ្វើជាគ្រូបង្រៀនកុមារនៅឆ្នាំ១៩៧២ ។ ចាប់ពីឆ្នាំ១៩៧៣នៅក្នុងភូមិរបស់ ទូច មានការផ្លាស់ប្តូរប្រធានភូមិ ដោយយកអ្នក



ជា ទូច

ដាច់ខាត ។ ចាប់ពីពេលនោះមក គ្រូបង្រៀនដែលមានចំណេះដឹងច្រើនក្នុងភូមិរបស់ ទូច ក៏ត្រូវជម្រុះម្តងម្នាក់ៗ រហូតដល់ឆ្នាំ១៩៧៥ ទូច ក៏ត្រូវជម្រុះដែរ ពីព្រោះគាត់បានរៀនដល់ថ្នាក់ទី៤ចាស់ ។

គ្រូបង្រៀននៅស្រុកត្រាំកក់ចាត់តាំងឡើងដោយគណៈសិក្សា ឬគណៈភូមិ-ឃុំ គឺសំដៅយកអ្នកមានប្រវត្តិរូបល្អ មានសមាសភាពជាប់ចលនាបដិវត្តន៍ ។ គ្រូបង្រៀនមាននាទីជាប្រធានកងកុមារដែលត្រូវដឹកនាំកុមារឲ្យធ្វើពលកម្មផង និងជាអ្នកអប់រំគោលជំហរបដិវត្តន៍ដល់កុមារផង ចំណែកការបង្រៀនអក្សរជាភារកិច្ចបន្ទាប់បន្សំតែប៉ុណ្ណោះ ។

ខិន ខុន បាននិយាយថា ថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យបានកម្រិតទិសដៅការសិក្សាឲ្យចេះអក្សរនិងលេខ ។ ដូច្នេះហើយ ការជ្រើសរើសគ្រូបង្រៀនក៏មិនចាំបាច់រកអ្នកមានចំណេះដឹងជ្រៅជ្រះដែរ គឺជ្រើសរើសតែអ្នកដែលចេះអក្សរនិងលេខតិចតួចប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧០ ការជ្រើសរើសគ្រូបង្រៀនពុំមានការគិតគូរដល់និន្នាការទេ រហូតដល់ឆ្នាំ១៩៧៥ ចាប់ផ្តើមមានការជម្រុះគ្រូបង្រៀនណាដែលមានជាប់ពាក់ព័ន្ធនិន្នាការ ហើយទុកតែអ្នកដែលមានសមាសភាពល្អ ។

ឌុល ជឹម ជាគណៈឃុំពេល ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ការបរាជ័យនៃរបបកម្ពុជាប្រជាធិបតេយ្យ បាននិយាយថា "គ្រូបង្រៀនចេះតិចតួចក៏បានដែរ ឲ្យតែស្មោះត្រង់នឹងអង្គការ ។ ការជ្រើសរើសគ្រូបង្រៀន គឺប្រឡងតាមស្មារតីដែលយើងយល់ពីទិសដៅសង្គមនិយម គ្មានការប្រឡងអក្សរសាស្ត្រឬយកសញ្ញាប័ត្រទេ" ។

នៅឆ្នាំ១៩៧០ អ៊ុច ម៉ន បានឈប់រៀនត្រឹមថ្នាក់ទី៨ចាស់ (ថ្នាក់ទី៥បច្ចុប្បន្ន) រហូតដល់ឆ្នាំ១៩៧៣ គាត់មានអាយុ១៥ឆ្នាំ គាត់បានរណសិរ្សរួបរួមជាតិជ្រើសរើសឲ្យធ្វើជាគ្រូបង្រៀនកុមារ រហូតដល់ចុងឆ្នាំ១៩៧៨ ។ តាមការណែនាំរបស់ តាសារី ដែលតែងតែហៅ ម៉ន ទៅប្រជុំមួយខែម្តងៗ គឺឲ្យ ម៉ន អប់រំកុមារពីរឿងធ្វើពលកម្មតែប៉ុណ្ណោះ ។

ហំ ហ៊ន បង្រៀនកុមារតែពេលសម្រាកថ្ងៃត្រង់បន្ទាប់ពីបាយរួច ។ ក្នុងមួយថ្ងៃគាត់បង្រៀនបានតែមួយម៉ោងប៉ុណ្ណោះ ។ ហ៊ន ក៏បាននិយាយដែរថា "ការសិក្សានេះគ្រាន់តែអាចឲ្យកុមារចេះដឹងពីលេខនិងអក្សរតិចតួចប៉ុណ្ណោះ" ។

ចំណែក ប៉ែន យាន ក្នុងឆ្នាំ១៩៧២ មានអាយុ១៦ឆ្នាំ




ធ្លាប់រៀនដល់ថ្នាក់ទី៩ (ស្មើថ្នាក់ទី៤បច្ចុប្បន្ន) បានប្រឡងជាប់លេខ១ក្នុងការជ្រើសរើសគ្រូបង្រៀនក្នុងភូមិដែលមាន តាសារី ប្រធានផ្នែកវប្បធម៌ស្រុកត្រាំកក់ធ្វើជាមេប្រយោគ ។ រហូតដល់ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យាន បានបង្រៀនកុមារថ្នាក់ទី៣ដែលជាថ្នាក់ខ្ពស់បំផុត ។ ដោយសារលំហាត់ដែលមានចម្លើយស្រាប់ ដូច្នេះការបង្រៀននេះមិនចោទជាបញ្ហាអ្វីសម្រាប់ យាន និងគ្រូដទៃឡើយ ទោះបីគ្រូមិនចេះក៏អាចបង្រៀនបានដែរ ។

ក្រោយពេលរំដោះឆ្នាំ១៩៧៥ ប៊ុន ណម ត្រូវអង្គការជ្រើសរើសឲ្យទៅនៅកងកុមារ ។ នៅក្នុងកងកុមារ ណម បានរៀនសូត្រអក្សរបន្តិចបន្តួចតែប៉ុណ្ណោះ ។ នៅក្នុងកងកុមារជាងមួយឆ្នាំ ណម ត្រូវប្រធានកងរបស់គាត់ជ្រើសរើសឲ្យធ្វើជាគ្រូបង្រៀនកុមារតូចៗ ។ នៅពេលនោះ ណម គ្មានចំណេះដឹងអ្វីសម្រាប់បង្រៀនកុមារឡើយ ។ ជារៀងរាល់ថ្ងៃ នៅពេលដែលដល់ម៉ោងបង្រៀន ណម តែងតែនាំសិស្សអង្គុយជជែកគ្នាលេងនៅក្រោមដើមឈើ ។

## សម្ភារសិក្សា

ឯកសារ "ពិនិត្យ ក្តាប់ និងអនុវត្តន៍មាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក" ដែលធ្វើនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ បានសរសេរថា ក្នុងការសិក្សាត្រូវមានខ្មៅដៃនិងសៀវភៅ ។

ថ្វីត្បិតតែមានគោលការណ៍បែបនេះក៏ដោយ ក៏នៅស្រុកត្រាំកក់ ការសិក្សារបស់កុមារភាគច្រើនមានការខ្វះខាតសព្វបែបយ៉ាង កុមារត្រូវយកភក់បាតត្រពាំងមកលញ់ជាដុំមូល ឬយកដំឡូងមីចិតជាពងមូលៗដាក់ហាលថ្ងៃធ្វើជាដីស ។ នៅកន្លែងខ្លះ កុមារអាចមានសម្ភារសិក្សាបន្តិចបន្តួចតែប៉ុណ្ណោះ ។

អ៊ូច ម៉ន បាននិយាយថា កូនសិស្សរបស់គាត់មានខ្មៅដៃសម្រាប់ប្រើប្រាស់ រីឯសៀវភៅកុមារទាំងនោះត្រូវយកក្រដាសធំៗដែលសល់ពីរោងចក្រជំនាន់មុនមកកាត់បត់ ហើយដេរជាសៀវភៅ។ ចំពោះកុមារដែលមិនចេះម្ចាស់ការច្នៃប្រឌិតធ្វើសៀវភៅដោយខ្លួនឯង គឺគ្មានសៀវភៅសម្រាប់សរសេរទេ។

ពេលរៀនសូត្រ ផាត់ សមុទ្រ គ្មានឧបករណ៍អ្វីទាំងអស់។ គ្រូរបស់ សមុទ្រ ចម្លងមេរៀនដាក់លើក្តារខៀនឲ្យសិស្សអាន និងចម្លងតាម។ សមុទ្រ និង មិត្តភ័ក្ត្រ គ្មានសៀវភៅនិងខ្មៅដៃសម្រាប់កត់ត្រាឡើយ។

នៅក្នុងឯកសារដែលមានចំណងជើងថា "សភាពការណ៍នៃការកសាងប្រទេសជាតិយើងលើគ្រប់ផ្នែកទាំងអស់" ដែលធ្វើឡើងនៅឆ្នាំ១៩៧៦ ក៏បានបញ្ជាក់ដែរថា អង្គការមានបោះពុម្ពសៀវភៅសម្រាប់សិក្សា។

ក្រោយពេលរំដោះឆ្នាំ១៩៧៥ អង្គការស្រុកត្រាំកក់បានចែកសៀវភៅពុម្ពសម្រាប់សិក្សា ប៉ុន្តែមានតែគ្រូបង្រៀនទេដែលអាចទទួលបាន។ គ្រូបង្រៀនក្នុងស្រុកត្រាំកក់ត្រូវបង្រៀនកុមារទៅតាមសៀវភៅពុម្ពដែលអង្គការចែកឲ្យ។ ការបែងចែកសៀវភៅពុម្ពឲ្យគ្រូបង្រៀនក្នុងស្រុកត្រាំកក់នេះមិនបានគ្រប់ទីកន្លែងទេ ពីព្រោះមានការខ្វះខាត។ នៅចំពោះមុខបញ្ហាខ្វះខាតបែបនេះ ថ្នាក់ដឹកនាំបានចេញគោលការណ៍ឲ្យបោះពុម្ពសៀវភៅសិក្សាឲ្យបានច្រើន ក៏ប៉ុន្តែនៅក្នុងស្រុកត្រាំកក់នៅតែមានគ្រូបង្រៀនមួយចំនួនមិនបានទទួលសៀវភៅពុម្ពសម្រាប់បង្រៀនតាមឡើយ។

### ការសិក្សាបច្ចេកទេស

ក្នុងស្រុកត្រាំកក់ ក្រៅពីការរៀនអក្សរ មានកុមារមួយចំនួនដែលជាកូនរបស់កម្មាភិបាល ត្រូវអង្គការជ្រើសរើសឲ្យទៅធ្វើការដូចជាពេទ្យ អ្នកផ្សំថ្នាំ កងទ័ព កម្មកររោងចក្រ។ កុមារទាំងនោះត្រូវរៀននូវបច្ចេកទេសជំនាញទៅតាមការងាររៀងៗខ្លួន មានកុមារខ្លះរៀននៅក្នុងភូមិស្រុករបស់ខ្លួន ហើយកុមារខ្លះទៀតទៅរៀននៅទីរួមខេត្តតាកែវ នៅទីក្រុងភ្នំពេញ ជួនកាលទៅខេត្តដទៃទៀត និងនៅប្រទេសចិន។

ចំពោះនៅស្រុកត្រាំកក់ មានការរៀនជំនាញពេទ្យ ផ្សំថ្នាំ និងហាត់បច្ចេកទេសយោធា។ ប៉ុន្តែការរៀនសូត្របច្ចេកទេសនៅក្នុងស្រុកត្រាំកក់ពុំមានភាពច្បាស់លាស់ឡើយ។ ភាគច្រើនបំផុតរៀនតាមការអនុវត្តន៍ជាក់ស្តែងជាមួយអ្នកមានបទពិសោធន៍ដែលធ្លាប់ធ្វើការពីមុន គឺរៀនបណ្តើរធ្វើបណ្តើរ សាកល្បងលើពិសោធន៍បណ្តើរ។ ថ្វីដ្បិតតែមានគោលការណ៍ឲ្យមានការសិក្សាក៏ដោយ ក៏ការសិក្សានៅស្រុកត្រាំកក់មិនបានរៀបចំគ្រប់ទីកន្លែងទេ ពីព្រោះមានការងារច្រើនត្រូវធ្វើ។



ម៉ម សុផាត

នៅក្នុងស្រុកត្រាំកក់ ម៉ម សុផាត បានរស់នៅក្នុងកងកុមារតាំងពីឆ្នាំ១៩៧៦ គាត់មិនដែលបានទទួលការសិក្សាទាល់តែសោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលទើបនឹងចូលកងកុមារក្នុងឆ្នាំ១៩៧៦ អ៊ិត ស្មើង បានរៀនសូត្រអក្សរបន្តិចបន្តួចតាមការកំណត់របស់អង្គការក្នុងស្រុកត្រាំកក់។ មិនបាន១ឆ្នាំផងការងារកាន់តែច្រើន គាត់ក៏លែងបានរៀនសូត្រតទៅទៀត។ នៅក្នុងកងកុមារចល័ត ទឹម ផល មិនដែលបានរៀនត្រឹមត្រូវទេ។ ក្នុងម៉ោងរៀន គ្រូរបស់គាត់បង្រៀនតែបទចម្រៀងបដិវត្តន៍ និងអក្សរ២ទៅ៣តួដដែលៗជារៀងរាល់ថ្ងៃ។



អ៊ិត ស្មើង



ទឹម ផល

ដោយសារបានឆ្លងកាត់នូវរបបដែលពុំបានយកចិត្តទុកដាក់ចំពោះការសិក្សា កុមារក្នុងស្រុកត្រាំកក់មួយចំនួនដែលបច្ចុប្បន្នមានវ័យចំណាស់ទៅហើយនោះ បានក្លាយជាមនុស្សអវិជ្ជារហូតសព្វថ្ងៃ។

**កីម កែវកន្និដ្ឋា**

**(តមកពីទំព័រ១៥)** ភាគីទាំងពីរឯកភាពគ្នាលើគ្រប់បញ្ហាហើយសម្តែងការគាំទ្រគ្នាទៅវិញទៅមក ដើម្បីវាយបំបាក់នូវគ្រប់អំពើឈ្លានពានរបស់វាតទីនិយមសូវៀតនិងយួនជាបរិវារ ។

បន្ទាប់មក ភាគីកម្ពុជាយើងបានខទ្វេសនាមជូនមិត្តចិននូវអត្ថបទព្រាងទុកមួយ ជាការឆ្លើយតបនឹងសុន្ទរកថាមិត្តចិនពីពេលព្រឹក ហើយដែលមានខ្លឹមសារដូចតទៅ÷

ជារួម យើងឯកភាពទាំងស្រុងលើគ្រប់បញ្ហានិងទិដ្ឋភាពដែលមិត្តចិនលើកឡើងពីពេលព្រឹកថ្ងៃនេះ ។

ការរីកចំរើនខាងពាណិជ្ជកម្មរវាងកម្ពុជានិងចិនដែលមានមកដល់ថ្ងៃនេះគឺដោយសារបក្សយើងទាំងពីរឆ្លងតាមការផ្លាស់ប្តូរទស្សនកិច្ចនៃគណៈប្រតិភូបក្សនិងរដ្ឋាភិបាលជាហូរហែមក ។

ក្នុងកិច្ចការការពារប្រទេសក្រោមការដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជា ដែលមានសមមិត្តលេខា ប៉ុល ពត ជាមគ្គុទ្ទេសក៍ យើងខ្ញុំការពារព្រំដែនខាងលិចបានដោយម្ចាស់ការរហូតដល់សព្វថ្ងៃ ។ សព្វថ្ងៃនេះ នៅខាងលិចមានសភាពការណ៍ល្អចំពោះយើងខ្ញុំ ។

ចំពោះព្រំដែនខាងកើត យួនចង់លេបទឹកដីយើងខ្ញុំ បំបាត់ពូជសាសន៍កម្ពុជា ហើយវាយប្រហារយើងជាបន្តបន្ទាប់ ។ មើលពីក្រៅទំនាស់ហាក់ដូចជាទំនាស់ព្រំដែន តែធាតុពិតគឺយួនចង់លេបទឹកដីយើងខ្ញុំ ។ នៅចុងឆ្នាំ១៩៧៧ យួនបានវាយយើងខ្ញុំដោយទ្រង់ទ្រាយធំ តាមយុទ្ធសាស្ត្រវាយរហ័សឈ្នះរហ័ស ប៉ុន្តែវីរកងទ័ពកម្ពុជាយើងខ្ញុំក្រោមការដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាដែលមានសមមិត្តលេខា ប៉ុល ពត នាំមុខបានវាយបំបាក់ការឈ្លានពានយួន ឲ្យវាបរាជ័យយ៉ាងអាម៉ាស់នៅថ្ងៃទី៦ មករា ឆ្នាំ១៩៧៨ ។ ទោះបីវាចាញ់យ៉ាងនេះក៏ដោយ ក៏យួននៅតែបន្តវាយយើងខ្ញុំឥតឈប់ឈរ...

...ចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសយើងទាំងពីរ បញ្ហានេះយើងបានឯកភាពគ្នាតាំងពីម្សិលមិញហើយ ។ យើងខ្ញុំក៏យល់ស្របថាចាំបាច់ត្រូវមានកិច្ចព្រមព្រៀងពាណិជ្ជកម្មដើម្បីលើកតម្កើងឥទ្ធិពលនយោបាយភាគីយើងទាំងពីរ ។ យើងខ្ញុំឯកភាពនឹងពិភាក្សាល្អិតលើបញ្ហានេះនៅថ្ងៃក្រោយ ។

នៅពេលខាងមុខជិតនេះ យើងនឹងពិភាក្សាគ្នាលើសំភារៈដែលយើងខ្ញុំស្នើទិញសម្រាប់ឆ្នាំ១៩៧៩ ដើម្បីកំណត់ក្បួនខ្នាតឲ្យបានច្បាស់លាស់ ហើយសម្រួលការងារមិត្តចិនក្នុងការផ្តល់សម្ភារទាំងនោះឲ្យយើងខ្ញុំ ។ យើងខ្ញុំជឿជាក់ថា យើងនឹងធ្វើការបានលឿន ហើយសម្រេចសំណូមពររបស់យើងបានដោយជោគជ័យ ។ ក្នុងការសាកសួរពីក្បួនខ្នាតនេះ បើយើងខ្ញុំឆ្លើយដោះស្រាយមិនរួចនៅទីនេះ យើងខ្ញុំសូមអញ្ជើញមិត្តទៅពិនិត្យជាក់ស្តែងដល់កន្លែង ឧទាហរណ៍គ្រឿងបន្លាស់រោងចក្រផ្សេងៗ ពីព្រោះអ្នកបច្ចេកទេសយើងនៅថ្មីថ្មោងណាស់ ដូនកាលពន្យល់មិត្តចិនជាទ្រឹស្តីមិនទាន់បានទេ ។

នៅទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់មិត្តចិនទាំងអស់ក្នុងគណៈប្រតិភូ ឲ្យប្រកបដោយសេចក្តីសុខសប្បាយនិងទទួលជ័យជម្នះក្នុងឱកាសធ្វើទស្សនកិច្ចនៅកម្ពុជាយើងខ្ញុំ ។

មតិមិត្តចិនៈ

យើងខ្ញុំបានស្តាប់ដោយយកចិត្តទុកដាក់នូវសុន្ទរកថារបស់សមមិត្ត វ៉ាន់ រិត ស្តីពីការទាក់ទងពាណិជ្ជកម្មរវាងប្រទេសយើងទាំងពីរ ។

យើងខ្ញុំក្តាប់បានអំពីសមិទ្ធិដែលប្រជាជនកម្ពុជាសម្រេចបាននៅពេលក្រោយរំដោះ ក្រោមការដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជា ។ យើងខ្ញុំសូមថ្លែងអំណរគុណមិត្តកម្ពុជាដែលបានដាក់ការទុកចិត្តលើយើងខ្ញុំ យើងខ្ញុំនឹងនាំពាក្យទៅប្រាប់អង្គការនិងអង្គភាពនានាក្នុងប្រទេសយើងខ្ញុំ ដើម្បីឲ្យគេធ្វើការបានល្អជូនមិត្តកម្ពុជា ។

ដោយអនុលោមទៅតាមការរីកចំរើនខាងកសិកម្មឧស្សាហកម្មនិងពាណិជ្ជកម្មរបស់កម្ពុជា យើងខ្ញុំសង្ឃឹមថាមិត្តកម្ពុជាអាចដាក់តម្លៃផលិតផលនាំចេញរបស់កម្ពុជាក្នុងកិច្ចសន្យាទៅថ្ងៃមុខ ពីព្រោះមិត្តកម្ពុជាក៏ត្រូវធ្វើពាណិជ្ជកម្មជាមួយប្រទេសផ្សេងៗទៀតដែរ ។ ក្នុងវិស័យនេះ បើមិត្តកម្ពុជាចង់ឲ្យយើងខ្ញុំជួយរបៀបណាសូមលើកមតិឡើង យើងខ្ញុំនឹងខិតខំជួយ ។ ចំពោះបញ្ហាកំណត់គុណភាពនិងការវេចខ្ចប់ បើមិត្តកម្ពុជាចង់ឲ្យយើងខ្ញុំជួយក៏សូមមានមតិ ដើម្បីធ្វើឲ្យផលិតផលកម្ពុជាមានគុណភាពល្អនិងមានតម្លៃប្រសើរឡើងក្នុងផ្សារអន្តរជាតិ ។

ចំពោះការទិញដូររបស់មិត្តកម្ពុជា បើមិត្តកម្ពុជាមានបញ្ហា

អ៊ីស្មើលើកឡើងឲ្យបានមុន ហើយឲ្យសព្វគ្រប់បើធ្វើបាន ។ ខ្ញុំនឹងខិតខំផ្តល់សំភារៈតាមសំណូមពរកម្ពុជា ។

មិត្តកម្ពុជាអាចលើកគ្រប់បញ្ហាជាមួយយើងខ្ញុំនៅពេលនេះ ឬជាមួយគណៈប្រតិភូយើងខ្ញុំដែលស្ថិតនៅកម្ពុជាមួយរយៈពេលទៀត ឬជាមួយស្ថានទូតយើងខ្ញុំនៅភ្នំពេញគ្រប់ពេលវេលា ។

មតិយើងៈ

សូមអរគុណចំពោះការចាប់អារម្មណ៍និងមតិរបស់សមមិត្តប្រធានគណៈប្រតិភូ ។

ចំពោះការនាំចេញយើងខ្ញុំ ដោយយើងខ្ញុំនៅខ្វះខាតខាងស្ថិតិនិងជួរអ្នកបច្ចេកទេស យើងខ្ញុំស្នើមិត្តចិនដាក់តម្លៃផលិតផលយើងខ្ញុំតទៅទៀត យើងខ្ញុំទុកចិត្តមិត្តចិនទាំងស្រុង (សមមិត្តចេន ជា មានមតិតបវិញថា មិត្តកម្ពុជាដាក់តម្លៃខ្លួនឯងបានពេលណា ធ្វើពេលនោះចុះ) ។

យើងសូមអរគុណចំពោះការយោគយល់របស់មិត្តចិន យើងខ្ញុំនឹងខិតខំកែលម្អការងារយើងខ្ញុំឲ្យកាន់តែល្អទៅថ្ងៃមុខ ។ យើងខ្ញុំជឿជាក់ថា ទៅអនាគត ពាណិជ្ជកម្មរវាងប្រទេសយើងទាំងពីរនឹងកាន់តែលូតលាស់ថែមទៀត ។

ការចរចាបានចប់នៅម៉ោង៨និង២៥នាទីរសៀល ។ ភាគីទាំងពីរបានឯកភាពគ្នាលើគ្រប់គោលការណ៍សំខាន់ៗដែលបានលើកឡើង ។

បន្ទាប់បានអគ្គុយសម្រាកនិងសំណេះសំណាលបន្តិច ការប្រជុំក៏ត្រូវបានបញ្ចប់នៅម៉ោង៨និង៤៥នាទីរសៀលដោយជោគជ័យ ។

ធ្វើនៅភ្នំពេញ, ថ្ងៃ៣ ខែធ្នូ ឆ្នាំ១៩៧៨

# គោរពជូន បងខៀវ និង បងធុំ

◆ តាមសេចក្តីរាយការណ៍ពីស.មសេនាធុព័ន្ធនៅស្ថានទូតចិន ស.ម មៀវ ឲ្យដឹងថាៈ នៅចុងខែមិថុនាឬដើមខែកក្កដាមុខនេះ សម្ភារៈយោធានឹងដឹកមកតាមកប៉ាល់ទឹកមកកំពង់សោម មានទម្ងន់ទាំងអស់ប្រហែល១០០០តោន ។

សម្ភារៈទាំងនោះមាន÷

១) សម្ភារៈរបស់រថក្រោះ និងរថក្រោះ
 ◆ រថក្រោះធុនស្រាល ២០គ្រឿង
 ◆ រថក្រោះបើកក្នុងទឹក និងដីគោក ១០គ្រឿង
២) ម៉ាស៊ីនភ្លើងសម្រាប់កងរថក្រោះ ១គ្រឿង
៣) ឡានសំណង់កែកំដៅ ១គ្រឿង
៤) ឡានបញ្ជាការ ១គ្រឿង
៥) ឡានស្ទូច ១គ្រឿង
៦) ឡានបូមប្រេង ១គ្រឿង
៧) ឡានដាង ១គ្រឿង
៨) គ្រាប់សម្រាប់កាំភ្លើងដាក់លើរថក្រោះ ១០០០០គ្រាប់
៩) គ្រាប់១២,៧ ៣០០០០គ្រាប់
១០) សម្ភារៈសម្រាប់កងជើងទឹក
១១) សម្ភារៈសម្រាប់កងអាកាស
១២) សម្ភារៈសម្រាប់វិទ្យុទាក់ទង
១៣) សម្ភារៈខាងក្រុមសំណង់
១៤) សម្ភារៈសម្រាប់កងវរៈសេនាធំកាំភ្លើងធំ ។

សម្ភារៈទាំងអស់នេះ គឺជាសម្ភារៈមាននៅក្នុងកិច្ចព្រមព្រៀងបក្សនិងប្រជាជនទាំងពីរកម្ពុជា-ចិន ។

**បន្ថែមៈ**

យន្តហោះធុន សេ-១២៣ បានជួសជុលហើយពីរគ្រឿង "២" ។

យន្តហោះនេះនឹងសាកល្បងហោះហើរនៅថ្ងៃ១៥-៦-៧៦ នេះនៅកំពង់ឆ្នាំង ។

ខាងចិនទៅរួមក្នុងការសាកល្បងមាន

◆ ស.ម ទូត ស៊ុន ហាវ

◆ ស.ម គឹង យុនសាង

ខាងចិនចេញដំណើរទៅមើលនៅថ្ងៃ១៥-៦-៧៦ ដោយជិះយន្តហោះពីពោធិចិនតុងទៅកំពង់ឆ្នាំង ។ ពេលល្ងាចត្រឡប់មកវិញ ។

ថ្ងៃទី១២-៦-៧៦

ធាញ

**(ឯកសារលេខ** L1291)

# ក្រមច្បាប់នីតិវិធីជាអប្បបរមា ក្រុងប៉ែលក្រាដ សម្រាប់បេសកកម្មស្វែងរកការពិត សិទ្ធិមនុស្សអន្តរជាតិ

## I. អាណត្តិ

១) អង្គការមួយដែលបង្កើតបេសកកម្មស្វែងរកការពិតមួយ គួរតែបង្កើតអាណត្តិជាទិសដៅដែលមិនវិនិច្ឆ័យមុនពិនិត្យការពិតដែលនឹងត្រូវស៊ើបអង្កេត ។ អាណត្តិទាំងនេះគួរស្របគ្នាទៅនឹងលិខិតូបករណ៍បង្កើតអង្គការនេះឡើង ។

២) សេចក្តីសម្រេចផ្តល់អំណាចដល់បេសកកម្មនេះមិនត្រូវវិនិច្ឆ័យរបកគំហើញនិងការងាររបស់បេសកកម្មនេះមុនការពិនិត្យលើអង្គហេតុឡើយ ។

៣) ទោះបីជាអាណត្តិមិនត្រូវដាក់កម្រិតលើបេសកកម្មក្នុងលក្ខណៈមិនសមស្របក្នុងការស៊ើបអង្កេតអំពីប្រធានបទនេះនិងបរិបទរបស់វាក៏ដោយ អាណត្តិទាំងនេះត្រូវតែមានលក្ខណៈច្បាស់លាស់ ដើម្បីចង្អុលបង្ហាញពីសារជាតិរបស់ប្រធានបទដែលត្រូវបានធ្វើការស៊ើបអង្កេត ។

## II. ការជ្រើសរើសអ្នកស្វែងរកការពិត

៤) បេសកកម្មស្វែងរកការពិតត្រូវមានសមាសភាពជាក្រុមមនុស្សដែលបានទទួលការគោរពពីអ្នកដទៃដោយសារតែភាពស្មោះត្រង់ មិនលម្អៀង សមត្ថភាព និងកម្មវិស័យភាព និងអ្នកណាដែលកំពុងបម្រើការងារតាមភារកិច្ចផ្ទាល់ខ្លួនរបស់គេ ។

៥) កន្លែងដែលអាណត្តិរបស់បេសកកម្មទាក់ទងជាមួយរដ្ឋមួយ ឬក៏រដ្ឋមួយចំនួន ដើម្បីបង្កឲ្យមានលក្ខណៈងាយស្រួលដល់ភារកិច្ចរបស់បេសកកម្មនេះ រដ្ឋាភិបាលនោះឬរដ្ឋាភិបាលដែលពាក់ព័ន្ធគួរតែត្រូវបានពិគ្រោះយោបល់នៅគ្រប់ពេលដែលអាចធ្វើទៅបានចំពោះសមាសភាពដែលត្រូវបញ្ចូលក្នុងបេសកកម្មនេះ ។

៦) គ្រប់បេក្ខជនទាំងឡាយដែលត្រូវគេតែងតាំងជាសមាជិកបេសកកម្មស្វែងរកការពិត មិនត្រូវបានគេបញ្ឈប់ពីតួនាទីជាសមាជិកឡើយ លើកលែងតែមកពីមូលហេតុអសមត្ថភាពឬក៏មានអាកប្បកិរិយាមិនសមរម្យដែលមិនអាចទទួលយកបាន ។

៧) ប្រធាននិងអ្នករាយការណ៍នៃបេសកកម្មស្វែងរកការពិត មិនត្រូវផ្លាស់ប្តូរឡើយក្នុងពេលកំពុងបំពេញបេសកកម្មនេះ លើកលែងតែមានមូលហេតុដទៃទៀត ដូចជាអសមត្ថភាពឬការប្រព្រឹត្តខុសឆ្គងដ៏ធំ ។

៨) នៅពេលដែលបេសកកម្មស្វែងរកការពិតត្រូវបានបង្កើតឡើង ហើយសមាជិកនិងប្រធានបេសកកម្មនេះត្រូវបានជ្រើសតាំងឡើង គ្មាននរណាម្នាក់ទៀតត្រូវជ្រើសតាំងបន្ថែមជាសមាជិកនៃបេសកកម្មនេះឡើយ លើកលែងតែក្នុងករណីដើម្បីបំពេញកន្លែងទំនេរនៅក្នុងបេសកកម្មនេះប៉ុណ្ណោះ ។

## III. ការប្រមូលភស្តុតាង

៩) នៅពេលចាប់ផ្តើមបេសកកម្មនេះ រាល់ឯកសារទាំងអស់ដែលទាក់ទងទៅនឹងគោលបំណងនៃបេសកកម្មនេះត្រូវបង្កើតឲ្យមានឡើងសម្រាប់បេសកកម្មនេះ ដោយមានជំនួយពីសំណាក់អង្គការនានាដែលពាក់ព័ន្ធ ។

១០) បេសកកម្មស្វែងរកការពិតទាំងឡាយត្រូវធ្វើប្រតិបត្តិការជាមួយបុគ្គលិកដែលមានបុគ្គលិកលក្ខណៈគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឲ្យធ្វើការប្រមូលទិន្នន័យដោយឯករាជ្យ ហើយបេសកកម្មនេះត្រូវមានការជួយជ្រោមជ្រែងដោយអ្នកជំនាញបំពេញការងារជាឯករាជ្យតាមដែលបេសកកម្មនេះយល់ឃើញថាចាំបាច់ ។

១១) បេសកកម្មស្វែងរកការពិតអាចស្នើឲ្យមានការដាក់ជូននូវវត្ថុតាងជាលាយលក្ខណ៍អក្សរ ហើយដែលមានការអធិប្បាយដាក់លាក់ពីអង្គហេតុដែលអាចយកមកធ្វើការផ្ទៀងផ្ទាត់បាន ។

១២) រដ្ឋដែលពាក់ព័ន្ធត្រូវមានឱកាសមួយដើម្បីផ្តល់យោបល់ជាលាយលក្ខណ៍អក្សរអំពីទិន្នន័យដែលត្រូវបាននិយាយយោងនៅក្នុងកថាខណ្ឌទី១០ និងសេចក្តីអធិប្បាយទាំងឡាយដែលត្រូវបាននិយាយយោងនៅក្នុងកថាខណ្ឌទី១១ ។

១៣) ទាំងភាគីធ្វើពាក្យបណ្តឹងក៏ដូចជារដ្ឋ អង្គការមិនមែន

រដ្ឋាភិបាល ឬក្រុមបុគ្គលទាំងឡាយ និងរដ្ឋទាំងឡាយដែលពាក់ព័ន្ធ អាចបង្ហាញពីបញ្ជីឈ្មោះសាក្សីទាំងឡាយដល់បេសកកម្មស្វែងរកការពិតនេះ ។ បេសកកម្មស្វែងរកការពិត ត្រូវធ្វើសេចក្តីសម្រេចចិត្តមួយដោយខ្លួនឯង ចំពោះថាតើសាក្សីណាខ្លះដែលត្រូវអនុញ្ញាតឲ្យឡើងបកស្រាយ ។

១៤) តាមធម្មតា ភាគីធ្វើពាក្យបណ្តឹងត្រូវបានអនុញ្ញាតឲ្យឡើងមកបកស្រាយនៅចំពោះមុខបេសកកម្មស្វែងរកការពិតជាសាធារណៈ ដោយផ្តល់ឱកាសដល់រដ្ឋដែលពាក់ព័ន្ធឲ្យសួរសំណួរ ។

## IV. បញ្ហានៃការស្វែងរកការពិតនិងភ័ស្តុតាង

១៥) បេសកកម្មស្វែងរកការពិតត្រូវតម្រូវជាមុនឲ្យរដ្ឋដែលពាក់ព័ន្ធផ្តល់ការធានាឲ្យបានគ្រប់គ្រាន់ថានឹងមិនសងសឹកមកលើបុគ្គលដែលដាក់ពាក្យបណ្តឹង សាក្សី និងសាច់ញាតិរបស់ពួកគេឡើយ ។

១៦) ក្នុងករណីដែលការធានាមួយដូចដែលបាននិយាយយោងទៅក្នុងកថាខណ្ឌ១៥ ត្រូវបានផ្តល់គួរជាទីគាប់ចិត្តដល់បេសកកម្មស្វែងរកការពិត នៅពេលស្តាប់ការបកស្រាយដោយសាក្សីទាំងឡាយ បេសកកម្មស្វែងរកការពិតត្រូវផ្តល់ឱកាសមួយដល់រដ្ឋដែលពាក់ព័ន្ធ ឲ្យមានវត្តមានដើម្បីសួរសំណួរសាក្សីទាំងនោះ ឬក៏ផ្តល់របាយការណ៍កសិណរបស់សាក្សីទាំងនោះដល់រដ្ឋដែលពាក់ព័ន្ធ ដើម្បីសុំយោបល់ពីគេមកវិញ ។

១៧) បេសកកម្មស្វែងរការពិត អាចដកចេញនូវព័ត៌មានណាដែលតាមការកាត់សេចក្តីរបស់ខ្លួនឃើញថាបង្កឲ្យមានគ្រោះថ្នាក់ឬយាយីដល់សុវត្ថិភាពឬសុខុមាលភាពរបស់អ្នកទាំងឡាយដែលផ្តល់នូវកសិណសាក្សីនេះ ឬភាគីទីបី ឬដែលនៅក្នុងទស្សនៈរបស់ខ្លួន ព័ត៌មាននោះទំនងជាបង្កើតឲ្យដឹងពីប្រភពទាំងនោះ ។

១៨) ដោយផ្អែកលើទិន្នន័យដែលបង្កើតដោយបុគ្គលិករបស់ខ្លួន ឯកសារជាលាយល័ក្ខណ៍អក្សរ និងកសិណរបស់សាក្សីជាច្រើន បេសកកម្មស្វែងរកការពិតត្រូវធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯងចំពោះថា តើខ្លួនចាំបាច់ត្រូវចុះត្រួតពិនិត្យនៅតាមមូលដ្ឋានជាក់ស្តែងដែរឬយ៉ាងណា ។

## V. ការស៊ើបអង្កេតតាមមូលដ្ឋាន

១៩) បេសកកម្មស្វែងរកការពិតត្រូវតាក់តែងនូវកម្មវិធីការងាររបស់ខ្លួនរួមមានៈ បញ្ជីសាក្សីទាំងឡាយដែលខ្លួនមានបំណងចង់ជួបសម្ភាសន៍នៅកន្លែងស៊ើបអង្កេត ទីកន្លែងនានាដែលខ្លួនមានបំណងចុះទៅធ្វើការងារ លំដាប់លំដោយនៃអង្គហេតុ ការកំណត់ពេលវេលា និងការកំណត់សកម្មភាពទាំងឡាយដែលត្រូវអនុវត្តនៅតាមមូលដ្ឋាន ។

២០) បេសកកម្មស្វែងរកការពិតអាចប្រតិបត្តិការរបស់ខ្លួនទាំងស្រុង ឬជាក្រុមតូចៗជាងនេះ តាមស្ថានភាពជាក់ស្តែង និងតម្រូវការនៃការស៊ើបអង្កេតនេះ ។

២១) បេសកកម្មស្វែងរកការពិតត្រូវឈ្លុសឈ្លុលសុំសម្ភាសន៍ជនទាំងឡាយណាដែលខ្លួនគិតថាចាំបាច់ ទោះបីជាអ្នកជាប់ទោសក៏ដោយ ។

## VI. ដំណាក់កាលចុងក្រោយ

២២) បន្ទាប់ពីធ្វើសេចក្តីសន្និដ្ឋានលើការស៊ើបអង្កេតនៅតាមមូលដ្ឋាន សមាជិកទាំងឡាយនៃបេសកកម្មស្វែងរកការពិត ត្រូវរៀបចំគម្រោងធ្វើការស្រាវជ្រាវដំបូងមួយចំនួនហើយដាក់ជូននូវរបកគំហើញទាំងនេះ រួមទាំងសំណួរបន្ថែមមួយចំនួននៅចំណុចណាដែលសមស្រប ទៅឲ្យរដ្ឋទាំងឡាយដែលពាក់ព័ន្ធ ដោយផ្តល់នូវឱកាសមួយដល់រដ្ឋទាំងនោះក្នុងពេលសមស្របដើម្បីបង្ហាញពីយោបល់របស់ខ្លួន និង/ឬ ដើម្បីកែតម្រង់បញ្ហាដែលត្រូវស៊ើបអង្កេត ។

២៣) របាយការណ៍ចុងក្រោយត្រូវរៀបចំឡើងដោយប្រធានបេសកកម្មនេះ ដោយឆ្លុះបញ្ចាំងពីការប្រមូលមតិរួមនៃបេសកកម្មនេះ ។ បើពុំមានការមូលមតិគ្នាទេ របាយការណ៍របស់បេសកកម្មនេះត្រូវមានរបកគំហើញនៃសមាជិកភាគច្រើនក៏ដូចជាទស្សនៈនានានៃសមាជិកដែលមានការជំទាស់ ។

២៤) ក្នុងករណីដែលមានសេចក្តីសម្រេចថាត្រូវតែផ្សព្វផ្សាយរបាយការណ៍ គួរតែផ្សព្វផ្សាយទាំងស្រុងតែម្តង ។

២៥) អង្គការដែលបង្កើតឡើងនូវបេសកកម្មស្វែងរកការពិតនេះ គួរតែពិនិត្យរដ្ឋទាំងឡាយដែលពាក់ព័ន្ធអំពីការគោរពតាមការកិច្ចរបស់ខ្លួនដែលថាមិនសងសឹកទៅលើអ្នកផ្តល់

ពាក្យបណ្តឹង សាក្សី និងសាច់ញាតិរបស់ពួកគេ និងអ្នកដទៃទៀត ។

## ការស្វែងរកការពិតដោយអង្គការមិនមែនរដ្ឋាភិបាល

វាមិនមែនមានតែ ឬមិនសំខាន់តែអង្គការនៅក្រោមរដ្ឋាភិបាលនោះទេដែលចូលប្រឡូកនៅក្នុងដំណើរការនៃការស្វែងរកការពិតនៅក្នុងវិស័យសិទ្ធិមនុស្ស ។ អង្គការមិនមែនរដ្ឋាភិបាលក៏មានការចូលរួមសកម្មផងដែរនៅក្នុងវិស័យនេះ ហើយអង្គការមិនមែនរដ្ឋាភិបាលទាំងនេះប្រហែលជាសកម្មជ្រុលផង ដោយសារការនិយមចូលចិត្តប្រទេសមួយចំនួន ។ អង្គការមិនមែនរដ្ឋាភិបាលមានការចាប់អារម្មណ៍ មានមុខងារនិងប្រភពឯកសារដ៏ច្រើនប្រភេទស្ទើរតែបង្ហាញពីសញ្ញាណរួមទាំងមូលបាន ។ សូម្បីតែគោលដៅទាំងឡាយដែលពួកគេកំណត់ឡើងក្នុងការប្រើប្រាស់ឯកសារដែលខ្លួនទទួលបាន ក៏ខុសគ្នាដូចមេឃនិងដីដែរ ។

គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ជាឧទាហរណ៍ មានបទពិសោធន៍ដ៏ទូលំទូលាយក្នុងការស៊ើបអង្កេតលើលក្ខខណ្ឌទាំងឡាយដែលអ្នកទោសត្រូវបានឃុំឃាំងក្នុងពេលមានជម្លោះប្រដាប់អាវុធ ។ អង្គការនេះមិនត្រូវផ្សព្វផ្សាយពត៌មានឡើយ ។ មុខងាររបស់អង្គការនេះគឺជាសំខាន់ដើម្បីចរចាយ៉ាងប៉ិនប្រសប់ជាមួយរដ្ឋទាំងឡាយដែលមានការពាក់ព័ន្ធផ្ទាល់ ។ ផ្ទុយទៅវិញ អង្គការទាំងឡាយដូចជាអង្គការលើកលែងទោសអន្តរជាតិ និងឃ្លាំមើលសិទ្ធិមនុស្សទាំងឡាយនៅក្នុងបណ្តាប្រទេសជាច្រើន ហើយផ្សព្វផ្សាយរបាយការណ៍ទាំងនេះទៅសាធារណជនទូទៅឲ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមដទៃទៀតក៏ចូលរួមក្នុងការធ្វើក្តីក្តាំអំពីបញ្ហាសិទ្ធិមនុស្សនៅចំពោះមុខតុលាការក្នុងស្រុកឬអន្តរជាតិដែរ ។ ពួកគេត្រូវប្រមូលប្រភេទភ័ស្តុតាងដែលនឹងទទួលការឆ្លើយតបចំពោះមុខតុលាការច្បាប់ ។

***អេលីហ្សាប៊ែត វ៉ាន់ស្កាក់***



◆◆◆វាយចូលទីក្រុងភ្នំពេញឆ្នាំ១៩៧៩

# យុទ្ធសាស្ត្រការពារប្រទេសរបស់ខ្មែរក្រហម ទប់ទល់ជាមួយវៀតណាម

## ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨

*សេចក្ដីដកស្រង់ពីការផ្សាយពត៌មានតាមវិទ្យុផ្សាយសំឡេងកម្ពុជាប្រជាធិបតេយ្យ ស្ដីអំពីសភាពការណ៍ការពារប្រទេសចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ÷*

*តើសភាពការណ៍ការពារជាតិរបស់យើងកាលពីឆ្នាំទៅវាយ៉ាងម៉េច? នៅក្នុងអំឡុងពេលនេះ យើងបានវាយប្រយុទ្ធយ៉ាងស្វាហាប់អង់អាចខ្លាំងក្លាជាមួយខ្មាំង ទាំងខ្មាំងខាងក្នុង និងខាងក្រៅ ហើយទទួលបានជ័យជម្នះពេញលេញទៀតផង ។*

*១) ការពារនៅតាមព្រំប្រទល់ខាងលិចៈ ឆ្នាំនេះមានការប៉ះទង្គិចមួយចំនួន ប៉ុន្តែយើងបានម្ចាស់ការលើសភាពការណ៍ គ្មានអ្វីគួរឲ្យព្រួយបារម្ភទេ ។ ឥឡូវនេះយើងអាចការពារព្រំដែនបាន ហើយនៅពេលខាងមុខយើងកាន់តែការពារបានជាងនេះទៅទៀត ។*

*២) ការពារព្រំប្រទល់ខាងកើតៈ ការការពារព្រំដែនខាងកើតគឺជារឿងស្រួចស្រាល់ខ្លាំងក្លា ពីព្រោះនៅខាងកើតប្រទេសកម្ពុជាមានព្រំប្រទល់ជាប់ជាមួយវៀតណាម ។ វៀតណាមចង់យកទឹកដីយើង ហើយប្រែក្លាយឲ្យទៅជាប្រទេសរណបរបស់វា ដោយយកធ្វើជាផ្នែកមួយរបស់ប្រទេសវៀតណាម ។ ដោយសារយ៉ាងនេះហើយ បានជាឆ្នាំកន្លងមកមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លានិងឃោរឃៅប្រឆាំងនឹងវៀតណាម ។*

*នៅក្នុងអំឡុងពេលគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី១៧ ខែមេសា ១៩៧៨ ការប្រយុទ្ធគ្នាកើតមានឡើងជាទ្រង់ទ្រាយតូច មធ្យម និងទ្រង់ទ្រាយធំ ។ ឆ្នាំនេះកម្រិតនៃការវាយប្រយុទ្ធគ្នាបានកើនឡើង ។ ចំណុចពិសេសនៃការវាយវៀតណាមគឺថា វាមានភាពស្រួចស្រាល់ជាងឆ្នាំកន្លងទៅ ។ នេះគឺដោយសារវៀតណាមដែលមិនមានកម្លាំងខាងក្នុងត្រូវវាយយើងពីខាងក្រៅ ហើយការវាយពីខាងក្រៅតម្រូវឲ្យមានកម្លាំងយ៉ាងច្រើនទើបអាចទៅរួច ។ (ក្នុងការប្រយុទ្ធគ្នាក្នុងខែវិច្ឆិកានិងធ្នូ) កន្លងទៅនេះ យើងបានកម្ទេចនិងវាយរុញច្រានកងទ័ពយួនឈ្លានពានឲ្យចេញពីទឹកដីយើងអស់នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ ដោយធ្វើឲ្យពួកវាស្លាប់និងរបួសប្រមាណ២ម៉ឺន៩ពាន់ក្បាល និងកម្ទេចកងពលវាអស់ចំនួន៥...។ នេះគឺជាការបើកឆាកជ័យជម្នះនៅដំណាក់កាលដំបូង ។ នៅពេលយើងវាយប្រហារទៅលើខ្មាំងនិងទទួលបានជ័យជម្នះជាលើកដំបូងនេះ យើងមិនទាន់បានរៀបចំកម្លាំងបានត្រឹមត្រូវនៅឡើយទេ ។ ដូចជាកម្លាំងកងទ័ពរបស់មជ្ឈិមបក្សដែរ កម្លាំងរបស់យើងនៅក្នុងតំបន់នីមួយៗមិនត្រូវបានរៀបចំឲ្យបានពេញលេញស្រួលបួលក្នុងការប្រយុទ្ធក្នុងទ្រង់ទ្រាយធំឡើយ ហើយទាំងកងទ័ពនិងអាវុធយុទ្ធភ័ណ្ឌក៏មិនទាន់បានចាត់ចែងឲ្យបានពេញលេញដែរ ។ ក៏ប៉ុន្តែយើងទទួលជោគជ័យក្នុងការកម្ទេចកម្លាំងវៀតណាម...។*

*កម្លាំងវៀតណាមពេលនោះវាយយើងក្នុងដំណាក់កាលទីពីរ ។ ការវាយលុកក្នុងដំណាក់កាលនេះបានចាប់ផ្ដើមនៅចុងខែកុម្ភៈឆ្នាំ១៩៧៨ ហើយរៀបចំកម្ទេចយើងនៅក្នុងខែមីនា ហើយកាន់កាប់ទឹកដីកម្ពុជាយើងនៅខែមេសា...។ ហេតុដូច្នេះហើយបានជាវៀតណាមដាក់កងពលចំនួន១១ក្នុងការវាយលើកនេះ ពោលគឺលើសពីដំណាក់កាលទីពីររហូតដល់២កងពល ។ តើវាយ៉ាងម៉េចទៅបើយ៉ាងដូច្នេះ?*

*នៅពេលដែលយើងទទួលបានជ័យជម្នះនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ យើងមិនឲ្យវៀតណាមវាយយើងមុនទៀតឡើយ ប៉ុន្តែយើងនៅតែបន្តវាយវាឥតដាច់ ។ យើងបានវាយប្រយុទ្ធរហូតដល់ចុងខែមករា ។ យើងក៏បានវាយពួកវានៅក្នុងខែកុម្ភៈដែរ ។ កម្លាំងវៀតណាមចេះតែថមថយទៅៗជាលំដាប់ដោយបាត់បង់ទ័ពអស់ជាច្រើន ។ ពេលនោះវៀតណាមបានបញ្ជូនកម្លាំងថ្មីមកបន្ថែមទៀតដើម្បីវាយយើង ។ ក៏ប៉ុន្តែក្នុងខែមីនាវៀតណាមមិនមានកម្លាំងវាយយើងទេ ។ ផ្ទុយមកវិញយើងទេដែលបន្តវាយពួកវាវិញនោះ ។ នៅក្នុងខែមីនា ការប្រយុទ្ធគ្នាប្រព្រឹត្តទៅខ្លាំងក្លាណាស់ ពីព្រោះនៅតាមខ្សែត្រៀមមួយ*

ចំនួនមានរាយកម្លាំងកងពល ដូច្នេះកងពលប៉ះជាមួយកងពលពិតជាមិនមែនជាសង្គ្រាមតូចតាចទេ ។ វៀតណាមបានបរាជ័យនៅក្នុងខែមករានិងខែកុម្ភៈរួចមកហើយ ហើយនៅក្នុងខែមីនានេះទៀត វៀតណាមក៏ទទួលបរាជ័យទៀត ដូច្នេះបរាជ័យរឹតតែធ្ងន់ធ្ងរជាន់ពីលើទៀត ។ ដោយសារកម្លាំងខ្លួនត្រូវទទួលបរាជ័យក្នុងខែមីនា វៀតណាមគ្មានកម្លាំងវាយយើងបានទេ... ។ ដូច្នេះហើយបានជាវាបែរមកប្រើយុទ្ធសាស្ត្រសង្គ្រាមឈ្លបវិញប្រវាយប្រហារក្នុងរូបភាពតូចៗ ។ ដោយសារតែផែនការវាយទ្រង់ទ្រាយធំត្រូវទទួលបរាជ័យ វៀតណាមបានងាកមករកការវាយប្រហារតូចៗ ប៉ុន្តែនៅពេលការវាយទ្រង់ទ្រាយធំបានបរាជ័យ ការវាយប្រយុទ្ធក្នុងរូបភាពតូចៗក៏មានការបាត់បង់កាន់តែធ្ងន់ធ្ងរទៅៗដែរ... ។

យើងត្រូវប្រយុទ្ធដើម្បីការពារឯករាជ្យ អធិបតេយ្យភាពនិងបូរណភាពទឹកដីកម្ពុជា ។ យើងត្រូវរស់នៅដោយស្វ័យម្ចាស់ការខ្លួនទីពឹងខ្លួន ។ យើងមិនអាចទ្រាំរស់នៅក្រោមការគាបសង្កត់បានទេ ។ នេះជាគោលជំហរជ័យជម្នះ ។ នេះមិនមែនជាជំហរចុះចាញ់ទេ ប៉ុន្តែជាជំហរជ័យជម្នះ ។ នេះជាចំណុចទី១ ។ ឈរលើជំហរជាមូលដ្ឋាននេះ យើងរៀបចំមាគ៌ាប្រយុទ្ធរបស់យើង អនុវត្តសង្គ្រាម និងអនុវត្តមាគ៌ាប្រយុទ្ធឲ្យមានប្រសិទ្ធិភាពដើម្បីវាយឲ្យខ្មាំងបរាជ័យ ។ បក្សបានណែនាំថា យើងត្រូវព្យាយាមកម្ទេចខ្មាំងឲ្យបានកាន់តែច្រើនតាមតែអាចធ្វើទៅបាន ហើយព្យាយាមរក្សាកម្លាំងរបស់យើងឲ្យបានច្រើនជាអតិបរមា ។ យើងមានកម្លាំងតិច ប៉ុន្តែយើងត្រូវវាយកម្លាំងធំ ។ ហេតុដូច្នេះយើងត្រូវរក្សាកម្លាំងរបស់យើងឲ្យបានច្រើននិងសម្លាប់ខ្មាំងឲ្យបានច្រើន ។ នេះជាទិសស្លោករបស់យើង ។ និយាយពីចំនួនវិញ កម្លាំងយើង១នាក់ត្រូវសម្លាប់វៀតណាម៣០នាក់ ។ បើយើងអាចអនុវត្តទិសស្លោកនេះបាន យើងប្រាកដជាឈ្នះ ។ យើងត្រូវកម្ទេចវៀតណាម ទោះជាវាធំប៉ុនណាក៏ដោយ ។ ប្រទេសណាដែលហ៊ានឈ្លានពានទឹកដីកម្ពុជាយើងនឹងត្រូវទទួលបរាជ័យជាមិនខានបើយើងគោរពតាមទិសស្លោកនេះ ។ មកដល់សព្វថ្ងៃនេះយើងបានជោគជ័យក្នុងការអនុវត្តទិសស្លោក១ទល់នឹង៣០នេះ ។ ពោលគឺយើងបាត់បង់ម្នាក់ទល់នឹងវៀតណាម៣០នាក់ ។ ដូច្នេះការបាត់បង់កម្លាំងរបស់យើងស្មើនឹង១ភាគ៣០នៃការបាត់បង់កម្លាំងរបស់វៀតណាម ។

ដោយប្រើតួលេខនេះ ទាហានកម្ពុជាម្នាក់ស្មើនឹងទាហានវៀតណាមចំនួន៣០នាក់ ។ តើវៀតណាមប៉ុន្មាននាក់ទៅស្មើនឹងទាហានកម្ពុជា១០នាក់នោះ? ចម្លើយគឺថា៣០០នាក់ ។ ហើយកម្ពុជា១០០នាក់ស្មើនឹងវៀតណាម៣០០០នាក់ ។ កម្ពុជា១លាននាក់ស្មើនឹងវៀតណាម៣០លាននាក់ ។ យើងមានកម្លាំង២លាននាក់គឺស្មើនឹងកម្លាំងវៀតណាម៦០លាននាក់ហើយ ។ ក៏ប៉ុន្តែកងកម្លាំង២លាននាក់វាលើសពីគ្រប់គ្រាន់បាត់ទៅហើយក្នុងការវាយជាមួយវៀតណាមនោះ ពីព្រោះវៀតណាមមានប្រជាជនរស់នៅតែ៥០លានប៉ុណ្ណោះ ។ យើងមិនចាំបាច់យកប្រជាជនទាំង៨លានទៅវាយទេ ។ យើងត្រូវការតែ២លាននាក់វាគ្រប់គ្រាន់បាត់ទៅហើយក្នុងការវាយកម្ទេចវៀតណាម៥០លាននាក់នេះ វាយហើយយើងនៅសល់៦លាននាក់ទៀតឯណោះ ។ ដើម្បីជោគជ័យបាន យើងត្រូវចាត់ចែងរៀបចំមាគ៌ាប្រយុទ្ធរបស់យើងតាមផ្លូវនេះ ។ នេះជាមាគ៌ាប្រយុទ្ធដែលនឹងត្រូវអនុវត្តនៅសមរភូមិ ។ យើងត្រូវអនុវត្តទិសស្លោក១ទល់នឹង៣០ ។ ប្រសិនបើយើងមិនអាចអនុវត្តទិសស្លោកនេះទេ យើងនឹងមិនអាចទទួលជោគជ័យឡើយ ។ បញ្ហានេះមិនពាក់ព័ន្ធកងកម្លាំងប្រដាប់អាវុធតែមួយមុខទេ ។ បក្ស កងទ័ពនិងប្រជាជនទាំងមូល ត្រូវជ្រាបឲ្យបានច្បាស់អំពីមាគ៌ា ទស្សនៈនិងគោលជំហរទាំងនេះ ។ ក្នុងការយកជ័យជម្នះតើឥឡូវនេះយើងបានអនុវត្តមាគ៌ាយុទ្ធសាស្ត្រយ៉ាងណាខ្លះហើយ? និយាយឲ្យខ្លី គោលដៅ១ទល់នឹង៣០ត្រូវបានសម្រេចហើយ... ។

តើវៀតណាមវាយយើងនៅថ្ងៃអនាគតតាមរបៀបណាហើយយើងត្រូវដោះស្រាយយ៉ាងដូចម្តេច? យើងត្រូវប្រមើលហេតុការណ៍ដែលអាចកើតឡើងនៅពេលខាងមុខ ។ ដើម្បីធ្វើដូច្នេះបានលុះត្រាតែពិនិត្យព្រឹត្តិការណ៍កាលពីអតីត និងសម្លឹងមើលទៅអនាគត ។ តើវៀតណាមធ្លាប់វាយឈ្នះយើងទេកាលពីពេលកន្លងទៅនេះ? វៀតណាមមានបំណងចង់ប្រែក្លាយកម្ពុជាឲ្យទៅជាប្រទេសរណបរបស់ខ្លួនតាំងពីឆ្នាំ១៩៣០មកម្ល៉េះ ។ នៅឆ្នាំ១៩៤៥ យើងចូលរួមវាយបារាំង ។ វៀតណាមពេល

នោះចង់កាន់កាប់និងដាក់ប្រទេសយើងជាចំណុះវា ។ តើវៀតណាមបានសម្រេចទេ? ទេ! មិនបានសម្រេចទេ ។ តើវៀតណាមបានជោគជ័យក្នុងការកាន់កាប់កម្ពុជាក្នុងឆ្នាំ១៩៥០ ១៩៦០ ១៩៧០ និង១៩៧៥ ដែរឬទេ? ទេ! មិនបានជោគជ័យទេ ។ មូលហេតុនេះហើយបានជាយើងមិនចង់ប្រកាន់យកទស្សនៈចុះចាញ់និយម ។ យើងត្រូវរំឭកមើលប្រវត្តិសាស្ត្ររបស់យើង ។ តើវៀតណាមលេបទឹកដីយើងបានទេ? ទេ! មិនបានទេ ។ វៀតណាមចង់លេបយើង ប៉ុន្តែមិនបានសម្រេចតាមបំណង ។ វៀតណាមបានចូលចរចានៅឆ្នាំ១៩៧៥ ក្នុងគោលបំណងលេបយើង ប៉ុន្តែមិនអាចទៅរួច ។ វាបានព្យាយាមម្តងទៀតនៅឆ្នាំ១៩៧៥ ។ ផែនការរបស់វៀតណាមគឺវាយយកព្រៃនគរ (សៃហ្គន,ហូជីមិញ) មុនគេបន្ទាប់មកវាយប្រហារភ្នំពេញដើម្បីត្រួតត្រាយើង ។ ពេលនេះទៀតសោត វៀតណាមនៅពីក្រោយយើងមួយជំហាន ។ កម្ពុជាទទួលជ័យជម្នះមុនវៀតណាម ។ ក្រោយពីជ័យជម្នះ វៀតណាមចង់ធ្វើរដ្ឋប្រហារ ហើយបានវាយប្រហារមកលើយើង ។ ប៉ុន្តែត្រូវបរាជ័យជាថ្មីម្តងទៀត ។ វៀតណាមត្រូវបានធ្វើឲ្យបរាជ័យនៅក្នុងឆ្នាំ១៩៧៥ ១៩៧៦ ហើយនៅឆ្នាំ១៩៧៧ម្តងទៀត ។ ហើយការវាយប្រហាររបស់វៀតណាមកាលពីខែមេសាឆ្នាំ១៩៧៨ក៏ត្រូវបរាជ័យទៀត ។

ដូច្នេះយើងត្រូវអានប្រវត្តិសាស្ត្រនិងមានការជឿជាក់ ហើយយើងមិនត្រូវជឿការភូតភរនិងការបន្លកការភាន់ច្រឡំនៅក្នុងចំណោមប្រជាជនដែលថាតើប្រជាជនកម្ពុជាមានតែ៨លាន ធ្វើម្តេចនឹងវាយឈ្នះវៀតណាមដែលមានប្រជាជនទៅដល់ ៥០លាននាក់នោះ ។ យើងមិនត្រូវជឿទេថាយើងមិនអាចវាយឲ្យវៀតណាមបរាជ័យដោយសារតែយើងមានកងទ័ព១សែននាក់ទល់នឹងទ័ពវៀតណាម១លាននាក់... ។

តើត្រូវដោះស្រាយយ៉ាងដូចម្តេចចំពោះបញ្ហាប្រើកម្លាំងតូចវាយកម្លាំងធំ? ការដឹងពីរបៀបប្រើឥទ្ធិពលវាយកម្លាំងធំជាការសំខាន់ណាស់សម្រាប់កម្លាំងតូច ដូចលើកឡើងខាងលើមកហើយគឺ១ទល់នឹង៣០ ។ បើយើងអាចប្រើកម្លាំង១នាក់ទប់ទល់នឹងកម្លាំង៣០នាក់ យើងប្រាកដជាឈ្នះ ទោះបីជាការវាយប្រយុទ្ធមានរយៈពេល៧០០ឆ្នាំឬក៏ច្រើនជាងនេះក៏ដោយ ។ ប៉ុន្តែបើយើងមិនដើរតាមមាគ៌ានេះទេ យើងមិនអាចទទួលជោគជ័យបានទេ ។ ដូច្នេះយើងត្រូវ÷ ១) ដាច់ខាតការពារទឹកដីយើង ។ ការពារទឹកដីខ្មែរមានន័យថាការពារជាតិខ្មែរ ។ ប្រសិនបើវៀតណាមកាន់កាប់ទឹកដីកម្ពុជាបានសម្រេច នោះជាតិខ្មែរនឹងត្រូវបាត់ស្រមោលនៅក្នុងអំឡុង៣០ឆ្នាំខាងមុខ ។ ដូច្នេះជាការសំខាន់ណាស់ក្នុងការការពារប្រទេសកម្ពុជា ។ ២) យើងត្រូវជឿជាក់ក្នុងចិត្តថាយើងពិតជាអាចវាយវៀតណាមបាន ។ ៣) តើវាយវៀតណាមតាមរបៀបណា? យើងត្រូវយល់ដឹងពីវិធីកម្លាំងតូចវាយកម្លាំងធំ ។ យើងត្រូវប្រើ១នាក់ទល់នឹង៣០នាក់ ។ នេះជាចំនួនដែលកំណត់ដោយបក្ស ប៉ុន្តែតាមការអនុវត្តជាក់ស្តែងសមមិត្តយើងមួយចំនួនវាយ១នាក់ទល់នឹង១០នាក់ ។ អ្នកខ្លះវាយ១ទល់នឹង១០ ឬ១ទល់នឹង៥ ។ អ្នកខ្លះទៀត១ទល់នឹង២០ ហើយមានខ្លះទៀតរហូតដល់១ទល់នឹង៥០ឬ១០០ផង ។ តែមិនថ្មីទេ ទោះជាប៉ុន្មានក៏ដោយ វាមិនមែនជាបញ្ហាទេ ។ វានៅតែជោគជ័យតែដដែល ។ នេះជាមាគ៌ាប្រយុទ្ធ ។ អនុវត្តមាគ៌ាប្រយុទ្ធគឺអនុវត្តវិទ្យាសាស្ត្រសង្គ្រាមប្រជាជនដើម្បីដោះស្រាយទំនាស់ ពីព្រោះយើងត្រូវប្រើកម្លាំងតូចវាយកម្លាំងធំ ។ យើងទទួលបានជ័យជម្នះពីព្រោះយើងដោះស្រាយទំនាស់បានត្រឹមត្រូវ ។ នេះជាអ្វីដែលកើតឡើងកាលពីអតីតកាលនិងកំពុងតែកើតឡើងនៅពេលបច្ចុប្បន្ន ។

តើយើងត្រូវធ្វើអ្វីទៅថ្ងៃអនាគត? យើងត្រូវ÷ ១) ជឿជាក់ថាយើងនឹងអាចបន្តប្រយុទ្ធឲ្យបានជោគជ័យដូចកាលពីអតីតកាល ។ ២) មានជំនឿទុកចិត្តក្នុងការអនុវត្តមាគ៌ាប្រយុទ្ធដដែល ពោលគឺ១ទល់នឹង៣០ ។ អង្គភាពខ្លះត្រូវវាយ១ទល់នឹង៤០ ហើយអង្គភាពខ្លះទៀតវាយ១ទល់នឹង៥០ ។

នៅក្នុងការវាយយួនឈ្លានពានកាល៣-៤ខែកន្លងទៅនេះ កងកម្លាំងរបស់យើងបានរីកធំធាត់យ៉ាងច្រើន ពោលគឺកើនឡើង៤ដង៦ណោះ ។ នេះជាការប្រែប្រួលទីមួយ ។ ការប្រែប្រួលទីពីរគឺថាចំនួនកម្មាភិបាលក៏កើនឡើងដែរ ។ ដើម្បីបង្កើនកម្លាំងប្រដាប់អាវុធ ចាំបាច់ត្រូវមានកម្មាភិបាល ។ មួយខែពីរខែ

ក្រោយពីការប្រយុទ្ធគ្នាមក កម្មាភិបាលរបស់យើងអាចបញ្ជាវរសេនាតូចបាន ។ មួយខែពីរខែក្រោយទៀតនឹងអាចកាន់វរសេនាធំ ហើយអ្នកដែលនៅវរសេនាធំអាចកាន់ការកងពលធំទៀត ។ យើងបានប្រើកម្មាភិបាលយោធាក្នុងការពង្រីកកងទ័ពនៅទូទាំងប្រទេស ។ ហេតុដូច្នេះហើយបានជាកងទ័ពយើងអាចម្ចាស់ការលើសភាពការណ៍ចាប់ពីកន្ទុយនាគពោលគឺចាប់ពីចុងម្ខាងរហូតដល់ចុងម្ខាងទៀតនៃខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទួល មេមត់ ព្រៃវែង រមាសហែក ស្វាយរៀង កណ្តាល តាកែវ និងកំពត ។ យើងអាចកម្ទេចវរសេនាធំរបស់ខ្មាំងដែលវាយយើងក្នុងខ្សែត្រៀមចំនួនមួយថ្ងៃពីរថ្ងៃ ។

ហេតុអ្វីបានជាកងកម្លាំងប្រដាប់អាវុធយើងមានអំណាចខ្លាំងម្ល៉េះ? គឺដោយសារកម្មាភិបាលយោធាយើងខ្លាំង ។ កម្មាភិបាលយោធាខ្លាំងធ្វើឲ្យយុទ្ធជនខ្លាំង ពីព្រោះយុទ្ធជនស្ថិតនៅក្រោមការដឹកនាំរបស់កម្មាភិបាល ។ ហេតុអ្វីបានជាកម្មាភិបាលទាំងនេះខ្លាំងម្ល៉េះ? ពីព្រោះគេជាកម្មាភិបាលយោធាដែលត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវតាមមាគ៌ារបស់បក្សនិងជាអ្នកអនុវត្តមាគ៌ាកម្មាភិបាលបរិសុទ្ធ ។ កម្មាភិបាលទាំងនេះពិតជាមានអំណាចខ្លាំងណាស់ ។ គេមានអំណាចខ្លាំងប៉ុន្តែមិនដែលចូលប្រឡូកក្នុងសមរភូមិដោយគ្មានរៀបចំផែនការច្បាស់លាស់នោះទេ ។ កម្មាភិបាលទាំងនេះមានអំណាច ហើយ


កងទ័ពខ្មែរក្រហម

អាចវាយយ៉ាងប្រសិទ្ធភាព ។ គេទទួលបានជោគជ័យក្នុងការរក្សាកម្លាំងបានច្រើនហើយកម្ទេចកម្លាំងខ្មាំងអស់ជាច្រើន ។ កម្លាំងរបស់យើងវាយប្រយុទ្ធដូចនេះ ។ កម្មាភិបាលរបស់យើងមិនដែលរួញរាម្តងណាឡើយ ។ ដើម្បីវាយខ្មាំងឲ្យដូចនេះទី១កម្មាភិបាលត្រូវប្រកាន់ជំហរខ្លាំងនិងដាច់ខាត ហើយទី២ប្រកាន់នូវមាគ៌ាប្រយុទ្ធដ៏ត្រឹមត្រូវនិងប្រកាន់ខ្ជាប់នូវគំនិតមានវត្តមានជាអចិន្ត្រៃយ៍របស់មេបញ្ជាការនៅក្នុងអង្គភាពរបស់ខ្លួននិងនៅសមរភូមិ ។ មេបញ្ជាការអង្គភាពត្រូវមានវត្តមាននៅមុខសញ្ញាដើម្បីក្តាប់សភាពការណ៍នៅសមរភូមិប្រយុទ្ធ ដូចជានៅសមរភូមិ កំពត តាកែវ និងខ្សែត្រៀមភាគខាងកើត ។ មេបញ្ជាការត្រូវមានវត្តមានជានិច្ចដើម្បីងាយស្រួលនៅពេលខ្មាំងវាយយើងយើងអាចចាត់តាំងភ្លាមៗ ហើយឲ្យអង្គភាពវាយបកទាន់សភាពការណ៍ ព្រមទាំងអាចចាត់តាំងឲ្យអង្គភាពដេញតាមខ្មាំងនៅពេលយើងកម្ទេចពួកវាហើយ ។ នៅពេលខ្មាំងបេះតែរត់មិនឈប់ យើងអាចបញ្ជាឲ្យក្រុមនិងអង្គភាពយើងដេញតាមពួកវា ។ យើងដេញតាមក្រោយនិងវាយប្រហារកម្លាំងខ្មាំងរហូតដល់ពួកវារត់តាមផ្លូវណាមួយនឹងកាត់តាមព្រំដែន ។ នេះជាអ្វីដែលយើងហៅថាការវាយប្រហារដូចនេះបាញ់ ។



កងកម្លាំងទាំងអស់ត្រូវតែប្រុងប្រយ័ត្នដាច់ខាត ។ ខ្មាំងមិនត្រូវតវ៉ាបានទេ ពីព្រោះការបញ្ជារបស់យើងប្រព្រឹត្តទៅដោយមានការប្រុងប្រយ័ត្នជាប់ជានិច្ច ។ នៅពេលមានការប្រុងប្រយ័ត្នយ៉ាងនេះ មិនចាប់បាច់មានបញ្ជាមកពីកងពលធំទៅវរសេនាធំ វរសេនាតូចនិងទៅអនុសេនាធំទេ ។ ប្រសិនបើយើងនៅចាំតែរបាយការណ៍ពីកងអនុសេនាតូចផ្ញើមកអនុសេនាធំពីអនុសេនាធំទៅវរសេនាតូច ពីវរសេនាតូចទៅវរសេនាធំ និងពីវរសេនាធំទៅកងពលធំ ហើយនៅពេលមានបញ្ជាមកពីកងពលធំត្រូវឆ្លងកាត់អង្គភាពទាំងប៉ុន្មានដដែលជាដដែលនេះ នឹងធ្វើឲ្យខ្មាំងមានឱកាសក្នុងការរៀបចំវាយយើងមិនខាន ។ នៅពេលយើងរវល់តែសរសេរផែនការ កម្លាំងរបស់ខ្មាំងអាចនឹងរៀបចំវាយយើងសាជាថ្មីទៀត ។

យើងត្រូវមានជំនឿជាក់ទៅលើមហាជន ប្រជាជន កម្លាំងប្រដាប់អាវុធ បក្ស មាគ៌ា សង្គ្រាមប្រជាជន និងមាគ៌ាប្រយុទ្ធ ។ នៅពេលខ្មាំងទោះជិតឬឆ្ងាយ ធ្វើយុទ្ធនាការឃោសនាបោកបញ្ឆោតយើង ហើយធ្វើឲ្យយើងខ្លាចខ្មាំង យើងត្រូវតែវាយបកវិញ ។ យើងមិនត្រូវឲ្យមេរោគនេះ វាយប្រហារទៅលើប្រជាជនមហាជន បក្ស ឬកងកម្លាំងប្រដាប់អាវុធយើងបានទេ ។ យើងត្រូវសម្រិតសម្រាំងកងកម្លាំងប្រដាប់អាវុធយើង បក្សយើង និងមហាជនប្រជាជន ដើម្បីបន្តវាយខ្មាំងតទៅទៀតក្នុងការការពារទឹកដីកម្ពុជានិងជាតិសាសន៍ខ្មែរ ព្រោះបើយើងមិនធ្វើដូច្នេះទេ ជាតិសាសន៍យើងនឹងត្រូវបាត់បង់អស់ជាមិនខាន ។

វៀតណាមនឹងនាំយកជនជាតិវា១លានឬ២លាននាក់

ចូលមកទឹកដីយើងរាល់ឆ្នាំ នៅពេលនោះយើងនឹងបាត់បង់ទឹកដី ហើយជាតិយើងនឹងត្រូវវាលេបត្របាក់យកអស់មិនខាន...។

វៀតណាមគិតថាខ្លួននឹងអាចយកចំណេញនូវអ្វីដែលយើងបានធ្វើ ប៉ុន្តែតាមការពិតសកម្មភាពទាំងនេះបានត្រឹមបញ្ឆេះកំហឹងប្រជាជននិងកងកម្លាំងប្រដាប់អាវុធយើងតែប៉ុណ្ណោះ ។ ហើយ នេះពិតជាពង្រឹងបដិវត្តន៍យើងកាន់តែខ្លាំងឡើង ។ វៀតណាមមិនអាចធ្វើឲ្យបដិវត្តយើងចុះខ្សោយបានទេ ។ វៀតណាមអាចធ្វើឲ្យបដិវត្តន៍យើងចុះខ្សោយប្រសិនបើយើងចុះចាញ់ ប៉ុន្តែយើងមិនចុះចាញ់ទេ បែរជាកាន់តែខ្លាំងទៅវិញ ។ យើងអាចការពារប្រទេសយើង និងអាចធ្វើអ្វីៗគ្រប់យ៉ាង ។ ប៉ុន្តែយើងគ្រាន់តែអនុវត្តការងារកសាងតែប៉ុណ្ណោះដោយសារកម្ពុជាត្រូវបានថែរក្សាការពារហើយ ។ បើយើងបាត់បង់កម្ពុជាទៅ តើយើងមានការងារកសាងឯណាទៀត? ដូច្នេះដោយសារយើងបានជោគជ័យក្នុងការការពារកម្ពុជា យើងប្រាកដជាអាចធ្វើអ្វីៗគ្រប់បែបយ៉ាង ។

## គណៈប្រតិភូបក្សសង្គមនិយមជប៉ុននៅក្នុងប្រទេសកូរ៉េ

*ដកស្រង់ពីរបាយការណ៍*

គណៈប្រតិភូមួយក្រុមនៃបក្សសង្គមនិយមជប៉ុនបានចេញដំណើរទៅទីក្រុងព្យុងយ៉ាងតាមជើងយន្តហោះ Khabarov ដើម្បីមកធ្វើទស្សនកិច្ចដោយសុឆន្ទៈចំនួនមួយសប្តាហ៍នៅប្រទេសកូរ៉េ ។ នេះជាគណៈប្រតិភូលើកទី៥ ហើយដែលបញ្ជូនមកដោយបក្សសង្គមនិយមជប៉ុន និងជាលើកទីមួយនៅក្នុងរយៈពេល៤ឆ្នាំដែលប្រធានបក្សមកធ្វើទស្សនកិច្ចនៅទីក្រុងព្យុងយ៉ាង ។

គណៈប្រតិភូបានមកដល់ទីក្រុងព្យុងយ៉ាងនាថ្ងៃទី១១ ខែឧសភា ដើម្បីមកធ្វើទស្សនកិច្ចនៅប្រទេសកូរ៉េខាងជើងតាមសេចក្តីអញ្ជើញរបស់គណៈកម្មាធិការមជ្ឈិមបក្សពលករកូរ៉េ ។ គណៈប្រតិភូនេះដឹកនាំដោយលោក អ៊ីជីអូ អាស៊ូកាគា ប្រធានគណៈកម្មាធិការមជ្ឈិមបក្សសង្គមនិយមជប៉ុន ជាមួយលោក ណូបូរូ អាគូណេ អនុប្រធានគណៈកម្មាធិការមជ្ឈិមបក្សសង្គមនិយមជប៉ុន ក្នុងឋានៈជាអនុប្រធានគណៈប្រតិភូ និងលោក តាមីអូ កាវ៉ាកាមិ សមាជិកគណៈកម្មាធិការមជ្ឈិមបក្សសង្គមនិយមជប៉ុន និងប្រធាននាយកដ្ឋានអន្តរជាតិ ក្នុងឋានៈជាលេខាទូទៅ ។ សមាជិកដទៃទៀតរួមមាន តេតស៊ូ អ៊ីដា សមាជិកគណៈកម្មាធិការមជ្ឈិមបក្សសង្គមនិយមជប៉ុន និងជាប្រធាននាយកដ្ឋានអប់រំនិងឃោសនាការ លោក តូហ៊្គោ យ៉ុនដា ប្រធានគណៈកម្មាធិការពិសេសទទួលបន្ទុកកិច្ចការកូរ៉េនៃគណៈកម្មាធិការមជ្ឈិមបក្សសង្គមនិយមជប៉ុន និងលោក ស៊ីកេយុគី ហ៊ិុនណាបាស៊ី សមាជិកគណៈកម្មាធិការមជ្ឈិមបក្សសង្គមនិយមជប៉ុន ។

គណៈប្រតិភូត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់នៅព្រលានយន្តហោះដោយសមមិត្ត ប៉ាក សុង កូល និងលោក គីម យុង ណាម ព្រមទាំងឥស្សរជនមួយចំនួនទៀតដូចជា គីម វ៉ាន់ ស៊ុប, សូ យុន សុខ, គីម ពង់ ដូ, ឈី ជី យ៉ុង, យ៉ុន ឈុន គុក, ឈុ ជុង សាម, និង ជូ ឆាង ឈុ ន ។

គណៈកម្មាធិការមជ្ឈិមនៃបក្សពលករកូរ៉េបានរៀបចំពិធីជប់លៀងមួយជាកិត្តិយសដល់គណៈប្រតិភូនាថ្ងៃទី១១ខែឧសភា ។ លោក ប៉ាក សុង កូល និង អ៊ីជីអូ អាស៊ូកាគា បានឡើងថ្លែងសុន្ទរកថាក្នុងឱកាសនោះ ។ ពិធីជប់លៀងប្រព្រឹត្តទៅក្នុងបរិយាកាសស្រស់ស្រាយពោរពេញទៅដោយមិត្តភាព ។

នៅថ្ងៃទី១២ខែឧសភា គណៈប្រតិភូនៃគណៈកម្មាធិការមជ្ឈិមបក្សសង្គមនិយមជប៉ុនបានជួបសន្ទនាជាមួយគណៈប្រតិភូកូរ៉េខាងជើងដែលមានសមមិត្ត ប៉ាក សុង កូល និងលោក គីម យុង ណាម ព្រមទាំងឥស្សរជនមួយចំនួនទៀតដូចជា គីម វ៉ាន់ ស៊ុប, យ៉ុន ឈុន គុក និង ជូ ចាង ឈុន ។ គណៈប្រតិភូទាំងពីរក្រុមបានពិភាក្សាផ្លាស់ប្តូរយោបល់ស្តីអំពីការអភិវឌ្ឍទំនាក់ទំនងមិត្តភាពនិងសហប្រតិបត្តិការរវាងភាគីទាំងពីរនិងប្រជាជនទាំងពីរជប៉ុន-កូរ៉េ និងអំពីការពង្រឹងការជួយគាំទ្រគ្នាទៅវិញទៅមក និងសាមគ្គីភាព ព្រមទាំងពិភាក្សាអំពីបញ្ហាពាក់ព័ន្ធទៅវិញទៅមក ។ គណៈប្រតិភូបានយល់ស្របគ្នាលើបញ្ហាដែលបានលើកមកពិភាក្សាខាងលើ ។ កិច្ចសន្ទនាគ្នាបានប្រព្រឹត្តទៅក្នុងបរិយាកាសរីករាយនិងមិត្តភាព ។ គណៈប្រតិភូបានពិភាក្សាអំពីសភាពការណ៍នៅអាស៊ី ។ ហើយក្រោយមកបានទស្សនាការសម្តែងសិល្បៈ ម្នាស់សុងសួគ៌ា "The Song of Paradise" នៅរោងល្ខោនមែនស៊ូដេ ។


ហ៊ុយ វណ្ណៈ ឆ្នាំ១៩៨៩

# បាត់បងប្រុសជាងម្ភៃឆ្នាំហើយ

រាល់ពេលដែលរំឭកទៅដល់ជីវិតគ្រួសាររបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហម ម្តាយខ្ញុំតែងតែបង្ហូរទឹកភ្នែក ។ ខ្ញុំដឹងថានៅក្នុងអារម្មណ៍របស់ម្តាយខ្ញុំមានការសោកស្តាយនិងអាឡោះអាល័យយ៉ាងខ្លាំងដល់បងប្រុសម្នាក់របស់ខ្ញុំដែលបានវង្វេងព្រាត់ប្រាសគ្នានៅចុងឆ្នាំ១៩៧៨ ។ រហូតមកទល់សព្វថ្ងៃនេះ គ្រួសារខ្ញុំមិនដែលបានឮដំណឹងអ្វីបន្តិចសោះអំពីបងប្រុសរបស់ខ្ញុំ ។ តើការព្រាត់ប្រាសនេះ ជារឿងព្រហ្មលិខិតឬយ៉ាងណា?

ក្នុងពេលដែលខ្មែរក្រហមកាន់កាប់អំណាច ខ្ញុំមិនទាន់ដឹងក្តីនៅឡើយទេ ។ ក្នុងចំណោមសមាជិកគ្រួសាររបស់ខ្ញុំ ប្រហែលមានតែខ្ញុំម្នាក់គត់ដែលមានសំណាង ពីព្រោះខ្ញុំមិនដែលបានទៅធ្វើការនៅការដ្ឋានឆ្ងាយៗ ។ ខ្ញុំកើតនៅពាក់កណ្តាលឆ្នាំ១៩៧៨ ក្នុងមន្ទីរពេទ្យខ្មែរក្រហមនៅក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ។

នៅពេលដែលគ្រួសាររបស់ខ្ញុំបានជួបជុំគ្នាម្តងៗ ម្តាយខ្ញុំតែងតែរំឭកឡើងវិញអំពីរឿងរ៉ាវគ្រួសាររបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំនៅចាំបានថា នៅពេលដែលម្តាយខ្ញុំនិយាយឡើងវិញម្តងៗ តែងតែមានរឿងរ៉ាវប្លែកៗជានិច្ច ។ របបខ្មែរក្រហមមានរយៈពេលជាង៣ឆ្នាំសោះ ក៏ប៉ុន្តែមានរឿងរ៉ាវជាច្រើនដែលបានកើតឡើងមកលើគ្រួសារខ្ញុំ ។

ម្តាយខ្ញុំបាននិយាយថា នៅក្នុងរបបខ្មែរក្រហម គ្រួសាររបស់ខ្ញុំមានសមាជិកប្រាំពីរនាក់ ។ ម្នាក់ៗមានភារកិច្ចរៀងៗខ្លួន ។ ឪពុករបស់ខ្ញុំត្រូវទៅកាត់ដេរសម្លៀកបំពាក់នៅមន្ទីរឃុំ ។ ចំណែកឯម្តាយខ្ញុំត្រូវទៅធ្វើអង្ករនៅកងម៉ែៗ ។ បងប្រុសទី១ (សុជាត) និងបងស្រីទី២ (ផល្លា) របស់ខ្ញុំនៅកងចល័តកុមារ ។ បងប្រុសទី១ត្រូវអង្គការចាត់តាំងឲ្យទៅលើកទំនប់នៅស្រុកអង្គរបូរី ។ ការដ្ឋានលើកទំនប់នៅឆ្ងាយពីផ្ទះរបស់ខ្ញុំជាង១០គីឡូម៉ែត្រ ។ ពីរឬបីខែម្តងទើបគាត់បានមកលេងផ្ទះ ។ កាលនោះបងប្រុសខ្ញុំមានអាយុ១៨ឆ្នាំ ។ គាត់មានរាងកាយស្គម ហើយពោរពេញទៅដោយក្អែលដែលដុសស៊ើរមិនចេញ ។ សក់គាត់វែងហើយកើតសុទ្ធតែចៃ ។ ម្តាយខ្ញុំបានកាត់សក់ឲ្យបងប្រុសរបស់ខ្ញុំរាល់ពេលដែលគាត់មកលេងផ្ទះ ។

បងស្រីទី១របស់ខ្ញុំមានអាយុ១១ឆ្នាំ ។ អង្គការបានចាត់តាំងគាត់ឲ្យដើរកាប់ដើមទន្ទ្រានខែត្រនៅក្បែរៗភូមិ ។ ពេលថ្ងៃគាត់ហូបបបរនៅតាមកងកុមារ ។ នៅពេលយប់គាត់បានមកសម្រាកនៅផ្ទះវិញ ។ ថ្ងៃមួយនោះ នៅពេលដែលបងស្រីខ្ញុំកាន់ចានទៅដួសបបរ ស្រាប់តែមានកុមារម្នាក់ទៀតបានធ្វើឲ្យបបររលាកគាត់យ៉ាងខ្លាំងរហូតដល់ក្លាយជាដំបៅ ។ នៅពេលដែលគាត់ទៅធ្វើការលែងកើតទើបគាត់ប្រាប់ម្តាយខ្ញុំឲ្យដឹង ។ បងស្រីខ្ញុំត្រូវហុតតែទឹកបបរស្ទើរតែរៀងរាល់ពេល ពីព្រោះគាត់ចូលទៅដួសបបរមិនទាន់ ។ ម្តាយខ្ញុំតែងតែលាក់បាយនៅចង្កេះខោមកឲ្យបងស្រីខ្ញុំជានិច្ច ។

បងប្រុសទី៣ (សុភ័ក្រ) របស់ខ្ញុំមានអាយុ៦ឆ្នាំ និងបងប្រុសទី៤ (វណ្ណាត) មានអាយុ៥ឆ្នាំ ។ គាត់ទាំងពីរនាក់ត្រូវទៅរស់នៅក្នុងមណ្ឌលកុមារដែលមានដូនចាស់ម្នាក់មើលការខុសត្រូវ ។ មណ្ឌលកុមារស្ថិតនៅចម្ងាយពីផ្ទះខ្ញុំប្រមាណ៣គីឡូម៉ែត្រ ។ ការងាររបស់គាត់ទាំងពីរនាក់គឺរែកអាចម៍គោ ។

នៅពេលថ្ងៃគាត់ចេញទៅធ្វើការ ហើយនៅពេលយប់ត្រូវចូលទៅដេកនៅក្នុងមណ្ឌលកុមារវិញ ។ បងប្រុសខ្ញុំទាំងពីរនាក់រស់នៅជាមួយកុមារដែលមានអាយុស្របាលគាត់រាប់រយនាក់ ។ កុមារទាំងនោះរស់នៅដោយគ្មានសណ្តាប់ធ្នាប់ ។ ជារឿយៗបងប្រុសខ្ញុំទាំងពីរនាក់ចេញទៅធ្វើការដោយគ្មានអាវពាក់ ។ នៅពាក់កណ្តាលអធ្រាត្រ បងប្រុសខ្ញុំទាំងពីរនាក់តែងតែបបួលគ្នាលួចរត់ចេញពីមណ្ឌលកុមារមកដេកនៅផ្ទះជាមួយឪពុកម្តាយខ្ញុំ ហើយមេឃជិតភ្លឺទើបគាត់រត់ទៅមណ្ឌលកុមារវិញ ។ បងប្រុសទាំងពីររបស់ខ្ញុំនិយាយប្រាប់ម្តាយខ្ញុំថា នៅក្នុងមណ្ឌលកុមារគាត់ពិបាកដេកណាស់ពីព្រោះនៅទីនោះសម្បូរសត្វសង្កើច ។ នៅពេលយប់ កុមារដេកនោមដាក់គ្នាដោយមិនដឹងខ្លួន ។ ដោយសារតែហូបមិនគ្រប់គ្រាន់ បងប្រុសខ្ញុំទាំងពីរបានលួចប្រហុកហូបជាមួយចេកខ្ចី ។ ម្តាយខ្ញុំធ្លាប់ទទួលការស្តីបន្ទោសពីប្រធានមណ្ឌលជាញឹកញាប់ដោយសារតែបងប្រុសខ្ញុំទាំងពីរនាក់ ។

ជីតារបស់ខ្ញុំ (ជីតាខាងម្តាយ) មិនអាចធ្វើការបានទេពីព្រោះគាត់មានជំងឺស្លាប់មួយចំហៀងខ្លួន ។ ឆ្លៀតពេលសម្រាកពីការងារនៅវេលាថ្ងៃត្រង់ ម្តាយខ្ញុំបានរត់ពីកន្លែងធ្វើអង្ករដើម្បីមកដោះដូរសម្លៀកបំពាក់និងបញ្ចុកបបរជីតារបស់ខ្ញុំ ។ តិចពេលណាស់ដែលឪពុកខ្ញុំបានមកជួយមើលថែទាំជីតាខ្ញុំ ។ ឪពុកខ្ញុំបានចោះរនាបផ្ទះនិងចងខ្សែព្រួរទុកសម្រាប់ជីតាខ្ញុំនៅពេលដែលគាត់ត្រូវការបត់ជើងម្តងៗ ។ ពីមួយថ្ងៃទៅមួយថ្ងៃជំងឺរបស់ជីតាខ្ញុំកាន់តែធុនធាបទៅ ។ ដៃជើងរបស់គាត់ហើមដោយសារខ្វះជាតិអាហារ ។ ម្តាយឪពុកខ្ញុំគ្មានលទ្ធភាពនឹងរកថ្នាំមកព្យាបាលជំងឺរបស់ជីតាខ្ញុំទេ ។ ជីតាខ្ញុំកាន់សីលតាំងពីមុនសម័យខ្មែរក្រហម ក៏ប៉ុន្តែសីលមិនអាចទប់ទល់នឹងសេចក្តីស្រេកឃ្លានបានឡើយ ។ នៅពេលឃើញមាន់កំពុងដើរនៅខាងមុខផ្ទះជីតារបស់ខ្ញុំបានប្រាប់ម្តាយខ្ញុំថា«ចង់ហូបសាច់មាន់» ។ ម្តាយខ្ញុំមានលទ្ធភាពត្រឹមតែសុំស្ករត្នោតពីរោងសហករណ៍យកមកឲ្យជីតាខ្ញុំពិសាជំនួសសាច់មាន់នៅមុនពេលដែលគាត់លាចាកលោកនេះទៅប៉ុណ្ណោះ ។

នៅយប់មួយក្នុងឆ្នាំ១៩៧៧ កងឈ្លបបានមកគោះទ្វារផ្ទះហៅឪពុកខ្ញុំ ។ ម្តាយខ្ញុំភ័យយ៉ាងខ្លាំងដោយនឹកគិតថាកងឈ្លបនឹងយកឪពុកខ្ញុំទៅសម្លាប់ ។ បន្ទាប់ពីឪពុកខ្ញុំបើកទ្វារ កងឈ្លបបានហៅឈ្មោះ«ប្រជាជន១៧មេសា»ដែលមកស្នាក់នៅផ្ទះជាមួយឪពុកម្តាយខ្ញុំឲ្យចុះដី ។ ប្រជាជន១៧មេសាដែលមានសមាជិក៤នាក់បានមកស្នាក់នៅជាមួយគ្រួសារខ្ញុំក្រោយពេលដែលខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញនៅថ្ងៃ១៧មេសា ១៩៧៥ ។ កងឈ្លបបានចាប់ចងមនុស្សទាំង៤នាក់បណ្តើរចេញពីភូមិបាត់ទៅ ។ គ្មាននរណាអាចជួយនរណាបានទេ សូម្បីតែខ្លួនឯងក៏មិនអាចជួយជីវិតខ្លួនឯងបានផង ។ ខ្មែរក្រហមមានទ្រឹស្តីថា «ក្បាលអ្នកណា សក់អ្នកហ្នឹង» ។

នៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយលុកយ៉ាងខ្លាំងដើម្បីផ្តួលរំលំរបបខ្មែរក្រហម ។ ខ្មែរក្រហមបានកេណ្ឌប្រជាជនទាំងអស់ទៅព្រំដែនថៃ ។ គ្រួសារនិងសាច់ញាតិរបស់ខ្ញុំទាំងអស់បានធ្វើដំណើរឆ្ពោះទៅទិសខាងលិចជាមួយអ្នកស្រុកជាច្រើនទៀត ។ ម្តាយខ្ញុំប្រាប់ថា នៅពេលនោះខ្ញុំមានអាយុ៦ខែ ។ កម្មាភិបាលខ្មែរក្រហមបាននិយាយថា «បើមិននាំគ្នារត់ឡើងភ្នំទេ កងទ័ពវៀតណាមមកដល់នឹងអារ-ក វះពោះប្រកស្មោ» ។ ដំណើរឆ្ពោះទៅទិសខាងលិចគ្មានអ្វីក្រៅពីចានឆ្នាំងអង្ករ និងបង្វេចបន្តិចបន្តួចដាក់តាមរទេះនោះឡើយ ។ គ្រួសារខ្ញុំបានធ្វើដំណើរដោយរទេះដែលអូសដោយគោម្នាងនិងម្នាងទៀតអូសដោយឪពុកខ្ញុំ ។ អ្វីដែលពិបាកបំផុតនៅក្នុងពេលធ្វើដំណើរគឺការខ្វះទឹក ។

នៅខណៈពេលដែលគ្រួសារខ្ញុំធ្វើដំណើរទៅដល់ខេត្តពោធិសាត់ កងរថក្រោះរបស់កងទ័ពវៀតណាមបានបាញ់ផ្លោងយ៉ាងខ្លាំងទៅលើកងទ័ពខ្មែរក្រហម ។ វេលាល្ងាចនោះប្រជាជនមានការជ្រួលច្របល់ដោយភ័យខ្លាចថាវៀតណាមចាប់អារ-ក ។ ឪពុកខ្ញុំទៅដឹកគោដើម្បីរៀបចំរទេះបន្តដំណើរទៅមុខទៀត ចំណែកឯម្តាយខ្ញុំដែលកំពុងដាំបាយមិនទាន់ឆ្អិនផងនោះបានក្រោកឈរស្រែកហៅបងខ្ញុំទាំងបួននាក់ ។ ឮសំឡេងហៅរបស់ម្តាយខ្ញុំ បងប្រុសទី១និងបងស្រីទី១ បាននាំគ្នាត្រឡប់មកវិញ ក៏ប៉ុន្តែបងប្រុសរបស់ខ្ញុំពីរនាក់ទៀតមិនបានត្រឡប់មកវិញទេ ។ ក្រុមគ្រួសាររបស់ខ្ញុំធ្វើដំណើរបណ្តើរសាកសួរពីដំណឹងបងប្រុសទាំងពីរបណ្តើរ ។ អ្នកស្រុកនិយាយថា «បងប្រុសខ្ញុំ

ទាំងពីរនៅខាងមុខៗ ។ ទោះបីជាឪពុកម្តាយ ពូមីង លោកតានិងលោកយាយ (ខាងឪពុក) របស់ខ្ញុំខិតខំតាមរកយ៉ាងណាក៏ដោយក៏នៅតែមិនបានជួបបងប្រុសរបស់ខ្ញុំ ។ ដោយសារតែបាត់បង់បងប្រុសទាំងពីរនាក់របស់ខ្ញុំ ឪពុកម្តាយនិងសាច់ញាតិខ្ញុំមិនបានបន្តដំណើរទៅមុខទៀតទេ ។ ឪពុកម្តាយខ្ញុំបានត្រឡប់មកភូមិស្រុកវិញដោយពាំនាំមកនូវក្តីអាឡោះអាល័យនិងការទន្ទឹងរង់ចាំ ។ បន្ទាប់ពីឪពុកម្តាយខ្ញុំត្រឡប់មកដល់ផ្ទះវិញមិនយូរប៉ុន្មានបងប្រុសទីពររបស់ខ្ញុំក៏បានត្រឡប់មកផ្ទះវិញដែរ ។

បងប្រុសទីពររបស់ខ្ញុំនិយាយថា នៅពេលដែលកងទ័ពវៀតណាមបាញ់ផ្លោងមក គាត់និងបងប្រុសទី៤បានដឹកដៃគ្នារត់ទៅមុខយ៉ាងលឿន ។ បន្ទាប់ពីស្ងប់ស្ងាត់រកាំភ្លើង គាត់ទាំងពីរនាក់បានត្រឡប់មករកឪពុកម្តាយវិញ ក៏ប៉ុន្តែយប់ទៅហើយគាត់មិនអាចរកឃើញទេ ។ បងប្រុសទី៤ពាក់អាវវែងត្រឹមជង្គង់ ចំណែកបងប្រុសទី៣គ្មានអាវពាក់ទេ ។ នៅយប់នោះមេឃត្រជាក់ខ្លាំងណាស់ ។ បងប្រុសខ្ញុំបានដោះយកអាវពីសាកសពដែលទើបនឹងស្លាប់ មកពាក់ដើម្បីទប់ទល់នឹងអាកាសធាតុត្រជាក់នៅក្នុងព្រៃ ។ បងប្រុសខ្ញុំទាំងពីរនាក់បានបន្តដំណើរឡើងភ្នំដើម្បីស្វែងរកឪពុកម្តាយ ។ បងប្រុសខ្ញុំទាំងពីរដើររើសឆ្អឹងគោមកហូបជំនួសបាយ ។ ដោយមិនអាចស៊ូទ្រាំនឹងការឡើងភ្នំ ជើងទាំងពីររបស់បងប្រុសទី៤ហើមរហូតដើរលែងរួច ។ បងប្រុសទី៣ដែលធំតែក្បាលពោះ បានខំប្រឹងអៀវបងប្រុសទី៤រហូតឡើងដល់កំពូលភ្នំ ។

បងប្រុសទី៣បានរំឭករឿងអតីតកាលថា អាកាសធាតុនៅលើកំពូលភ្នំនាពេលយប់ត្រជាក់ស្រឹប ។ ល្ងាចនោះគាត់ដើររកឆ្អឹងគោហូបមិនបានទេ ។ គាត់ទាំងពីរនាក់អង្គុយត្របោមក្បាលជង្គង់ពីមុខភ្នក់ភ្លើង ។ នៅលើភ្នំនោះមានសត្វស្វាជាច្រើន ។ គាត់ទាំងពីរនាក់ត្រូវដេកដោយគ្មានអាហារនៅក្នុងពោះ ។ បន្ទាប់ពីចូលដេកបានមួយស្របក់ បងប្រុសទី៤ស្រែកទឹក ។ បងប្រុសទី៣បានក្រោកឡើងដើររកទឹក ។ នៅពេលត្រឡប់មកវិញឃើញតែភ្នក់ភ្លើង ។ ពេញមួយយប់ដែលបងប្រុសទី៣របស់ខ្ញុំស្រែកហៅបងប្រុសទី៤ ។ គាត់គ្មានសង្ឃឹមថានឹងបានជួបគ្នាវិញទេ ។ គាត់បានសម្រេចចិត្តចុះពីភ្នំសំដៅមកផ្ទះវិញ ។ រហូតមកដល់សព្វថ្ងៃនេះ ជាងម្ភៃឆ្នាំហើយដែលគ្រួសារខ្ញុំនៅតែទន្ទឹងរង់ចាំបងប្រុសទី៤ ។

គ្រួសារខ្ញុំធ្លាប់ពិភាក្សាគ្នាជាញឹកញាប់អំពីការព្រាត់ប្រាសបងប្រុសទី៤ ។ ឪពុកម្តាយខ្ញុំយល់ថាប្រហែលជាកងទ័ពវៀតណាមរើសយកទៅចិញ្ចឹមនៅប្រទេសវៀតណាម ពីព្រោះនៅឆ្នាំ១៩៧៩ វៀតណាមបានប្រមូលកុមារកំព្រាជាច្រើននាក់យកទៅចិញ្ចឹម ។ ចំណែកឯបងប្រុសទី១និយាយថា បើទោះជាកងទ័ពវៀតណាមរើសយកទៅចិញ្ចឹម ក៏បងប្រុសទី៤ពិបាកនឹងត្រឡប់មកវិញដែរ ពីព្រោះនៅជំនាន់ខ្មែរក្រហម បងប្រុសទី៤មិនបានរស់នៅជួបជុំឪពុកម្តាយ គឺទៅរស់នៅក្នុងមណ្ឌលកុមារ ។ ដូច្នេះបងប្រុសទី៤ពិបាកនឹងចាំឈ្មោះឪពុកម្តាយនិងភូមិស្រុកដែលគាត់រស់នៅ ។

នៅក្នុងអំឡុងរបបខ្មែរក្រហម ខ្ញុំមិនត្រឹមតែបាត់បង់បងប្រុសម្នាក់ទេ ខ្ញុំមានពូម្នាក់និងមីងម្នាក់ដែលចូលធ្វើជាកងទ័ពខ្មែរក្រហម ហើយត្រូវបាត់ដំណឹងរហូតមកដល់សព្វថ្ងៃនេះ ។ ខ្ញុំមិនដឹងថាតើគាត់ទាំងពីរនាក់នៅរស់ឬយ៉ាងណាទេ ។

នៅឆ្នាំ២០០០ ខ្ញុំអានឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានប្រទះឃើញបញ្ជីឈ្មោះកុមារមួយសន្លឹកដែលនៅក្នុងនោះមានឈ្មោះពូរបស់ខ្ញុំម្នាក់ឈ្មោះ "ហ៊ុយ ភី" ។ ខ្ញុំមានអារម្មណ៍រំភើបខ្លាំងណាស់នៅពេលដែលបានឃើញឈ្មោះពូរបស់ខ្ញុំ ។ ខ្ញុំបានពាំនាំដំណឹងនេះទៅប្រាប់ដល់លោកតាលោកយាយ ឪពុកម្តាយ មាមីង និងបងប្អូនរបស់ខ្ញុំ ។ អ្នកទាំងអស់គ្នាមានចិត្តសប្បាយរីករាយដូចខ្ញុំដែរ ទោះបីជាមិនដឹងច្បាស់ថាពូខ្ញុំស្លាប់ឬរស់ក៏ដោយ ។

ខ្មែរក្រហមមិនបានសម្លាប់បងប្អូននិងសាច់ញាតិណាម្នាក់របស់ខ្ញុំដោយផ្ទាល់ដៃទេ ។ ទង្វើដែលខ្មែរក្រហមបានធ្វើមកលើក្រុមគ្រួសាររបស់ខ្ញុំគឺគ្រប់គ្រាន់ក្នុងការហៅថា"សម្លាប់"បាត់ទៅហើយ ។ ខ្មែរក្រហមមិនបានសម្លាប់ជីតារបស់ខ្ញុំដោយផ្ទាល់ដៃទេ ប៉ុន្តែការមិនបានផ្តល់អាហារនិងថ្នាំសង្កូវដល់គាត់នោះគឺគ្រប់គ្រាន់នឹងឲ្យជីតារបស់ខ្ញុំស្លាប់ ។ ខ្មែរក្រហមមិនឲ្យពូមីងនិងបងប្រុសរបស់ខ្ញុំរស់នៅជួបជុំគ្រួសារក៏មានន័យថាខ្មែរក្រហមបានសម្លាប់មនោសញ្ចេតនាគ្រួសាររបស់ខ្ញុំដែរ ។

**ហ៊ុយ ខណ្ណៈ**

*ប្រលោមលោកបដិវត្តន៍ខ្មែរក្រហមៈ*

# ស្នាដៃឈ្លាសវៃរបស់កុមារឃ្វាលក្របីក្នុងការកំទេចខ្មាំង

ស្រុកកំចាយមារជាស្រុកមួយឋិតនៅក្នុងខេត្តព្រៃវែង ហើយដែលមានព្រំប្រទល់ជាប់នឹងវៀតណាមខាងត្បូង ។ ប្រជាជនដែលរស់នៅជិតព្រំដែនសុទ្ធសឹងជាកសិករក្រនិងកសិករកណ្តាលថ្នាក់ក្រោម ។ លក្ខណៈភូមិសាស្ត្រនៅតំបន់នេះជាតំបន់វាលរាបគ្មានព្រៃធំទេ មានតែព្រៃកុម្មោតតូចៗ ។ ប្រជាជនប្រកបរបរធ្វើស្រែតែមួយមុខគត់ ។ ឆ្នាំណាភ្លៀងត្រូវ ប្រជាជនធ្វើស្រូវបានល្អបន្តិចដែរ ។ តែកាលមុនពេលរំដោះ ដោយពួកអាក្បត់លន់ណុល សិរិមតៈ សឹងផ្ទុកថាញ់ និងដៃជើងវា ជិះជាន់ឆក់ប្លន់ធ្ងន់ធ្ងរពេក ប្រជាជនយើងនៅម្តុំនោះត្រូវអត់បាយតែរាល់ឆ្នាំ ។

ក្រោយរដ្ឋប្រហារថ្ងៃ ១៨ មីនា ១៩៧០ ពួកអាក្បត់ភ្នំពេញបានប្រគល់ទឹកដីកម្ពុជាប៉ែកខាងកើតឲ្យទៅអាធិរាជព្រៃនគរគ្រប់គ្រងត្រួតត្រា ។ ដូច្នោះកងទ័ពចក្រពត្តិអាមេរិកនិងកងទ័ពអាធិរាជវាប់សែននាក់បានចូលរុករានទន្ទ្រានឈ្លានពានដែនកម្ពុជាប៉ែកខាងកើតយ៉ាងសាហាវយង់ឃ្នងបំផុត ។ ប្រជាជននៅស្រុកកំចាយមារក៏ដូចប្រជាជនយើងដែលនៅជិតព្រំដែនវៀតណាមផ្សេងទៀតដែរ ត្រូវទទួលរងទុក្ខទោសនិងទារុណកម្មគ្រប់បែបយ៉ាងពីពួកអាចោរឈ្លានពានយ៉ាងព្រៃផ្សៃបំផុត ។ មានការចាប់កូនប្រពន្ធយកទៅរំលោភលេងសើចតាមទំនើងចិត្តវា ការឆក់ប្លន់ស្រូវអង្ករ ជ្រូកមាន់ទា ការបាញ់សម្លាប់គោក្របីស៊ី ការដុតបំផ្លាញភូមិករផ្ទះសំបែង ការកាប់បំផ្លាញដំណាំដាំដុះក្នុងភូមិ ការចាប់ចងវាយដំប្រំធាក់ រហូតដល់ការបាញ់ចោលដូចសត្វធាតុទៀតក៏មាន ។ ការនេះធ្វើឲ្យប្រជាជនយើងនៅតាមព្រំដែនមានការឈឺចាប់ ហើយចងអាឃាតជាមួយពួកអាចោរឈ្លានពានអស់មួយជីវិត ។

ក្រោយរំដោះហើយភ្លាម ពួកអាធិរាជនៅតែបញ្ជូនយន្តហោះឲ្យមកបាញ់រះនិងទម្លាក់គ្រាប់បែកបំផ្លិចបំផ្លាញភូមិករផ្ទះសំបែងផលដំណាំ និងគោក្របីរបស់ប្រជាជនយើងទៀត ។ ជួនកាលវាបញ្ជូនទាហានវាឲ្យចូលមកឆក់ប្លន់ស្រូវអង្ករ គោក្របី ជ្រូកមាន់ទា ដឹកយកទៅវៀតណាមខាងត្បូងអស់ទាំងភូមិៗ ។ អំពើឈ្លានពានរឹបជាន់ឆក់ប្លន់និងកាប់សម្លាប់យ៉ាងសាហាវឃោរឃៅ ហ្វាស៊ីសរបស់ចក្រពត្តិអាមេរិកនិងបនអាធិរាជព្រៃនគរទាំងនេះបានដុតភ្លើងកំហឹងជាតិឲ្យឆេះសន្ធោសន្ធៅជាប់ជានិច្ចនៅក្នុងប្រជាជនយើងតាមព្រំដែន ។ ទោះបីជាខ្មាំងសត្រូវបង្ក្រាបរាតត្បាត កាប់សម្លាប់ និងបំផ្លិចបំផ្លាញយ៉ាងនេះក៏ដោយក៏ប្រជាជនយើងនៅតាមព្រំដែនទាំងប្រុសទាំងស្រីទាំងចាស់ទាំងក្មេងមិនសុខចិត្តរត់ទៅណាដែរ ។ បងប្អូនប្តេជ្ញានៅប្រយុទ្ធជាមួយវា ការពារទឹកដីមាតុភូមិកម្ពុជា ការពារស្រុកភូមិដែលជាកេរដំណែលតាំងពីដូនតាមក មិនឲ្យបាត់បង់សូម្បីតែមួយចំអាមក៏ទេដែរ ។ ក្រោមការដឹកនាំដ៏ឈ្លាសវៃនៃអង្គការបដិវត្តន៍ ប្រជាជនយើងបានចាត់តាំងជាកងឈ្លបប្រដាប់អាវុធទាំងសម័យទាំងបុរាណដើម្បីការពារភូមិ-ឃុំខ្លួន ។ រីឯផលដំណាំជាយុទ្ធសាស្ត្រផ្សេងៗដូចជាស្រូវ ពោត ដំឡូង ជាដើម ក្រោយពេលប្រមូលផលហើយភ្លាម បងប្អូនប្រញាប់ដឹកជញ្ជូនយកទៅលាក់ទុកដាក់នៅឃ្លាំងសំងាត់ឆ្ងាយៗពីផ្ទះសំបែងអស់ ។ សូម្បីតែកុមារឃ្វាលក្របីតូចៗក៏មានការប្រុងប្រយ័ត្នខ្ពស់ដែរ ។ ឲ្យតែឮសូរយន្តហោះ កុមារនាំគ្នាដេញគោក្របីយកទៅលាក់បំពួនក្នុងព្រៃកុម្មោតអស់ ។ ហើយបើពេលណាដឹងថាទាហានអាធិរាជចូលមកភូមិហើយ កុមារតែងនាំគ្នាដេញក្របីពន្លាសពន្លាងទៅឆ្ងាយៗពីភូមិ ។ ថ្ងៃនេះ កុមារ ផាត ត្រូវវេនទៅឃ្វាលក្របីរបស់សហករណ៍ ។ ដោយរដូវនេះជារដូវប្រាំង មិនសូវសំបូរស្មៅសំបូរទឹកទេ ។

ដូច្នេះ ថ្ងៃនេះកុមារ ផាត ត្រូវដឹកក្របីទៅឃ្វាលនៅទីឆ្ងាយៗពីភូមិ ដើម្បីមានស្មៅមានទឹកល្មមគ្រប់គ្រាន់ឲ្យក្របី ។ កុមារស្រលាញ់ក្របីរួមរបស់សហករណ៍ណាស់ ។ ដល់វេនកុមារឃ្វាលក្របីម្តងៗ កុមារយកចិត្តទុកដាក់មើលថែទាំក្របីយ៉ាងជិតស្និត រកមើលកន្លែងណាមានស្មៅល្អទើបយកក្របីទៅចង ។ បន្តិចកុមារមកមើលផ្លាស់កន្លែងម្តង ។ បន្តិចមកមើលផ្លាស់កន្លែងទៀត ដើម្បីឲ្យក្របីស៊ីស្មៅបានឆ្អែត ។ ក្នុងមួយថ្ងៃៗ កុមារឲ្យទឹកក្របីបី-បួនដងកុំឲ្យវាក្តៅ ។ ល្ងាចថ្ងៃនេះ ក្រោយពេលដែលកុមារបានយកវាទៅមុជទឹកដុសលាងស្អាតហើយ កុមារក៏ឡើងជិះលើខ្នងក្របីមួយ បណ្តើរហ្វូងវាទាំងអស់ត្រឡប់មកភូមិវិញ ។ តែដោយផ្លូវឆ្ងាយបន្តិច ទាល់តែព្រលប់ព្រាលៗទើបកុមារត្រឡប់មកដល់ភូមិវិញ ។ ជាទំលាប់ប្រុងប្រយ័ត្នបដិវត្តខ្ពស់របស់កុមារ មុននឹងត្រឡប់ចូលភូមិវិញម្តងៗ កុមារតែងតែក្រឡេកមើលនាយអាយ ពិនិត្យមើលសភាពការណ៍ក្នុងភូមិតាំងពីចម្ងាយ រួចហើយផ្ទៀងស្តាប់ក្រែងមានសូរស័ព្ទអ្វីចំឡែកនៅក្នុងភូមិ ។ ល្ងាចនេះ ពេលកុមារជិះក្របីមកជិតដល់ភ្លាម ក៏ស្រាប់តែឃើញភ្លក់ភ្លើងជាច្រើនឆេះភ្លឺរន្ទាលពេញទាំងភូមិខុសប្លែកពីធម្មតា ។ កុមារនឹកមន្ទិលក្នុងចិត្តជាខ្លាំង ក៏បញ្ឈប់ក្របីចុះហើយយកវាទៅចងទុកមួយកន្លែងសិន ។ រួចកុមារក៏លបដើរសៀរៗទៅជិតភូមិដើម្បីពិនិត្យសភាពការណ៍ឲ្យបានច្បាស់លាស់ថែមទៀត ។ លុះទៅជិតទើបឮសូរស័ព្ទសំឡេងពួកទាហានអាធិរនៅក្នុងភូមិ ។ ពួកវាទើបមកដល់ ហើយកំពុងដើរគំរាមកំហែងប្រជាជនឲ្យដាំបាយឲ្យវាស៊ី ហើយឲ្យកាប់គោក្របីទទួលពួកវាទៀត ។ តែពេលនោះពុំទាន់មានគោក្របីត្រឡប់ចូលភូមិមួយក្បាលទេ ព្រោះកុមារឃ្វាលក្របីក្នុងក្រុមសហករណ៍ផ្សេងៗទៀតដឹងសភាពការណ៍នេះមុន បានដេញគោក្របីទៅឆ្ងាយៗពីភូមិអស់ទៅហើយ ។ ឃើញសភាពការណ៍ដូច្នេះ កុមារ ផាត ក៏លូនត្រឡប់ក្រោយវិញយ៉ាងប្រញាប់ ។ កុមារដើរស្រាយក្របីទាំងអស់ជាបន្ទាន់ រួចហើយដេញបំបែកវាឲ្យទៅឆ្ងាយៗពីភូមិអស់ ។ ***(នៅមានត)***

# លិខិតពីសាលាបឋមសិក្សាព្រះនរោត្តម

*ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០២*

*លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

*ឯកឧត្តមជាទីគោរពរាប់អាន*

*នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមដែលបានផ្តល់នូវទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងមួយលេខចំនួន៤ច្បាប់ (០៤) ចាប់ពីលេខ១៩ដល់លេខ២៨ និងទស្សនាវដ្តីស្វែងរកការពិតជាភាសាអង់គ្លេសចំនួន១២ច្បាប់ ព្រមទាំងសៀវភៅដែលមានចំណងជើងថា "ជនរងគ្រោះឬជនដៃដល់" ចំនួន០១ក្បាល ។*

*នាងខ្ញុំសូមគោរពជូនពរមហាប្រសើរចំពោះឯកឧត្តមព្រមទាំងសហការីទាំងអស់ដែលកំពុងស្រាវជ្រាវរកការពិត និងកំពុងខិតខំដើម្បីធ្វើយ៉ាងណាឲ្យមានដំណើរការកាត់ទោសខ្មែរក្រហមជនប្រល័យពូជសាសន៍ឲ្យបានជោគជ័យក្នុងពេលដ៏ខ្លីខាងមុខនេះ ដោយក្តីសង្ឃឹមបំផុតរបស់ប្រជាជនរងគ្រោះទាំងអស់និងអ្នកដែលស្លាប់ហើយព្រលឹងគេកំពុងតែដង្ហោយហៅរកយុត្តិធម៌ ។ ដើម្បីឲ្យព្រលឹងអ្នកដែលស្លាប់បានទៅចាប់ភពថ្មីប្រកបដោយសេចក្តីសុខ និងអ្នកដែលរងគ្រោះកំពុងរស់នៅសព្វថ្ងៃនេះបានស្ងប់ចិត្តស្ងប់អារម្មណ៍ ដើម្បីរស់នៅកសាងសង្គមគ្រួសារនិងសង្គមជាតិមួយដែលពោរពេញទៅដោយសេរីភាព ប្រជាធិបតេយ្យ យុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ ដែលប្រជាជនកម្ពុជាទូទៅកំពុងតែទន្ទឹងចង់បាន ។*

*សូមឯកឧត្តមទទួលនូវសេចក្តីរាប់អានអំពីនាងខ្ញុំ*

**លឹម ស្រីផល្លា**

*កំណាព្យខ្មែរក្រហម*

# ជាច់ខាតការពារព្រំដែនកម្ពុជាដ៏ពិសិដ្ឋ

១)　ជួរភ្នំក្រវាញ ភ្នំដងរែក　លាតវែងអនេកជាប់ខ្ពង់រាប　ឦសាន បូព៌ា ឧត្ដរ ទាប
ទំនាបនិរតីទល់សមុទ្រ ។

២)　ព្រំដែនពិសិដ្ឋនៃកម្ពុជា　បុត្រអ្នកការពារត្រៀមប្រយុទ្ធ　ដៃក្ដាប់កាំភ្លើងភ្នែកវៃមុត
រាល់ខ្មាំងរន្ធត់ស្លុតរួញអស់ ។

៣)　ចុងឈើ-លើភ្នំ-ក្នុងព្រៃស្រោង　គ្មានទេប្រហោងប្អូចន្លោះ　ព្រៃស្បាត រនាម ព្រៃរបោះ
រូង ប្រក កៀនកោះ ត្រៀមស្ទាក់ស្កាត់ ។

៤)　ទន្លេ ស្ទឹង អូរ ជ្រលងជ្រោះ　ផងផឹតជ្រៅហួសជ្រងំស្ងាត់　រុករើក្រោមលើប្រុងប្រយ័ត្ន
ខ្មាំងចូលត្រូវខ្ចាត់ជាដេះដង ។

៥)　ព្រំដែនពិសិដ្ឋកម្ពុជាអើយ　អ្នកធ្លាប់ល្បីល្បើយពីយូរលង់　វណ្ណៈជិះជាន់ក្បត់លិចលង់
រក្សាមិនគង់សាងមិនកើត ។

៦)　ឥឡូវបុត្រអ្នកយកទ្រូងពាំង　រារាំងមិនឲ្យខ្មាំងមកអើត　ពង្រីកសាងអ្នកឲ្យឆើត
លិច កើត ត្បូង ជើង ណែនមាំល្អ ។

៧)　ដែនគោករឹងហើយមុខមាត់ថ្មី　ប្រណាំងដោតជ័យដែនលំហ　សមុទ្រនិងកោះស្រស់បវរ
ល្បីល្បាញខ្ទរខ្ទរខ្ទប់ល្បិចខ្មាំង ។

៨)　ខ្មាំងចូលលិចលង់ចូលវិនាស　កូនយកទ្រូងពាសជារបាំង　យាមល្បាតបើកបរបោះទីតាំង
កំទេចខរខាំងខ្មាំងទាំងអស់ ។

៩)　ដែនគោកដែនទឹករឹងគង់វង្ស　ធានាខាងក្នុងមហាលោតផ្លោះ　មហាថ្កើងថ្កានមហាស្ទុះហោះ
មហារុងរឿងខ្ពស់មហាអស្ចារ្យ ។

១០)　កម្មករកសិករកងទ័ពអ្នក　ស្មោះស្ម័គ្របូជាឈាមស្រស់ថ្លា　ក្រហមប្រាលឆ្អៅគ្រប់វេលា
ជាច់ខាតការពារអ្នករៀងទៅ ។

“យុវជននិងយុវនារីបដិវត្ត” លេខ៣ ខែមីនា ឆ្នាំ១៩៧៦

*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*
*ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់នៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 30, June 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
the Royal Danish Government; Swedish International Development Co-operation Agency (Sida);
and the Royal Netherlands Government, *The Hague*.